សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## ការប្រៀបធៀបប្រកាសនីយបត្រឥណកម្មក្រោមច្បាប់ជាតិ និងអន្តរជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១

រៀបរៀងដោយ

និស្សិតឈ្មោះ ៖ ក. **ស្រេង យូគីម**

ក. **ជុំ អូរីសា**

សាស្ត្រាចារ្យណែនាំ៖

**លោក ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១ (សិក្សាបង់ថ្លៃ)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ស្រេខ យូគីម** និង **ជុំ អូទីសុា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២១ ឆ្នាំសិក្សា២០១៧-២០២១។

សូមសម្ដែងនូវកត្តញ្ញូតធម៌ និងសេចក្ដីថ្លែងអំណរអរគុណចំពោះ

លោកអ្នកមានគុណ និងបងប្អូនប្រុស-ស្រី បានផ្ដល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាប្រកបដោយក្ដីស្រលាញ់ ផ្ដល់ការអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ មិនតែប៉ុណ្ណោះបានជម្រុញនិងលើកទឹកចិត្តបញ្ជូនយើងខ្ញុំមកសាលារៀនដើម្បីទទួលបានការអប់រំ និងបានផ្គត់ផ្គង់ទាំងសម្ភារៈក្នុងការសិក្សានិងសតិស្មារតីដើម្បីបន្តដំណើឆ្ពោះទៅរកអនាគតដ៏រុងរឿង។

រាជរដ្ឋាភិបាល ក្រសួងអប់រំ និង ឯកឧត្តមសកលវិទ្យាធិការ ឯកឧត្តមវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យគ្រប់រូប និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃសាកលវិទ្យាល័យដែលបានបង្ហាត់បង្រៀន និងបង្កនូវភាពងាយស្រួលក្នុងការសិក្សា។

សាស្ត្រាចារ្យ **ទេព សុខ** ដែលបានបង្ហាត់បង្រៀន និងណែនាំរៀបចំក្នុងការស្រាវជ្រាវនេះឲ្យលេញចេញជារូបរាងឡើង។

លោកគ្រូ-អ្នកគ្រូ សិស្សច្បង-សិស្សប្អូន ក្រុមការងារ និងមិត្តភក្តិទាំងអស់ ដែលបានជួយកែសម្រួលដល់យើងខ្ញុំក្នុងការស្រាវជ្រាវប្រធានបទនេះតាមរយៈការផ្ដល់ជាគំនិតយោបល់ និងឯកសារជាដើម។

ជាចុងក្រោយសូមគោរពជូនពរដល់ លោកអ្នកមានគុណ បងប្អូនប្រុស-ស្រី សាស្ត្រាចារ្យគ្រប់រូបនិងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកគ្រូ-អ្នកគ្រូ សិស្សច្បង-សិស្សប្អូន ក្រុមការងារ និងមិត្តភក្តិទាំងអស់ សូមជួបតែសេចក្ដីសុខចម្រើននិងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីប្រទេសកម្ពុជាចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១៣ តុលា ២០០៤ មក ភាគីកម្ពុជាព្យាយាមយ៉ាងខ្លាំងក្នុងការអនុម័តច្បាប់ដែលគោរពតាមច្បាប់អន្តរជាតិដើម្បីមកអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចប្រទេសកម្ពុជា។ ជាពិសេសជាងនេះទៅទៀតគឺ គោរពនូវវិធានច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកដែលបានដាក់បន្ទុកកាតព្វកិច្ចដល់រដ្ឋជាសមាជិកត្រូវតែគោរពតាម។ ការចូលខ្លួនជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកគឺជា ការបង្ហាញឆន្ទៈរបស់ប្រទេសកម្ពុជាក្នុងការទាញខ្លួនចេញពីប្រទេសកំពុងអភិវឌ្ឍន៍មកជាប្រទេសអភិវឌ្ឍន៍ តាមរយៈវិស័យពាណិជ្ជកម្មដោយមានចង្កូវិស័យវែងឆ្ងាយដើម្បីទាក់ទាញអ្នកវិនិយោគពីបរទេសដោយការអនុម័តច្បាប់និងការចូលជាសមាជិករបស់អង្គការពិភពលោក។

បន្ទាប់ពីក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាយើងបានអនុម័តច្បាប់ជាច្រើនជាពិសេសគឺ ច្បាប់ដែលមានគោលដៅក្នុងការគ្រប់គ្រងវិស័យពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញា។ យ៉ាងណាមិញមុនពេលដែលកម្ពុជាក្លាយជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកកម្ពុជាក៏បានអនុម័ត និងប្រកាសឱ្យប្រើប្រាស់នូវច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំរូឧស្សាហកម្មនៅថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០៣ ដែលមានគោលដៅការពារនូវសិទ្ធិ និងកំណត់នូវកាតព្វកិច្ចនៃតក្កកម្មដែលបានចុះបញ្ជីស្របតាមច្បាប់ក្នុងប្រទេសកម្ពុជា។

បន្ថែមលើនេះទៅទៀត កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដែលបានបង្កើតដោយអង្គការពាណិជ្ជកម្មពិភពលោក និងបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥ គឺជាកិច្ចព្រមព្រៀងកំណត់អំពីប្រភេទនៃកម្មសិទ្ធិបញ្ញាទាំងឡាយដែលបានកំណត់ពីសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋជាសមាជិកដែលត្រូវគោរពតាម ហើយក្នុងកិច្ចព្រមព្រៀងនេះក៏បានចែងអំពីប្រកាសនីយបត្រតក្កកម្មដែរ។

ការសម្រេចចិត្តជ្រើសរើសស្រាវជ្រាវលើប្រធានបទទាក់ទងនឹង «**ការប្រៀបធៀបប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ និងអន្តរជាតិ**» ពីព្រោះយើងខ្ញុំគិតថា ការយល់ដឹងឱ្យច្បាស់អំពីការអនុវត្តសិទ្ធិនិងកាតព្វកិច្ចដែលទទួលបានក្រោមច្បាប់ជាតិ និងអន្តរជាតិមានសារៈសំខាន់ណាស់ជាពិសេសក្នុងបរិបទនៃសម័យកូវីដ១៩នេះ ព្រោះថាក្នុងករណីអាចមានក្រុមហ៊ុនផលិតឱសថបានរកឃើញថ្នាំដែលអាចព្យាបាលជំងឺកូវីដនេះរដ្ឋាភិបាលអាចយកតក្កកម្មនោះមកប្រើប្រាស់ ឬអនុញ្ញាតឱ្យក្រុមហ៊ុនផ្សេងទៀតមានសិទ្ធិក្នុងការផលិតឱសថតាមរយៈតក្កកម្មនោះ ដោយទទួលមកវិញនូវផលចំណេញដែលកំណត់ដោយរដ្ឋាភិបាល។

ជាចុងក្រោយនាងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងក្លាយជាឯកសារ និងអាចជាការផ្តល់នូវចំណេះដឹងខ្លះៗ ឬអាចជាអត្ថបទជំនួយស្មារតីដល់បុគ្គលពាក់ព័ន្ធដែលពួកគាត់មានបំណងធ្វើការ

ស្រាវជ្រាវអំពីប្រកាសនីយបត្រតក្កកម្ម ពិសេសសិស្សប្អូនជំនាន់ក្រោយ ឬម្ចាស់តក្កកម្មទាំងឡាយឱ្យយល់ច្បាស់ពីសិទ្ធិនិងកាតព្វកិច្ចដែលត្រូវគោរពតាមបន្ទាប់ពីចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្ម។ ម៉្យាងទៀតដែរនេះ ក្នុងករណីមានកំហុសខុសឆ្គងលើខ្លឹមសារ ឬអក្ខរាវិរុទ្ធ សូមខន្តីអភ័យទោស ហើយនាងខ្ញុំទាំងពីរនាក់រីករាយនឹងទទួលយកការរិះគន់ដើម្បីស្ថាបនាក្នុងគោលបំណងធានាថាការងារនេះនឹងកាន់តែល្អប្រសើរ និងក្នុងកម្រិតដែលអាចទទួលយកបានពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់គ្នា។

# **អំណះអំណាង**

យើងខ្ញុំទាំងពីរឈ្មោះ **ស្រេង យូគីម** និង **ជុំ អូវីស្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ ឆ្នាំសិក្សា២០១៧ ដល់ ឆ្នាំ ២០២១នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរសូមធ្វើការអះអាងថាចំពោះខ្លឹមសារនៃសារណាបញ្ចប់ការសិក្សានេះ គឺមិនបានចំលងពីសារណា ឬរបាយការណ៍របស់បុគ្គលណាមួយ ឬក៏មានបុគ្គលណាមួយមកសរសេរជំនួសនោះឡើយ។ រាល់ខ្លឹមសារទាំងឡាយដែលមានសរសេរក្នុងនេះ រាល់អក្ខរាវិរុទ្ធនីមួយៗគឺកើតចេញពីគំនិតរបស់ពួកយើងទាំងពីរនាក់ដោយមានការជួយជ្រោមជ្រែង និងការបង្ហាត់បង្ហាញតាមរយៈការណែនាំរបស់លោកសាស្ត្រចារ្យ **ទេព សុខ** ទើបពួកយើងទាំងពីរអ្នកបានបញ្ចប់សារណានេះយ៉ាងរលូនប្រកបដោយជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២១

**ហត្ថលេខា**

**ស្រេង យូគីម** **ជុំ អូវីស្សា**

# មាតិកា

**សេចក្តីផ្តើម**............................................................... ១

## ជំពូកទី១
## សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្ម

**១.១. ប្រភពនៃប្រកាសនីយបត្រតក្កកម្ម**............................................................... ៣

១.១.១. ប្រភពអន្តរជាតិ............................................................... ៣

១.១.២. ប្រភពតាមតំបន់............................................................... ៤

១.១.៣. ប្រភពជាតិ............................................................... ៥

**១.២. សញ្ញាណគតិយុត្តិនៃប្រកាសនីយបត្រតក្កកម្ម**............................................................... ៦

១.២.១. ប្រវត្តិនៃការវិវត្តរបស់ប្រកាសនីយបត្រតក្កកម្ម............................................................... ៦

១.២.២. និយមន័យ............................................................... ៧

១.២.៣. អត្ថប្រយោជន៍ដែលទទួលបានពីការការពារដោយច្បាប់............................................................... ១០

## ជំពូកទី២
## ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិនិងច្បាប់អន្តរជាតិ

**២.១. នីតិវិធីការចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ**............................................................... ១៣

២.១.១. លក្ខខណ្ឌគ្រឹះនៃការចុះបញ្ជី............................................................... ១៣

២.១.២. លក្ខខណ្ឌទម្រង់ចុះបញ្ជី............................................................... ១៥

**២.២. ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់អន្តរជាតិ**............................................................... ២១

២.២.១. ការដាក់ពាក្យ............................................................... ២១

២.២.២.ការស្រាវជ្រាវជាអន្តរជាតិ............................................................... ២៣

២.២.៣.ការផ្សព្វផ្សាយជាអន្តរជាតិ............................................................... ២៤

២.២.៤. ការស្រាវជ្រាវអន្តរជាតិបន្ថែម(មិនតម្រូវនោះទេ)............................................................... ២៤

២.២.៥. ការត្រួតពិនិត្យបឋមអន្តរជាតិ (មិនតម្រូវនោះទេ)............................................................... ២៥

២.២.៦.ដំណាក់កាលអនុវត្តក្នុងប្រទេស............................................................... ២៥

២.២.៧. តម្លៃសេវា............................................................... ២៥

**២.៣. ការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មរបស់បរទេស** ........ ២៦
២.៣.១. ប្រកាសនីយបត្រតក្កកម្មកម្ពុជាជាមួយនឹងការិយាល័យប្រកាសនីយបត្រតក្កកម្មជប៉ុន ........ ២៦
២.៣.២. ការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ........ ២៦
២.៣.៣. ការទទួលស្គាល់នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ........ ២៧
**ជំពូកទី៣**
**សិទ្ធិនិងភាតព្វកិច្ចដែលទទួលបានបន្ទាប់ពីការចុះបញ្ជី**
**៣.១. អាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ** ........ ២៩
៣.១.១. ប្រភេទអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ ........ ២៩
៣.១.២. លក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណបញ្ជា ........ ៣៣
៣.១.៣. ការរំលោភសិទ្ធិ និង ដំណោះស្រាយវិវាទ ........ ៣៥
**៣.២. អាជ្ញាប័ណ្ណនៃប្រកាសសនីយបត្រតក្កកម្មក្រោមច្បាប់អន្តរជាតិ** ........ ៣៨
៣.២.១. ប្រភេទនៃអាជ្ញាប័ណ្ណប្រកាសនីយបត្រតក្កកម្ម ........ ៣៨
៣.២.២. សិទ្ធិដែលទទួលបាន ........ ៤៥
៣.២.៣. ការដោះស្រាយវិវាទ ........ ៤៥
**សេចក្តីសន្និដ្ឋាន** ........ ៤៨
**អនុសាសន៍** ........ ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ជារឿយៗនៅរាល់ពេលដែលយើងទិញទំនិញតាមរយៈការដោះដូរជាប្រាក់នោះគឺមានន័យថា យើងបានសង ត្រលប់ទៅម្ចាស់ដើមវិញដោយសារពួកគាត់បានចំណាយពេលវេលា ថវិការ ការប្រឹងប្រែង ក៏ដូចជាគំនិតច្នៃប្រឌិតក្នុង ការបង្កើតនូវស្នាដៃមក។ ជាងនេះទៀតនោះ វាជាការជម្រុញលើកទឹកចិត្តក្នុងការបង្កើតផលិតផលថ្មីៗ និងគំនិតច្នៃ ប្រឌិតក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មពិភពលោក។ ទន្ទឹមនឹងសេដ្ឋកិច្ចរបស់ពិភពលោកមានការរីកចម្រើន បច្ចេកវិទ្យា ក៏មានការរីកលូតលាស់ណាស់ដែរដែលបច្ចេកទេសទាំងនោះកើតឡើងពីគំនិតច្នៃប្រឌិត និងការប្រកួតប្រជែងរបស់ មនុស្ស។ ដូច្នេះរឿងដែលគួរតែយកចិត្តទុកដាក់មួយទៀតគឺ បញ្ហានៃការការពារកម្មសិទ្ធិបញ្ញាក្នុងពិភពលោករួមមាន ទាំងកម្ពុជាផងដែរ។ នេះក៏ដោយសារតែប្រទេសកម្ពុជា ប្រកាន់យកនូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីដូចប្រទេសជាច្រើន ក្នុងសកលលោក ស្របពេលដែលកម្ពុជាចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក និងការចូលទៅក្នុង សហគមន៍សេដ្ឋកិច្ចអាស៊ាន (ឆ្នាំ ២០១៥) យើងបានចាប់ផ្តើមយកចិត្តទុកដាក់អំពីបញ្ហានេះ។

ច្បាប់កម្មសិទ្ធិបញ្ញាបានបង្កើតឡើង គឺក្នុងគោលបំណងការពារម្ចាស់កម្មសិទ្ធិដែលបានចំណាយសមត្ថភាព ច្នៃប្រឌិតក្នុងការបង្កើតនូវអ្វីថ្មីៗ។ កម្មសិទ្ធិបញ្ញាចែកចេញជាច្រើនប្រភេទផ្សេងគ្នាដូចជា សិទ្ធិអ្នកនិពន្ធ និងសិទ្ធិ ប្រហាក់ប្រហែល ម៉ាក ពាណិជ្ជនាម ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូ ឧស្សាហកម្ម។ យ៉ាងណាមិញការការពារសិទ្ធិ និងកាតព្វកិច្ចចំពោះកម្មសិទ្ធិបញ្ញាមានលក្ខណៈខុសៗទៅតាមប្រភេទ របស់កម្មសិទ្ធិបញ្ញានីមួយៗ។ នៅក្នុងចំណោម ប្រភេទនៃកម្មសិទ្ធិបញ្ញាទាំងឡាយដែលបានរៀបរាប់ខាងលើនេះ ប្រកាសនីយបត្រតក្កកម្មមានលក្ខណៈគួរឱ្យកំណត់សម្គាល់មួយគឺ វាពាក់ព័ន្ធនឹងការរកនូវដំណោះស្រាយថ្មីសម្រាប់ បញ្ហាណាមួយ។ តាមរយៈតក្កកម្មដែលគេបានកំណត់និយមន័យ គឺជាគំនិតរកឃើញរបស់តក្កករដែលអាចយកទៅ អនុវត្តបាន នៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា ឬអាចជាការរកឃើញផលិតផល ឬ ដំណើរការផលិតកម្ម ឬអាចជាការឃើញអ្វីមួយដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិត[1]។ ប៉ុន្តែទោះបីជា យ៉ាងនេះក្តីដើម្បីទទួលបានការការពារទៅលើតក្កកម្មរបស់ខ្លួន លុះត្រាតែតក្កករធ្វើការស្នើសុំប្រកាសនីយបត្រតក្កកម្ម តាមរយៈការចុះបញ្ជីតក្កកម្ម។ ក្រោយពេលដែលទទួលបានប្រកាសនីយបត្រតក្កកម្ម គឺបានបង្កើតឱ្យមានសិទ្ធិនិង កាតព្វកិច្ចទៅលើម្ចាស់តក្កកម្ម។ បន្ថែមលើពីនេះទៅទៀត ម្ចាស់តក្កកម្មមានសិទ្ធិផ្តាច់មុខលើតក្កកម្មដែលបានចុះ បញ្ជីនោះ ពោលសិទ្ធិផ្តាច់មុខនេះគឺបានហាមឃាត់ដល់បុគ្គលដទៃទៀត ដែលបានធ្វើការផលិតនូវផលិតផលណា មួយប្រើប្រាស់នូវតក្កកម្មនោះដើម្បីទទួលបានផលិតផលដូចគ្នាតែយកជាប្រយោជន៍ផ្ទាល់ខ្លួន។ ទន្ទឹមគ្នានេះម្ចាស់ តក្កកម្មអាចធ្វើអាជីវកម្មបន្តទៅលើតក្កកម្មរបស់ខ្លួនបាន ដើម្បីស្វែងរកប្រាក់ចំណេញដែលនេះគឺជាចំណុចយ៉ាង

[1] មាត្រា៣ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

សំខាន់និងជាផលប្រយោជន៍ដែលម្ចាស់តក្កកម្មអាចធ្វើបាន បន្ទាប់ពីចុះបញ្ជីតក្កកម្មនោះដោយសារវាជាផ្នែកមួយនៃសិទ្ធិដែលម្ចាស់តក្កកម្មទទួលបាន។

ផ្ទុយទៅវិញដើម្បីជាការការពារ បង្កើតឱ្យមានតុល្យភាពក្នុងការប្រើប្រាស់សិទ្ធិរបស់ម្ចាស់តក្កកម្ម និងដើម្បីកុំឱ្យម្ចាស់អាជីវកម្មប្រើប្រាស់សិទ្ធិរបស់ខ្លួនហួសហេតុ ចំពោះករណីដែលតក្កកម្មនោះក្លាយជាប្រធានយ៉ាងសំខាន់ក្នុងពេលដែលប្រទេសត្រូវការជាចំបាច់ ជាពិសេសក្នុងករណីដើម្បីបម្រើដល់សេវាសុខភាពសារធារណៈរដ្ឋាភិបាលអាចធ្វើការអនុញ្ញាតឱ្យតតិយជនណាមួយធ្វើអាជីវកម្មលើតក្កកម្មនោះតាមរយៈ«ការផ្តល់អាជ្ញាប័ណ្ណ»។ ការណ៍នេះបានបញ្ជាឱ្យឃើញថា បន្ទាប់ពីធ្វើការចុះបញ្ជីស្នើសុំប្រកាសនីយបត្រតក្កកម្មរួចរាល់ហើយ ម្ចាស់អាជីវកម្មអាចធ្វើអាជីវកម្មស្វែងរកប្រាក់ចំណេញចេញពីតក្កកម្មរបស់ខ្លួន ឬក្នុងករណីមួយវិញផ្សេងទៀតរដ្ឋាភិបាលអាចធ្វើអាជីវកម្មលើតក្កកម្មបានកាលណាក្នុងករណីចាំបាច់។ ចំពោះការនេះអាចធ្វើទៅបាន លុះត្រាតែការអនុវត្តនោះត្រឹមត្រូវតាមច្បាប់ដែលមានអនុវត្តជាធរមានរបស់ប្រទេស។ ជាឧទាហរណ៍នៅប្រទេសកម្ពុជាយើងមានច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍ និងគំរូឧស្សាហកម្ម។ ការអនុវត្តច្បាប់របស់ប្រទេសនីមួយៗក៏ត្រូវមើលទៅលើច្បាប់អន្តរជាតិដែលប្រទេសនោះជាសមាជិកដែរ។ ប្រសិនបើប្រទេសមួយ ចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកយើងអាចមើលលើកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា។

ក្នុងកិច្ចការស្រាវជ្រាវសារណានេះយើងខ្ញុំទាំងពីរនាក់ នឹងធ្វើការបកស្រាយអំពីការប្រៀបធៀបប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ និងក្រោមច្បាប់អន្តរជាតិដែលបានធ្វើការបែងចែកជា៣ជំពូក៖

-ជំពូកទី១ ធ្វើការបកស្រាយអំពី «សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្ម» ដោយរួមបញ្ចូលដោយប្រភពនៃប្រកាសនីយបត្រតក្កកម្ម ប្រវត្តិនៃប្រកាសនីយបត្រតក្កកម្ម និងនីតិវិធីក្នុងការចុះបញ្ជីក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

-ជំពូកទី២ ធ្វើការបកស្រាយអំពី «ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ និងអន្តរជាតិ »។

-ជំពូកទី៣ នឹងផ្តោតទៅលើ «សិទ្ធិ និងកាតព្វកិច្ចដែលទទួលបានបន្ទាប់ពីការចុះបញ្ជី»។

ការបកស្រាយទាំងមូលមានខ្លឹមសារដូចតទៅនេះ៖

# ជំពូកទី១
# សញ្ញាណទូទៅនៃប្រកាសនីយបត្រតក្កកម្ម

## ១.១. ប្រភពនៃប្រកាសនីយបត្រតក្កកម្ម

### ១.១.១. ប្រភពអន្តរជាតិ

ប្រភពអន្តរជាតិគឺសំដៅដល់កិច្ចព្រមព្រៀងទាំងឡាយណា ដែលបានកំណត់ដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងអង្គការពាណិជ្ជកម្មពិភពលោកក្នុងកិច្ចព្រមព្រៀងស្ដីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា វាគឺជាកិច្ចព្រមព្រៀងមួយដែលក្នុងក្របខណ្ឌនេះមានគោលបំណងធ្វើការការពារកម្មសិទ្ធិបញ្ញានៅរាល់បណ្ដាប្រទេសទាំងឡាយដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ក្នុងនោះផងដែរប្រភពក្នុងក្របខណ្ឌអន្តរជាតិមានដូចជាអនុសញ្ញាទីក្រុងប៉ារីសស្ដីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មឆ្នាំ ១៨៨៣ និងអនុសញ្ញាទីក្រុងប៊ែនស្ដីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និងសិល្បៈឆ្នាំ ១៨៨៦។

ប្រកាសនីយបត្រតក្កកម្មដែលជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា ទទួលបានការអភិវឌ្ឍន៍ជាយូរណាស់មកហើយ មិនមែនទើបតែកើតមានបច្ចុប្បន្ននោះទេ។ ប្រកាសនីយបត្រតក្កកម្មនេះចាប់ផ្ដើមទទួលបានការទទួលស្គាល់គឺចាប់តាំងពីមុនសម័យនៃបដិវត្តន៍ឧស្សាហកម្មទៅទៀត។ ដោយច្បាប់ប្រកាសនីយបត្រតក្កកម្មនេះគឺរកឃើញដំបូងបំផុតនៅប្រទេសអ៊ីតាលីនៅក្នុងឆ្នាំ ១៤២១។

ការណ៍នេះបានសរបញ្ជាក់ឱ្យឃើញថា ប្រកាសនីយបត្រតក្កកម្មគឺបានកកើតឡើងតាំងពីមុនសម័យកាលបដិវត្តន៍ឧស្សាហកម្មទៅទៀត ដែលនាពេលនោះការផ្ដល់នូវប្រកាសនីយបត្រតក្កកម្មដំបូងបំផុតរបស់ការរកឃើញថ្មីនៃឧស្សាហកម្មទៅស្ថាបត្យករ និងវិស្វករអគ្គសនីលោក Fillippo Brunelleschi ដោយគេឱ្យរយៈពេលគាត់ចំនួនបីឆ្នាំក្នុងការប្រើប្រាស់សិទ្ធិផ្ដាច់មុខក្នុងការផលិតជណ្ដើរយន្ត ដែលមានឧបករណ៍លើកស្ទូចប្រើសម្រាប់ដឹកថ្មម៉ាប។[2] ការផ្ដល់នូវសិទ្ធិពិសេសជូនទៅម្ចាស់ដែលបានរកឃើញនូវបច្ចេកទេសថ្មីនេះបានរីកសាយភាយក្នុងប្រទេសអ៊ីតាលី និងរីករាលដាលក្នុងតំបន់អ៊ឺរ៉ុបតែក្នុងរយៈពេល២សតវត្សន៍តែប៉ុណ្ណោះ។

#### ក. កិច្ចព្រមព្រៀងដែលមានគោលការណ៍ការពារកម្មសិទ្ធិបញ្ញា

- អនុសញ្ញាទីក្រុងប៊ែនស្ដីពីកិច្ចការពារសិទ្ធិឧស្សាហកម្ម និងសិល្បៈឆ្នាំ ១៨៨៦
- អនុសញ្ញាទីក្រុងប៉ារីសស្ដីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មឆ្នាំ ១៨៨៣
- អនុសញ្ញាទីក្រុងរ៉ូមស្ដីពីកិច្ចការពារអ្នកសម្ដែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយឆ្នាំ ១៩៦១
- អនុសញ្ញាទីក្រុងម៉ាទ្រីតឆ្នាំ ១៨៩១ ស្ដីពីបទទប់ស្កាត់ការចង្អុលបង្ហាញបន្លំ ឬមិនពិតនៃប្រភេទទំនិញ

[2] Fisher, William Weston. "Patent". Encyclopedia Britannica, 27 May. 2019, https://www.britannica.com/topic/patent

- កិច្ចព្រមព្រៀងស្តីពីច្បាប់ប្រកាសនីយបត្រតក្កកម្មឆ្នាំ២០០៦

**ខ. កិច្ចព្រមព្រៀងទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងកម្មសិទ្ធិបញ្ញា**

- កិច្ចព្រមព្រៀង Budabest ស្តីពីការទទួលស្គាល់ជាអន្តរជាតិនៃការដាក់ពាក្យមីក្រូសរីរាង្គសម្រាប់នីតិវិធីចុះបញ្ជីប្រកាសនីយបត្រតក្កកម្មឆ្នាំ ១៩៧៧
- កិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពីការចុះបញ្ជីអន្តរជាតិនូវគំរូឧស្សាហកម្មឆ្នាំ ១៩២៥
- កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីតស្តីពីបញ្ជីម៉ាកជាអន្តរជាតិ និងពិធីសារនៃកិច្ចព្រមព្រៀងនេះឆ្នាំ១៨៩១
- កិច្ចព្រមព្រៀងទីក្រុងលីសបិនស្តីពីកិច្ចការពារ និងការចុះបញ្ជីជាអន្តរជាតិនៃការហៅឈ្មោះដើមឆ្នាំ១៩៥៨
- កិច្ចព្រមព្រៀងសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មឆ្នាំ១៩៧០។

**គ. កិច្ចព្រមព្រៀងស្តីពីចំណាត់ថ្នាក់អន្តរជាតិ**

- អនុសញ្ញាទីក្រុងឡូកាណូស្តីពីការបង្កើតចំណាត់ថ្នាក់អន្តរជាតិនៃគំរូឧស្សាហកម្មឆ្នាំ១៩៦៨
- អនុសញ្ញាទីក្រុងស្ត្រាសប៊ូស្តីពីចំណាត់ថ្នាក់អន្តរជាតិប្រកាសនីយបត្រតក្កកម្មឆ្នាំ ១៩៧១
- អនុសញ្ញាទីក្រុងនីសស្តីពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវាសម្រាប់ចុះបញ្ជីម៉ាកឆ្នាំ ១៩៥៧
- អនុសញ្ញាទីក្រុងវៀនស្តីពីចំណាត់ថ្នាក់អន្តរជាតិសម្រាប់ម៉ាកបង្កើតឡើងដោយរូបភាពឆ្នាំ ១៩៧៣។

### ១.១.២. ប្រភពតាមតំបន់

**ក. ប្រភពក្នុងក្របខណ្ឌសមាគមន៍អាស៊ាន**

ក្នុងក្របខណ្ឌអាស៊ាន មានកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាក្នុងសមាគមន៍អាស៊ានដើម្បីគ្រប់គ្រងរាល់សកម្មភាពនៃវិស័យកម្មសិទ្ធិបញ្ញា។ ម្យ៉ាងវិញទៀត ដើម្បីជាការធានាថាការអនុវត្តកិច្ចព្រមព្រៀងនេះប្រកបដោយប្រសិទ្ធិភាពនោះ រាល់សកម្មភាពទាំងឡាយគឺត្រូវគោរពលើគោលបំណងទាំងប្រាំដែលមានដូចជា៖

- កិច្ចការពារ និងការអនុវត្តកម្មសិទ្ធិបញ្ញា
- ការគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- ការបង្កើតច្បាប់ទាក់ទងកម្មសិទ្ធិបញ្ញា និងការផ្សព្វផ្សាយចំណេះដឹងអំពីកម្មសិទ្ធិបញ្ញាដល់សាធារណៈជន
- ការពង្រឹងធនធានមនុស្ស និងសហប្រតិបត្តិការជាមួយវិស័យឯកជន
- សំណើបង្កើតប្រព័ន្ធគ្រប់គ្រង ម៉ាក និងប្រកាសនីយបត្រតក្កកម្មរួមក្នុងក្របខណ្ឌអាស៊ាន

**ខ. សមាគមន៍អាស៊ាន និង WIPO ក្នុងវិស័យកម្មសិទ្ធិបញ្ញា**

នៅដើមទស្សវត្សន៍ទី៩០ គឺជាពន្លកនៃការចាប់ផ្តើមនូវទំនាក់ទំនងរបស់សមាគមន៍អាស៊ាននិងអង្គការកម្មសិទ្ធិបញ្ញាពិភពលោកក្នុងវិស័យកម្មសិទ្ធិបញ្ញា។ សមាគមន៍អាស៊ានបានធ្វើការស្នើសុំការបង្កើតឱ្យមាននូវកិច្ចព្រម

ព្រៀងសហប្រតិបត្តិការក្នុងវិស័យកម្មសិទ្ធិបញ្ញាសម្រាប់សមាគមន៍អាស៊ាន។ តាមរយៈការស្នើសុំនេះផងដែរអង្គការពាណិជ្ជកម្មពិភពលោកនិង សមាគមន៍អាស៊ានបានបង្កើតឱ្យមាននូវកិច្ចព្រមព្រៀងមួយស្តីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញានៅក្នុងឆ្នាំ១៩៩៣ និងបានដាក់អនុម័តនៅក្នុងឆ្នាំ ១៩៩៥។

ក្រោយពីកិច្ចព្រមព្រៀងនេះបានកកើតឡើង សមាគមន៍អាស៊ានបានបង្កើតឱ្យមាននូវកិច្ចប្រជុំមួយនៅទីក្រុងហាណូយនៅឆ្នាំ១៩៩៧ ដើម្បីកំណត់គោលដៅនិងដាក់ផែនការរហូតដល់ឆ្នាំ២០២០ ដើម្បីធានាការអនុវត្តទទួលបានជោគជ័យដោយមានភាពច្បាស់លាស់សម្រាប់ការពារកម្មសិទ្ធិបញ្ញានៅក្នុងក្របខណ្ឌអាស៊ាន គឺត្រូវគោរពតាមគោលការណ៍ដូចជាៈ

- កំណត់តំបន់នៃស្ថាប័នតាមរយៈទំនើបកម្មនៃការគ្រប់គ្រង
- ការបង្កើតច្បាប់ និងការគ្រប់គ្រងដោយស្វ័យប្រវត្តិ
- ការអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្តុះបណ្តាលផ្នែកគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- កិច្ចការពារ និងអនុវត្តសិទ្ធិ
- ការកសាងចំណេះដឹង ជាពិសេសទាក់ទងនឹងបញ្ហាវិវឌ្ឍន៍ថ្មីៗដូចជាចំណេះដឹងដែលមានលក្ខណៈប្រពៃណី ឬប្រភពដែលមានលក្ខណៈដូចគ្នា ភាពពេញនិយម ប្រព័ន្ធអ៊ីនធើណែត និង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។
- ការពិភាក្សាគោលនយោបាយស្តីពីវិស័យទាំងអស់នេះ ជាមួយនឹងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងលទ្ធកម្មនៃផលិតផលឱសថ។ល។

### ១.១.៣. ប្រភពជាតិ

#### ក. ប្រភពច្បាប់ជាតិ

- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូឧស្សាហកម្មបានអនុម័តនិងចូលជាធរមានអនុវត្តនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៣ មានគោលដៅការពារតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានប្រយោជន៍ដែលបានទទួលវិញ្ញាបនបត្រ និងការពារគំរូឧស្សាហកម្មដែលបានចុះបញ្ជីស្របច្បាប់នៅប្រទេសកម្ពុជា។
- ប្រកាសលេខ ៧០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ចេញដោយក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលដែលបានកំណត់អំពីនីតិវិធីក្នុងសុំចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសកម្ពុជា។

- ប្រកាសលេខ ១៨១ ស្តីពីកាពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្មស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្រប សម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មរបស់កម្ពុជាទាក់ទងទៅនឹងពាក្យស្នើសុំ ប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុនចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៦។
- ប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦។
- ប្រកាសលេខ ២៨២ ស្តីពីការកំណត់គោលការណ៍និងកំណត់នីតិវិធីនៃសុំការទទួលស្គាល់សុពលភាពនៃ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជាចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧។
- ប្រកាសលេខ ០៨០ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រក្កកម្មសាធារណៈរដ្ឋប្រជាមានិតចិននៅ កម្ពុជា ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៨។

**ខ. កិច្ចព្រមព្រៀងទ្វេភាគីទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា**

- កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការការពារពាណិជ្ជកម្មនិងកម្មសិទ្ធិបញ្ញាទៅវិញទៅមករវាងកម្ពុជា និង សហរដ្ឋអាមេរិកឆ្នាំ ១៩៩៦
- កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការការពារពាណិជ្ជកម្ម និងកម្មសិទ្ធិបញ្ញាទៅវិញទៅមករវាងកម្ពុជានិង ប្រទេសថៃឆ្នាំ ១៩៩៧
- កិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងប្រទេសចិនឆ្នាំ ២០១១

## ១.២. សញ្ញាណគតិយុត្តិនៃប្រកាសនីយបត្រតក្កកម្ម

### ១.២.១. ប្រវត្តិនៃការវិវត្តរបស់ប្រកាសនីយបត្រតក្កកម្ម

ប្រកាសនីយបត្រតក្កកម្មបានចាប់កំណើត និងមានការវិវត្តន៍អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ប៉ុន្តែគេ សង្កេតឃើញមានទ្រង់ទ្រាយច្បាស់លាស់ក្នុងការប្រគល់នូវប្រកាសនីយបត្រតក្កកម្មនៅក្នុងឆ្នាំ១៧៩០ ដោយមាន ចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិកដែលបានផ្តល់អំណាចដល់សភា Congress ឱ្យអនុម័តច្បាប់ស្តីពីការពារ ប្រកាសនីយបត្រតក្កកម្ម និងស្នាដៃតែងនិពន្ធ។ សព្វថ្ងៃនេះ ប្រព័ន្ធប្រកាសនីយបត្រតក្កកម្មត្រូវបានអភិវឌ្ឍន៍ឱ្យក្លាយ ទៅជាប្រព័ន្ធអន្តរជាតិមួយយ៉ាងទំនើបជឿនលឿន ដោយសារប្រកាសនីយបត្រតក្កកម្មនេះត្រូវបានការពារតាមរយៈ សន្ធិសញ្ញាប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនិងអនុសញ្ញាទីក្រុងប៉ារីស។

ចំណែកការចាប់កំណើតប្រកាសនីយបត្រតក្កកម្មនៅកម្ពុជាវិញគឺទើបតែមានការយកចិត្តទុកដាក់ អំពីបញ្ហា នេះនៅក្នុងអំឡុងពេលដែលប្រទេសកម្ពុជាត្រៀមចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកតែប៉ុណ្ណោះ ហើយ ជាសមិទ្ធផលព្រះរាជាណាចក្រកម្ពុជាបានបង្កើត «ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថ

ប្រយោជន៍ និងគំនូរឧស្សាហកម្ម» ដែលសភាបានអនុម័តនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៣ ហើយច្បាប់នេះផងដែរពាក់ព័ន្ធយ៉ាងជិតស្និតទៅនឹងអ្វីដែលគេហៅថា «កម្មសិទ្ធិបញ្ញាផ្នែកឧស្សាហកម្ម»។

### ១.២.២. និយមន័យ

ប្រកាសនីយបត្រតក្កកម្ម ជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារតក្កកម្ម។[3]

ប្រកាសនីយបត្រតក្កកម្ម គឺជាការផ្តល់ឱ្យនូវសិទ្ធិដែលចេញឱ្យដោយរដ្ឋាភិបាលនៃប្រជាជាតិមួយដល់អ្នកកាន់កាប់ប្រកាសនីយបត្រតក្កកម្មនោះដោយត្រូវធ្វើយ៉ាងណា ដើម្បីរារាំងកុំឱ្យអ្នកដទៃប្រើប្រាស់ឬលក់ផលិតផលដែលទទួលបានប្រកាសនីយបត្រតក្កកម្មនោះក្នុងដែនដីណាមួយជាក់លាក់ក្នុងរយៈពេលកំណត់ណាមួយ។[4]

ប្រកាសនីយបត្រតក្កកម្ម គឺវាអាស្រ័យទៅលើពាក្យសុំឫការិយាល័យប្រកាសនីយបត្រតក្កកម្មរបស់រដ្ឋាភិបាល។ ប្រកាសនីយបត្រតក្កកម្មគឺជាឯកសារដែលពណ៌នាអំពីតក្កកម្ម និងការបង្កើតថ្មីក្នុងស្ថានភាពស្របច្បាប់ដែលតក្កកម្មនោះអាចត្រូវបានគេធ្វើអាជីវកម្មដោយមានការអនុញ្ញាតពីម្ចាស់។ ម៉្យាងវិញទៀត ប្រកាសនីយបត្រតក្កកម្មការពារតក្កកម្ម និងផ្តល់សិទ្ធិដល់ម្ចាស់សិទ្ធិនូវសិទ្ធិផ្តាច់មុខដើម្បីប្រើប្រាស់នូវតក្កកម្មរបស់ខ្លួនក្នុងរយៈពេលកំណត់ហើយតក្កកម្មនោះអាចមានដំណោះស្រាយថ្មីលើបញ្ហាបច្ចេកទេស។[5]

**ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម មានគោលបំណង៖**[6]

- លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី ឫចំពោះការស្រាវជ្រាវ ឫការអភិវឌ្ឍន៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- ជម្រុញ និង លើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ឫការវិនិយោគក្នុងនិងក្រៅប្រទេស។
- លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិជ្ជាមកក្នុងប្រទេសកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សហកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។
- ផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើក៏ដូចជា ការប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់។

ជារួមគោលបំណងនៃប្រកាសនីយបត្រតក្កកម្ម ជាកាផ្តល់ទម្រង់ការពារបច្ចេកវិទ្យាថ្មីទំនើប។ តាមទ្រឹស្តីកិច្ចការពារប្រកាសនីយបត្រតក្កកម្ម គឺផ្តល់ការលើកទឹកចិត្តមិនមែនត្រឹមតែបង្កើតថ្មីនោះទេ ថែមទាំងការអភិវឌ្ឍន៍តក្កកម្មដែលជាចំណុចបច្ចេកទេស និងទីផ្សារជម្រុញបន្ថែមលើសកម្មភាពលើកទឹកចិត្តដល់ក្រុមហ៊ុនដើម្បីបន្តអភិវឌ្ឍបច្ចេកវិទ្យាថ្មីដល់ទីផ្សារនិងមានប្រយោជន៍ដល់សាធារណៈជន។ សរុបមកតាមរយៈប្រកាសនីយបត្រតក្កកម្មអាចធ្វើឲ្យ

[3] មាត្រា៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[4] សាស្ត្រាចារ្យ ទេព សុខ សៀវភៅនីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០២០-២០២១, ទំព័រ១៧

[5] សាស្ត្រាចារ្យអនុបណ្ឌិត លឹម យូសួ សៀវភៅសេចក្តីផ្តើមនីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០១៣, ទំព័រ៥១,៥២

[6] មាត្រា២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

មានការផ្លាស់ប្តូរបច្ចេកវិទ្យាល្អដើម្បីភាពរីកចម្រើន។

**តក្កកម្ម** គឺជាគំនិតរបស់តក្កករដែលអាចយកទៅអនុវត្តបាននៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា ឬអាចជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិត។[7] តាមន័យនេះ តក្កកម្មគឺត្រូវតែជាផលិតផលនៃគំនិតប្រាជ្ញាផ្ទាល់របស់តក្កករជាអ្នកបង្កើតវា។ គួរបញ្ជាក់ផងដែរថាតក្កកម្មដែលត្រូវការពារដោយ «ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ២០០៣» ដែលកំពុងអនុវត្តជាធរមាននៅព្រះរាជាណាចក្រកម្ពុជានេះ ត្រូវតែជាតក្កកម្មដែលអាចយកមកអនុវត្តបានក្នុងវិស័យឧស្សាហកម្ម[8] ឬតក្កកម្មដែលមិនពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មត្រូវការពារដោយច្បាប់ដោយឡែក។[9]

តក្កករ សំដៅលើអ្នកបង្កើតស្នាដៃ។[10] ប៉ុន្តែនៅក្នុងវិស័យកម្មសិទ្ធិបញ្ញា «គោលការណ៍ចុះបញ្ជីមុន» ត្រូវយកមកអនុវត្ត នោះមានន័យថាប្រសិនបើបុគ្គលណាមួយបានយកតក្កកម្មទៅចុះបញ្ជីបានមុន បុគ្គលនោះត្រូវទទួលបានសិទ្ធិជាម្ចាស់តក្កកម្មនៃតក្កកម្មដែលត្រូវបានចុះបញ្ជីនោះ។

ចំពោះករណីនេះ តើច្បាប់អាចធានាបានទេថាបុគ្គលដែលបានទៅចុះបញ្ជីមុនជាម្ចាស់តក្កកម្មពិតប្រាកដ? ប្រសិនបើបុគ្គលទុច្ចរិតបានលួចយកតក្កកម្មរបស់អ្នកបង្កើតស្នាដៃពិតប្រាដកទៅចុះបញ្ជី នោះមានន័យថាទុច្ចរិតជននឹងក្លាយជាម្ចាស់ស្នាដៃរីឯម្ចាស់ស្នាដៃពិតប្រាកដពុំមានសិទ្ធិក្នុងការធ្វើអាជីវកម្មលើស្នាដៃរបស់ខ្លួនបានឡើយ។

តើច្បាប់នៃប្រទេសកម្ពុជាមានដំណោះស្រាយលើបញ្ហានេះដែរ ឬទេ?

បទបញ្ញត្តិនៃច្បាប់ប្រកាសនីយបត្រតក្កកម្មកម្ពុជាពុំមានចែងដំណោះស្រាយលើបញ្ហានេះឡើយ។ លើសពីនេះក្នុងនីតិកម្ពុជាក៏ពុំទាន់មានយុត្តិសាស្ត្រជាដំណោះស្រាយណាមួយនៅឡើយ តែក្នុងករណីនេះយើងអាចសិក្សាពីច្បាប់បរទេសដើម្បីរកដំណោះស្រាយ៖

The First Inventor Concept: ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិកឆ្នាំ ១៧៩០ បានអនុវត្តគោលការណ៍ First to invent ដោយតម្រូវឲ្យម្ចាស់សិទ្ធិនៃប្រកាសនីយបត្រតក្កកម្មត្រូវតែជាតក្កករមុនគេ និងពិតប្រាកដ ( The First and True Inventor ) និយាយរួមគឺជា អ្នកទីមួយដែលបានបង្កើតស្នាដៃ និងរបស់ពួក Romano Germanic មានបារាំងអាឡឺម៉ង់ដែលតាមនោះ «គឺជាអ្នកទីមួយដែលបានចុះបញ្ជីស្នាដៃ (First to File)»។ ក្នុងន័យនៃទ្រឹស្តីទាំងពីរនេះ អ្នកដែលបានយកតក្កកម្មទៅចុះបញ្ជីសុំប្រកាសនីយបត្រតក្កកម្មមុនគេនឹងត្រូវបានសន្មតដូចជា

[7] មាត្រា៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[8] មាត្រា៥ និង ៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[9] មាត្រា៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[10] មាត្រា១០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

អ្នកបង្កើតតក្កកម្ម ឬជាតក្កករ)។ លើសពីនេះទៅទៀត ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់រួមគ្នាបង្កើតតក្កកម្មមួយ សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះត្រូវជាកម្មសិទ្ធិរួមគ្នានៃបុគ្គលទាំងឡាយនោះ។[11] ផ្ទុយទៅវិញ ប្រសិនបើមានបុគ្គលពីរនាក់ឬច្រើននាក់បានរកឃើញដាច់ដោយឡែកៗពីគ្នានូវតក្កកម្មមួយដូចគ្នា បុគ្គលណាបានដាក់សំណុំលិខិតស្នើសុំដែលមានកាលបរិច្ឆេទសុំចុះបញ្ជីមុនគេបង្អស់ ព្រមទាំងបានប្រកាសសុពលភាពនៃកាលបរិច្ឆេទមានអាទិភាពនោះត្រូវទទួលសិទ្ធិជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម ប្រសិនបើសំណុំលិខិតស្នើសុំនោះមិនត្រូវបានដកហូត ឬបោះបង់ចោល ឬក៏ត្រូវបដិសេធចោល[12]។ តក្កករជាបុគ្គលដែលផលិតស្នាដៃដូចជា និយោជិករបស់សហគ្រាស កម្មសិក្សាការីនៃសហគ្រាស ឬអាចជាមន្ត្រីនៅក្នុងជំនាញផលិតកម្មនៃស្ថាប័នរដ្ឋ។

**តក្កកម្មរបស់និយោជិក៖** តាមរយៈកិច្ចសន្យាការងារនិយោជិកទាំងឡាយ មានចំណងក្រោមបង្គាប់បញ្ជារបស់និយោជក។ មានន័យថានិយោជិក មានកាតព្វកិច្ចបំពេញការងារដែលនិយោជកបានប្រគល់ឲ្យស្របតាមកិច្ចសន្យានិងច្បាប់ការងារ។ ក្នុងករណីនេះ ជាគោលការណ៍តក្កកម្មដែលកើតចេញពីបេសកកម្ម ឬសេវាក្នុងក្របខណ្ឌនៃកិច្ចសន្យាការងារតក្កកម្មនោះជាកម្មសិទ្ធិរបស់និយោជក[13]។ ផ្អែកតាមបទប្បញ្ញត្តិខាងលើ យើងអាចទាញចេញជាគោលការណ៍នៃសច្ចធារណ៍តាមច្បាប់បានថារាល់តក្កកម្មទាំងអស់ត្រូវចាត់ទុកជាកម្មសិទ្ធិរបស់និយោជក ប្រសិនបើតក្កកម្មនោះត្រូវបានបង្កើតឡើង ក្នុងម៉ោងការងារ ក្នុងក្របខណ្ឌសកម្មភាពការងារ និងដោយការប្រើប្រាស់មធ្យោបាយរបស់សហគ្រាស។

**តក្កកម្មរបស់កម្មសិក្សាការី៖** ជាគោលការណ៍កម្មសិក្សាការីមិនស្ថិតនៅក្រោមរបបគតិយុត្តិដូចនិយោជិកនោះទេ។ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ នៃព្រះរាជាណាចក្រកម្ពុជាពុំបានកំណត់អំពីរបបគតិយុត្តិនៃកិច្ចសន្យាកម្មសិក្សានោះទេពោលគឺកំណត់តែអំពីលក្ខខណ្ឌនៃការបញ្ចប់កម្មសិក្សាតែប៉ុណ្ណោះ។[14] ក្នុងការអនុវត្តនៅកម្ពុជាក៏ពុំទាន់ឃើញដំណោះស្រាយនៅឡើយទេ។ ក្នុងករណីនេះ ប្រសិនបើច្បាប់អវត្តមានក្នុងការកំណត់បញ្ញត្តិពាក់ព័ន្ធ វាជាសេរីភាពរបស់គូភាគីដែលត្រូវកំណត់លក្ខខណ្ឌជាក់លាក់នៅក្នុងកិច្ចសន្យារវាងអ្នកដឹកនាំកម្មសិក្សា និងកម្មសិក្សាការី។

**តក្កកម្មរបស់មន្ត្រី៖** ក្នុងក្របខណ្ឌគតិយុត្តិនៃកម្ពុជាពុំមានបទបញ្ញត្តិណាមួយកំណត់អំពីម្ចាស់កម្មសិទ្ធិលើតក្កកម្មដែលត្រូវបានបង្កើតឡើងដោយមន្ត្រីសាធារណៈដែលមានជំនាញ និងគ្រប់គ្រងបច្ចេកវិទ្យាណាមួយនោះទេ។ ប៉ុន្តែនីតិរបស់ប្រទេសបារាំង គឺបានបញ្ញត្តិអំពីភាពជាម្ចាស់កម្មសិទ្ធិលើតក្កកម្មដែលត្រូវបានបង្កើតឡើងដោយមន្ត្រី

---

[11] មាត្រា១១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[12] មាត្រា១២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[13] មាត្រា១៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[14] មាត្រា៨២(១) នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ «កម្មសិក្សាការីមិនចាំបាច់ជូនដំណឹងជាមុនដល់និយោជកក្នុងករណីបញ្ចប់កម្មសិក្សាឡើយ»

សាធារណៈ។ តក្កកម្មដែលត្រូវបានបង្កើតឡើងដោយមន្ត្រីសាធារណៈក្នុងក្របខណ្ឌការងាររបស់គាត់ត្រូវអនុវត្តរបប គតិយុត្តិដូចគ្នានឹងនិយោជិក[15] មានន័យថា វាគឺជាកម្មសិទ្ធិរបស់រដ្ឋ(ស្ថាប័ន)។

### ១.២.៣. អត្ថប្រយោជន៍ដែលទទួលបានការការពារដោយច្បាប់

គំនិតច្នៃប្រឌិត និងការបង្កើតថ្មីគឺជាបេះដូងដែលនាំឱ្យអាជីវកម្មឆ្ពោះទៅរកភាពជោគជ័យ។ ចំណែកឯគំនិត តែឯកឯង ទោះបីជាយ៉ាងណាក្តីក៏នៅតែមានតម្លៃជាលទ្ធផលតិចតួចប៉ុណ្ណោះ។ គំនិតទាំងនោះចាំបាច់ត្រូវធ្វើការ អភិវឌ្ឍន៍ដោយធ្វើការប្រែក្លាយវាទៅជាផលិតផលឬសេវាកម្មប្រកបដោយការច្នៃប្រឌិតថ្មី ហើយធ្វើពាណិជ្ជកម្មទំនិញ ឬសេវាកម្មទាំងនោះប្រកបដោយជោគជ័យ ដើម្បីធ្វើឱ្យអាជីវកម្មរបស់លោកអ្នកអាចច្បាមយកបាននូវផលប្រយោជន៍ ពីគំនិតច្នៃប្រឌិត និងការបង្កើតថ្មីរបស់លោកអ្នក។ កម្មសិទ្ធិបញ្ញា ជាពិសេសប្រកាសនីយបត្រតក្កកម្មអាចជាកត្តា សំខាន់បំផុតក្នុងការធ្វើឱ្យគំនិតនៃការច្នៃប្រឌិត និងការបង្កើតថ្មីក្លាយទៅជាផលិតផលប្រកបដោយការប្រកួតប្រជែង ដែលបង្កើនប្រាក់ចំណេញបានយ៉ាងច្រើន។

ម៉្យាងទៀតអាជីវកម្មរបស់លោកអ្នកក៏អាចប្រើប្រាស់នូវប្រកាសនីយបត្រតក្កកម្ម ដើម្បីទទួលបានចំណូល ជាលាភសក្ការៈ តាមរយៈការផ្តល់អាជ្ញាប័ណ្ណប្រកាសនីយបត្រតក្កកម្មប្រកបដោយការច្នៃប្រឌិតទៅឱ្យសហគ្រាដទៃ ដែលមានសមត្ថភាពក្នុងការធ្វើពាណិជ្ជកម្មនូវគំនិតច្នៃប្រឌិតទាំងនោះ។ ទីផ្សារផលិតផលទើបណែនាំថ្មីរបស់លោក អ្នកត្រូវបានការពារប្រកបដោយប្រសិទ្ធិភាព តាមរយៈការទទួលបាននូវការការពារប្រកាសនីយបត្រតក្កកម្ម។

ក្នុងនាមជាម្ចាស់ប្រកាសនីយបត្រតក្កកម្មមួយរូប លោកអ្នកអាចបើកផ្លូវផ្សេងទៀតដូចជា ការធ្វើអាជ្ញាប័ណ្ណ ឬការចងសម្ព័ន្ធជាយុទ្ធសាស្ត្រជាដើម។ ហើយក៏នៅមានអត្ថប្រយោជន៍ជាច្រើនផ្សេងទៀតដែលម្ចាស់តក្កកម្មអាច ទទួលបានពីការស្នើសុំប្រកាសនីយបត្រតក្កកម្មនេះពីរដ្ឋដូចជា៖

#### ១.២.៣.១. ជម្រុញការបង្កើតថ្មី និងអភិវឌ្ឍន៍បច្ចេកវិទ្យា

ប្រកាសនីយបត្រតក្កកម្ម ត្រូវបានចាត់ទុកដូចជាការធានារបស់រដ្ឋដើម្បីប្រឆាំងទល់នឹងអំពើនៃការក្លែងបន្លំ ទាំងឡាយចំពោះតក្កកម្មដែលជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មឲ្យដល់តក្កករ។ តាមរយៈវត្តមានរបស់ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម នោះអំពើនៃការក្លែងបន្លំតក្កកម្មនឹងត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពី«ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម» នេះជាមិនខានឡើយ។ ប្រកាសនីយបត្រតក្កកម្មនេះ ជម្រុញការលើកទឹកចិត្តដល់ការលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់សហគ្រាស ពីព្រោះតែវិញ្ញាបនបត្រគតិយុត្តិ ប្រភេទនេះនឹងត្រូវបានចាត់ទុកថាជាធាតុផ្សំមួយនៃទ្រព្យសកម្មរបស់សហគ្រាស ហើយក៏ជាប្រភពនៃការទាក់ទាញ

[15] មាត្រា L611-14 alinee1 នៃក្រមកម្មសិទ្ធិបញ្ញាបារាំង

អ្នកបណ្តាក់ទុនដើម្បីបង្កើតនូវមូលនិធិវិនិយោគរបស់សហគ្រាសផងដែរ។ មូលហេតុធំៗបួនយ៉ាងដែលគាំទ្រដល់សារៈប្រយោជន៍ខាងសេដ្ឋកិច្ចរបស់សហគ្រាសជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មមាន៖

- ទី១ ពត៌មានស្តីពីតក្កកម្ម ដែលបានរៀបរាប់នៅក្នុងប្រកាសនីយបត្រតក្កកម្មនឹងជួយសម្រួលដល់ការផ្ទេរបច្ចេកវិជ្ជានិងដល់ការវិនិយោគរបស់សហគ្រាស។
- ទី២ ប្រកាសនីយបត្រតក្កកម្មនឹងជួយលើកទឹកចិត្តដល់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាបន្តបន្ទាប់ទៀតរបស់សហគ្រាស។
- ទី៣ ប្រកាសនីយបត្រតក្កកម្មនឹងជួយពន្លឿនដល់ការបង្កើតបច្ចេកវិជ្ជាថ្មីៗក៏ដូចជាការបង្កើតមុខជំនួញថ្មីៗដល់សហគ្រាស។
- ទី៤ ប្រកាសនីយបត្រតក្កកម្មគឺជាកូនសោរដល់សំខាន់បំផុតក្នុងការសហការគ្នាក្នុងវិស័យជំនួញ (ដូចជាការរួមផ្សំបញ្ចូលបច្ចេកវិជ្ជាគ្នា) ដើម្បីអភិវឌ្ឍន៍សហគ្រាសរៀងៗខ្លួននិងអាចជាប្រភពចំណូលបន្ថែមរបស់សហគ្រាសតាមរយៈការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មលើតក្កកម្មនោះផងដែ។

ប្រកាសនីយបត្រតក្កកម្ម ក៏អាចត្រូវបានចាត់ទុកដូចជាយុទ្ធសាស្ត្រមួយដ៏ល្អប្រសើរបំផុតក្នុងការផ្សព្វផ្សាយកេរ្តិ៍ឈ្មោះ និងពង្រឹងនីត្យានុភាពរបស់សហគ្រាសដែលជាម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្មទៅដល់បណ្តាសាធារណជនក៏ដូចជាអតិថិជននិងដៃគូប្រកួតប្រជែងរបស់សហគ្រាសនោះផងដែរ។ ស្ថិតនៅក្នុងភាពជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះ សហគ្រាសទាំងឡាយរមែងមានឥទ្ធិពលខ្ពស់ជាងគេនៅក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងដៃគូនានារបស់ខ្លួនជានិច្ច។

### ១.២.៣.២.សិទ្ធិផ្តាច់មុខនិងឧត្តមភាពទីផ្សារ

ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានចាត់ទុកថាជាកម្មសិទ្ធិផ្តាច់មុខដោយសារតែម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះមានការគ្រប់គ្រងពេញលេញទៅលើ ការផលិត ការលក់ និងការប្រើប្រាស់គំនិតច្នៃប្រឌិតនោះ។ ប្រកាសនីយបត្រតក្កកម្មអនុញ្ញាតឱ្យម្ចាស់វាទាញយកផលប្រយោជន៍ជាសម្ភារៈដែលជារង្វាន់សម្រាប់កិច្ចការ និងការប្រឹងប្រែងខាងបញ្ញាញាណរបស់ខ្លួន។ តក្កកម្មនេះអាចនឹងត្រូវបានយកទៅធ្វើអាជីវកម្មបាន លុះត្រាណាតែមានការអនុញ្ញាតពីម្ចាស់របស់ប្រកាសនីយបត្រតក្កកម្មនោះជាមុនសិន។ ហេតុផលសម្រាប់ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មលើតក្កកម្មរបស់លោកអ្នកវានឹងនាំឲ្យតក្កករមានឋានៈជា៖

- សិទ្ធិផ្តាច់មុខ៖ ប្រកាសនីយបត្រតក្កកម្មផ្តល់នូវសិទ្ធិផ្តាច់មុខដែលជាធម្មតាអាចអនុញ្ញាតឱ្យអាជីវកម្មរបស់លោកអ្នកប្រើប្រាស់ និងធ្វើអាជីវកម្មលើតក្កកម្មនោះរយៈពេល២០ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទនៃការដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម។

- ផ្តល់នូវទីតាំងដ៏រឹងមាំលើទីផ្សារៈ តាមរយៈសិទ្ធិផ្តាច់មុខទាំងនេះ លោកអ្នកដែលបានចុះបញ្ជីរួចហើយអាចកាត់បន្ថយបាននូវការប្រកួតប្រជែង ហើយបង្កើតឡើងនូវទីតាំងរឹងមាំប្រកបដោយឧត្តមភាពសម្រាប់ទីផ្សារដោយលោកអ្នកមានតួនាទីលេចធ្លោមុនគេ។
- ផ្តល់ផលចំណូលត្រឡប់មកវិញខ្ពស់ចំពោះការវិនិយោគៈ ដោយបានបោះទុនវិនិយោគជាប្រាក់ និងពេលវេលាមួយចំនួនធំក្នុងការខិតខំបង្កើតផលិតផលប្រកបដោយគំនិតច្នៃប្រឌិត អាជីវកម្មរបស់លោកអ្នកអាចធ្វើពាណិជ្ជកម្មលើគំនិតច្នៃប្រឌិតនោះក្រោមផ្លាកសញ្ញាផ្តាច់មុខទាំងនេះ ហើយអាចឱ្យអាជីវកម្មរបស់លោកអ្នកទទួលបាននូវផលចំណូលខ្ពស់ជាងមុនអំពីការធ្វើវិនិយោគនេះ។
- ឱកាសក្នុងការផ្តល់អាជ្ញាប័ណ្ណឬលក់តក្កកម្មនោះវិញបាន ប្រសិនបើអស់លោកអ្នកសម្រេចមិនធ្វើអាជីវកម្មប្រកាសនីយបត្រតក្កកម្មដោយខ្លួនឯងទេលោកអ្នកអាចលក់ ឬផ្តល់អាជ្ញាប័ណ្ណចំពោះសិទ្ធិនៃការប្រើប្រាស់វាដើម្បីឲ្យក្រុមហ៊ុនដទៃធ្វើពាណិជ្ជកម្មតក្កកម្មនេះ ហើយវាក៏ជាប្រភពមួយនៃប្រាក់ចំណូលសម្រាប់អាជីវកម្មរបស់លោកអ្នកដែរ។
- បង្កើតថាមពលក្នុងការចចារៈ ប្រសិនបើអាវជីវកម្មរបស់លោកអ្នកស្ថិតក្នុងដំណាក់កាលនៃការទទួលបាននូវសិទ្ធិដើម្បីប្រើប្រាស់ប្រកាសនីយបត្រតក្កកម្មរបស់សហគ្រាសដទៃមួយទៀត តាមរយៈកិច្ចសន្យាអាជ្ញាប័ណ្ណ នោះរូបភាពនៃប្រកាសនីយបត្រតក្កកម្មរបស់លោកអ្នកនឹងជួយលើកកម្ពស់ថាមពលសម្រាប់ការតថ្លៃរបស់លោកអ្នកជាមួយសហគ្រាសនោះ។ មានន័យថាប្រកាសនីយបត្រតក្កកម្មរបស់លោកអ្នកជាចំណុចចាប់អារម្មណ៍របស់សហគ្រាសមួយផ្សេងទៀតដែលកំពុងចចារជាមួយ ហើយលោកអ្នកនឹងឈានទៅក្នុងការរៀបចំចាត់ចែងឱ្យមានការផ្តល់នូវអាជ្ញាប័ណ្ណទៅវិញទៅមក រវាងសហគ្រាសរបស់លោកអ្នកជាមួយនឹងសហគ្រាសរបស់អ្នកដទៃ។
- រូបភាពវិជ្ជមានរបស់សហគ្រាសរបស់លោកអ្នកៈ ដៃគូអាជីវកម្ម ឬអ្នកបណ្តាក់ទុនវិនិយោគ និងម្ចាស់ភាគហ៊ុនអាចយល់ឃើញថា រូបភាពប្រកាសនីយបត្រតក្កកម្មគឺជាការបង្ហាញនូវកម្រិតខ្ពស់នៃជំនាញឯកទេស និងសមត្ថភាពខាងបច្ចេកវិទ្យាដែលមាននៅក្នុងក្រុមហ៊ុនរបស់លោកអ្នក។ ប្រការនេះបានបង្ហាញនូវភាពមានប្រយោជន៍សម្រាប់ការអំពាវនាវមូលនិធិ ឬការស្វែងរកដៃគូអាជីវកម្ម និងការបង្កើតតម្លៃទីផ្សារក្រុមហ៊ុនរបស់លោកអ្នក។
- ជាពិសេសម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម(តក្កករ) មានសិទ្ធិក្នុងការហាមឃាត់តតិយជនមិនឱ្យផលិត ប្រើប្រាស់ ដាក់លក់ ធ្វើសំណើរដាក់លក់ ឬនាំចូលផលិតផលដោយពុំមានការអនុញ្ញាតពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម។

# ជំពូកទី២
# ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិនិងច្បាប់អន្តរជាតិ

## ២.១. នីតិវិធីនៃការចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ

### ២.១.១. លក្ខខណ្ឌគ្រឹះនៃការចុះបញ្ជី

តក្កកម្មមួយអាចនឹងទទួលបាននូវប្រកាសនីយបត្រតក្កកម្ម ប្រសិនបើស្នាដៃបង្កើតនេះឆ្លើយតបបានទៅនឹងលក្ខណៈសម្បត្តិបីយ៉ាងដូចជា

#### ២.១.១.១. ភាពថ្មីនៃស្នាដៃ

«ថ្មី» គឺជាលក្ខណៈដំបូងបំផុតសម្រាប់ទទួលបានប្រកាសនីយបត្រតក្កកម្មដែលតម្រូវឱ្យតក្កកម្មចាំបាច់ត្រូវតែថ្មី។ តក្កកម្មដែលបានចាត់ទុកថាថ្មី ប្រសិនបើវាពុំទាន់ត្រូវបានរកឃើញដោយស្នាដៃសិប្បកម្មណាមួយពីមុនមក។ ស្នាដៃសិប្បកម្មពីមុនមកមានន័យថា ជាចំណេះដឹងដែលបាននិងស្គាល់រួចមកហើយដោយសាធារណៈជនតាមរយៈការផ្សព្វផ្សាយ ឬតាមរយៈការប្រើប្រាស់ ឬតាមវិធីផ្សេងៗទៀតមុនពេលដាក់ពាក្យសុំចុះបញ្ជី (ឬមុនកាលបរិច្ឆេទអាទិភាព) តក្កកម្មនោះ។ ស្នាដៃសិប្បកម្មពីមុនមកដែលមាន តាមរយៈការបោះផ្សាយជារូបភាពរូបិយ ដែលពាំនាំនូវព័ត៌មានដូចជាតាមរយៈ ការសរសេរ ការគូរ ហ្វីល ខ្សែរអាត់ ឬប្រព័ន្ធអ៊ីនធើណេត។ ការបើកចំហរតាមរយៈការប្រើប្រាស់ គឺជាការបើកចំហរជាសាធារណៈ និងជាការបើកចំហរដែលអាចមើលឃើញ ឧទាហរណ៍ៈ ការដាក់តាំងបង្ហាញ ការលក់ ការបង្ហាញជាសាធារណៈ ការផ្សាយតាមទូរទស្សន៍ និងការប្រើជាក់ស្តែងតាមសាធារណៈ។

#### ២.១.១.២.មានជំហានច្នៃប្រឌិត

តក្កកម្ម គឺត្រូវតែមានជំហានច្នៃប្រឌិត។ តក្កកម្មមួយត្រូវបានគេចាត់ទុកថាពាក់ព័ន្ធនឹងជំហានច្នៃប្រឌិត ប្រសិនបើស្នាដៃនោះពិតប្រាកដច្បាស់ពេកចំពោះបុគ្គលណាម្នាក់ដែលមានជំនាញសាមញ្ញធម្មតា។ ប្រសិនបើបុគ្គលម្នាក់ដែលមានជំនាញសាមញ្ញធម្មតាអាចយល់បាននូវជំហានទាំងនេះបាន តក្កកម្មនោះគឺវាប្រាកដច្បាស់ងាយពេក ហើយមិនអាចទទួលបាននូវប្រកាសនីយបត្រតក្កកម្មបានទេ។ ក្នុងច្បាប់កម្ពុជា ជំហានរកឃើញថ្មីត្រូវបានកំណត់ដូចះ «តក្កកម្ម» មួយត្រូវបានចាត់ទុកថាមានជំហានរកឃើញថ្មី នៅពេលដែលតក្កកម្មនោះមិនអាចឲ្យបុគ្គលណាដែលមានកម្រិតធម្មតាក្នុងជំនាញយល់ដឹងបាន។[16] មានន័យថាបើគ្រាន់តែមើលនឹងភ្នែកអ្នកជំនាញធម្មតាមិនអាចយល់បានថាជាតក្កកម្មអ្វី ឬយន្តការនៃការផលិតរបស់វាត្រូវបានផលិតយ៉ាងដូចម្តេចបានឡើយ លុះត្រាតែមានការពន្យល់ពីតក្កករ។

[16] មាត្រា៧ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

### ២.១.១.៣.តក្កកម្មដែលអាចអនុវត្តបាននៅក្នុងឧស្សាហកម្ម

តក្កកម្ម មួយដែលអាចចាត់ទុកថាអាចអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម ប្រសិនបើតក្កកម្មនោះអាចត្រូវបានធ្វើ ឬប្រើប្រាស់សម្រាប់វិស័យឧស្សាហកម្មណាមួយ។ តក្កកម្មនេះត្រូវតែមានលក្ខណៈអាចអនុវត្តបានដោយមិនមែនគ្រាន់តែជាទ្រឹស្តីទេ។ ប្រសិនបើតក្កកម្មនោះជាផលិតផល វាត្រូវមានលទ្ធភាពអាចផលិតរបស់នោះបាន។ បើជាដំណើរការផលិតកម្មវាត្រូវតែមានលទ្ធភាពអនុវត្តផលិតកម្មនោះបាន។

ឧទាហរណ៍ទី១៖ គំនូរនៃតក្កកម្មរបស់សិស្សថ្នាក់បឋមសិក្សាដែលទទួលបានពានរង្វាន់ពីរដ្ឋមន្ត្រីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសជប៉ុន។ គំនូរនេះបង្ហាញអំពីឧបករណ៍នៅពេលអនាគតសម្រាប់សំអាតទឹកសមុទ្រដែលមានគោលដៅការពារបរិស្ថាន។

ឧទាហរណ៍ទី២៖ គំនូរនៃតក្កកម្មមួយរបស់សិស្សម្នាក់ថ្នាក់ទី៨ នៃប្រទេសជប៉ុនដែលទទួលបានពានរង្វាន់ច្នៃប្រឌិតថ្មី ជាឧបរកណ៍ស្រូបសំលេងដែលបំពុលបរិស្ថាននិងបម្លែងសំលេងទៅជាថាមពលអគ្គិសនីដើម្បីចែកចាយក្នុងទីក្រុង។

ដូចនេះហើយពុំមែនគ្រប់ តក្កកម្ម ទាំងអស់សុទ្ធតែអាចត្រូវការពារដោយប្រកាសនីយបត្រតក្កកម្មនោះឡើយ ពោលក៏មានតក្កកម្មមួយចំនួនផងដែរ ដែលច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនេះ បានបដិសេធក្នុងការផ្តល់វិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មដើម្បីការពារដល់តក្កកម្មនោះ។ យោងតាមបញ្ញត្តិច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម គេអាចរាប់បាននូវតក្កកម្មដែលពុំមានសំណាងទទួលបានការការពារពីប្រកាសនីយបត្រតក្កកម្មរួមមាន៖[17]

- ការរកឃើញទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា។
- គម្រោងការ ក្បួន ឬវិធីសាស្ត្រសម្រាប់ធ្វើជំនួញ សម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់លេងល្បែងកំសាន្ត។
- វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្ស ឬជាសត្វដោយការវះកាត់ ឬដោយការព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគដែលបានអនុវត្តចំពោះផលិតផលទាំងឡាយណា ដែលអាចយកមកប្រើប្រាស់ក្នុងវិធីសាស្ត្រខាងលើ។
- ផលិតផលឱសថដូចមានចែកក្នុងមាត្រា ១៣៦នៃច្បាប់នេះ។
- រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសរីរាង្គនិងដំណើរការកកើតតាមលក្ខណៈជីវសាស្ត្រសំខាន់ៗសម្រាប់ផលិតកម្មរុក្ខជាតិ ឬសត្វ។
- ប្រភេទផ្សេងៗនៃពូជរុក្ខជាតិណាមួយ។

[17] មាត្រា៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

តក្កកម្មណាដែលការធ្វើអាជីវកម្ម ឫពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់វាផ្ទុយទៅនឹងសណ្ដាប់ធ្នាប់សាធារណៈ ឫសីលធម៌ ឫមិនការពារជីវិត ឫសុខភាពរបស់មនុស្ស សត្វ ឫរុក្ខជាតិ ឫធ្វើឲ្យខូចខាតបរិស្ថានធ្ងន់ធ្ងរនោះនឹងត្រូវច្បាប់ហាមឃាត់និងមិនត្រូវផ្ដល់ប្រកាសនីយបត្រតក្កកម្មឲ្យនោះទេ។[18]

**២.១.២. លក្ខខណ្ឌនម្រង់ចុះបញ្ជី**

នីតិវិធីនៃការសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មមានដូចខាងក្រោមៈ

**២.១.២.១. ការដាក់ពាក្យសុំ**

តក្កកម្ម ត្រូវតែចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីទទួលបាននូវកិច្ចការពារស្របច្បាប់ក៏ដូចជាទទួលបាននូវសិទ្ធិផ្ដាច់មុខលើតក្កកម្មនោះ។ ការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មត្រូវធ្វើឡើងដោយម្ចាស់តក្កកម្ម ឫអ្នកតំណាងដោយស្របច្បាប់របស់ម្ចាស់តក្កកម្មដោយបំពេញតាមទម្រង់ដែលកំណត់ដោយច្បាប់និងបញ្ញត្តិពាក់ព័ន្ធរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ អាទិភាពនៃការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មនេះ ត្រូវបានផ្ដល់ឲ្យអ្នកដែលបានសុំចុះបញ្ជីជាផ្លូវការមុនគេ ឫអ្នកដែលបានអះអាងថាមានអាទិភាពនោះ។

**ក. សមត្ថកិច្ចទទួលបន្ទុកពាក្យសុំ**

រាល់ការស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវធ្វើនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។[19] ពាក្យស្នើសុំចុះបញ្ជីនេះត្រូវដាក់ជូនទៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃអគ្គនាយកដ្ឋានឧស្សាហកម្មរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ នាយកដ្ឋាននេះត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន១រូបដែលមានតួនាទីតាមច្បាប់នេះគឺជាមន្ត្រីកាន់កាប់បញ្ជីសម្រាប់រាល់ការស្នើសុំប្រកាសនីយបត្រតក្កកម្មទាំងអស់។[20]

ចំពោះការស្នើសុំអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម (តក្កករ) ត្រូវដាក់ឈ្មោះរបស់ខ្លួនគាត់ផ្ទាល់លើកលែងតែមានការប្រកាសជាលាយលក្ខណ៍អក្សរជាពិសេសណាមួយ ហើយផ្ញើរទៅមន្ត្រីកាន់កាប់បញ្ជីដោយបញ្ជាក់ថាគាត់ពុំមានបំណងនឹងបញ្ចេញឈ្មោះទេ។ ការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មគឺជាការដាក់សំណុំបែបបទដែលត្រូវបង់កម្រៃជាមុន ហើយដែលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវការពិនិត្យជាចាំបាច់។

**ខ. សំណុំឯកសារចាំបាច់សម្រាប់ដាក់ពាក្យសុំ**

[18] មាត្រា៩ នៃច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[19] មាត្រា១៦ នៃច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[20] ប្រការ២ នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រកចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្ដីអំពីនីតិវិធីផ្ដល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

សំណុំលិខិតចាំបាច់បំផុតដែលតម្រូវសម្រាប់ការស្នើសុំប្រកាសនីយបត្រតក្កកម្មមួយរួមមាន[21]៖ ពាក្យសុំ សេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង គំនូសបង្ហាញ និងខ្លឹមសារសង្ខេបនៃតក្កកម្មនោះជាដើម។ ការដាក់សំណុំលិខិតស្នើសុំចុះប្រកាសនីយបត្រតក្កកម្មគឺជាការដាក់សំណុំលិខិតបែបបទដែលត្រូវបង់កម្រៃជាមុន ហើយសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវការពិនិត្យជាចាំបាច់ចំពោះទម្រង់ និងខ្លឹមសារសង្ខេបពីតក្កកម្មនោះ។ ក្រោយពីការសំណុំលិខិតស្នើសុំជាលើកដំបូងនេះ តក្កករមានរយៈពេលរហូតដល់១២ខែដើម្បីជ្រើសរើសយកប្រទេសណាមួយដែលគាត់ចង់បានទទួលការការពារក្នុងប្រទេសទាំងនោះ។ លើសពីនេះទៅទៀត រាល់ការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវតែគោរពឱ្យបាននូវ «វិធានឯកភាពនៃតក្កកម្ម»។ វិធានឯកភាពនៃតក្កកម្មសំដៅដល់ការហាមឃាត់ចំពោះលទ្ធភាពផ្តល់ដល់តក្កកម្មច្រើននូវប្រកាសនីយបត្រតក្កកម្មតែមួយ។[22]

**គ. ប្រកាសនីយបត្រតក្កកម្មជាតិ**

សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិមានន័យថា ជាតក្កកម្មទាំងឡាយណាដែលបានរកឃើញនៅក្នុងប្រទេសស្នើសុំប្រកាសនីយបត្រតក្កកម្ម។ ការស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិដែលបែបបទក្នុងការស្នើសុំចុះបញ្ជីត្រូវអនុលោមតាមច្បាប់ជាកំណត់។ ជាធម្មតានៅពេលដែលរកឃើញតក្កកម្មណាមួយចាំបាច់ត្រូវស្នើសុំការការពារដោយបែបបទនៃការស្នើសុំនេះមានដូចតទៅ៖

**ឃ. ពាក្យសុំ**

អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ក្នុងពាក្យសុំឱ្យបានច្បាស់លាស់ពីអ្វីដែលអាចឈានទៅដល់ការផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មបានរួមទាំងទិន្នន័យដែលពាក់ព័ន្ធទៅនឹងតក្កករ និងភ្ជាប់មកជាមួយផងដែរនូវចំណងជើងរបស់តក្កកម្ម។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនមែនជាតក្កករ អ្នកដាក់ពាក្យសុំត្រូវបន្ថែមនូវឯកសារបញ្ជាក់ពីការផ្ទេរសិទ្ធិភ្ជាប់មកជាមួយផង។ ពាក្យសុំត្រូវបង្ហាញពីពត៌មានដែលទាក់ទងទៅនឹងឈ្មោះ អាស័យដ្ឋាន សញ្ជាតិ និងលំនៅឋានរបស់អ្នកដាក់ពាក្យសុំ។ ប្រសិនបើអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មនេះ ត្រូវធ្វើឡើងតាមរយៈអ្នកតំណាងរបស់តក្កករនោះអត្តសញ្ញាណរបស់អ្នកតំណាងស្របច្បាប់ក៏ត្រូវដាក់ក្នុងពាក្យសុំផងដែរ។ ករណីដែលតក្កករ មិនមានលំនៅឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ក្នុងប្រទេសកម្ពុជាទេការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មត្រូវធ្វើឡើង តាមរយៈអ្នកតំណាងដោយស្របច្បាប់ជាភ្នាក់ងារដែលគាត់ត្រូវតែមានលំនៅឋានពិតប្រាកដ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា[23]និង ដែលមិនបានបំពេញលក្ខខណ្ឌទាំងឡាយដែល

[21] ប្រការ១៦ នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[22] មាត្រា២៣ នៃច្បាប់ស្តីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[23] មាត្រា១១៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

បានកំណត់ដោយបញ្ញត្តិដោយឡែករបស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល។[24]

-សេចក្តីអធិប្បាយៈ សេចក្តីអធិប្បាយនៃតក្កកម្ម មានគោលដៅបញ្ជាក់អំពីពត៌មានទាក់ទងនឹងបច្ចេកទេស ឫដំណើរការនៃការផលិតដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតតក្កកម្មនោះ។ អត្ថន័យនៃសេចក្តីអធិប្បាយនៃតក្កកម្ម នេះត្រូវបានកំណត់ដោយប្រកាសរបស់ស្ថាប័នរដ្ឋ។[25] ក្នុងសេចក្តីអធិប្បាយនេះត្រូវបញ្ជាក់អំពីឈ្មោះ ឫចំណងជើង នៃតក្កកម្ម និងបញ្ជាក់អំពីលក្ខណៈបច្ចេកទេសដែលពាក់ព័ន្ធនឹងស្នាដៃក្នុងលក្ខខណ្ឌណាមួយដែលអាចយល់បាន ដោយមន្ត្រីចុះបញ្ជី។ សេចក្តីអធិប្បាយត្រូវពណ៌នាអំពីផលប្រយោជន៍នៃតក្កកម្មដែលអាចយកទៅផលិត និងប្រើប្រាស់បានក្នុងវិស័យឧស្សាហកម្មណាមួយជាក់លាក់។

- សេចក្តីអះអាងៈ កម្មវត្ថុនៃសេចក្តីអះអាងមានគោលដៅបញ្ជាក់នូវលក្ខណៈបច្ចេកទេសសុទ្ធសាធរបស់តក្កកម្មដើម្បីបញ្ជាក់ថាតក្កកម្មដែលត្រូវបានដាក់ពាក្យសុំនេះមិនស្ថិតនៅក្នុងវិស័យណាមួយ ដែលត្រូវបានការពារដោយប្រកាសនីយបត្រតក្កកម្មរួចហើយ ឫក៏វិស័យសាធារណៈ ឫដែលបម្រុងទុកការពារឲ្យតក្កកម្មដែលនៅមានសុពលភាពនៅឡើយដោយសេចក្តីអះអាងនេះត្រូវមានលក្ខណៈច្បាស់លាស់និងសមស្រប។[26]

- ខ្លឹមសារសង្ខេបនៃតក្កកម្មៈ ខ្លឹមសារសង្ខេប គឺជាអត្ថន័យសង្ខេបនៃលក្ខណៈបច្ចេកទេសរបស់តក្កកម្មដែលជាកម្មវត្ថុនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មសម្រាប់តម្កល់ជាឯកសារ។ ខ្លឹមសារសង្ខេបត្រូវធ្វើឡើងដោយខ្លី ងាយយល់ និងភ្ជាប់ជាមួយដោយគំរូពន្យល់អំពីតក្កកម្មដែលត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីនោះ។[27]

### ង. ប្រកាសនីយបត្រតក្កកម្មបរទេស

ទាក់ទងនឹងសំណុំលិខិតពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មមានន័យថា តក្កកម្មដែលបានរកឃើញនោះ មិនមែនមានតែនៅក្នុងប្រទេសដែលបានស្នើសុំចុះបញ្ជីនោះទេ។ ជាទូទៅប្រកាសនីយបត្រតក្កកម្មមានអនុភាពពាសពេញពិភពលោកនោះទេ។ ជាដំបូងប្រកាសនីយបត្រតក្កកម្មមួយមានអានុភាពត្រឹមតែមួយដែនដីដែលបានចុះបញ្ជី ប៉ុណ្ណោះមិនមានវិសាលភាពអនុវត្តនៅគ្រប់ប្រទេសដែលជាសមាជិកនៃសន្ធិសញ្ញាទេ។ ប៉ុន្តែប្រសិនបើចង់ឲ្យមានអានុភាពនៅកន្លែងណាមួយគេត្រូវសុំចុះបញ្ជីនៅទីនោះ។ សម្រាប់តក្កកម្មដែលធ្លាប់បានទទួលនូវប្រកាសនីយបត្រ

[24] ប្រការ៣៣ នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[25] ប្រការ៧ នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[26] ប្រការ៨ នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[27] ប្រការ១០ នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

តក្កកម្មនៅបរទេសរួចហើយអ្នកស្នើសុំត្រូវបន្ថែមនូវឯកសារមួយចំនួនផ្សេងទៀតដូចជា៖ សេចក្តីអះអាងអំពីសិទ្ធិអាទិភាពស្របតាមអនុសញ្ញាទីក្រុងប៉ារីសដើម្បីអាចទទួលបានសិទ្ធិជាអាទិភាពក្នុងរយៈពេល១២ខែ គិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីលើកទី១ ព្រមទាំងសំណុំលិខិតដែលបានស្នើសុំចុះបញ្ជីនៅបរទេសនោះនិងប្រកាសនីយបត្រតក្កកម្មបរទេសដែលបានចុះបញ្ជីរួចរាល់ស្រាប់ហើយនោះ ស្របតាមកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា។

តាមច្បាប់ប្រទេសកម្ពុជាបុគ្គលដាក់ពាក្យសុំត្រូវបំពេញបែបបទមួយចំនួនដូចជា៖[28]

-ត្រូវដាក់ពាក្យសុំរបស់ខ្លួនទៅមន្ត្រីកាន់កាប់បញ្ជីដោយរួមមានទាំងកាលបរិច្ឆេទ និងលេខនៃសំណុំលិខិតស្នើសុំទាំងឡាយដែលខ្លួនបានដាក់ពាក្យស្នើសុំនៅបរទេស និងមានជាប់ពាក់ព័ន្ធនឹងតក្កកម្មដែលបានអះអាងនូវសំណុំលិខិតស្នើសុំ។

-ភ្ជាប់មកជាមួយនូវឯកសារចម្លងនៃលិខិតឆ្លងឆ្លើយដែលជាប់ពាក់ព័ន្ធនឹងលទ្ធផលការស្រាវជ្រាវឬលទ្ធផលនៃការពិនិត្យសំណុំលិខិតស្នើសុំបរទេសដែលដាក់ពាក្យសុំបានទទួល។

-ឯកសារចម្លងនៃប្រកាសនីយបត្រតក្កកម្មដែលបរទេសបានផ្តល់ជូនតាមរយៈសំណុំលិខិតស្នើសុំបរទេស។

-ឯកសារចម្លងសេចក្តីសម្រេចចុងក្រោយដែលបដិសេធ មិនទទួលសំណុំលិខិតស្នើសុំបរទេស ឬបដិសេធមិនផ្តល់ប្រកាសនីយបត្រតក្កកម្មតាមសំណើរបស់អ្នកដាក់ពាក្យសុំ។ រាល់ការចុះបញ្ជីឬតម្កល់ឯកសារផ្សេងៗត្រូវបង់កម្រៃតាមការកំណត់របស់ច្បាប់។

### ២.១.២.២. ការត្រួតពិនិត្យលិខិតស្នើសុំចុះបញ្ជី

ការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវបញ្ជាក់អំពីជំពូកនៃតក្កកម្មដែលជាកម្មវត្ថុនៃកិច្ចការពារដោយអនុលោមតាមចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្មដែលនៅក្នុងកិច្ចព្រមព្រៀងទីក្រុងស្តាសបួ ចុះថ្ងៃទី២៥ខែមីនាឆ្នាំ១៩៧១។

ការត្រួតពិនិត្យរបស់មន្ត្រីកាន់កាប់បញ្ជី គឺត្រូវធ្វើឡើងជាពីរដំណាក់កាលមុនពេលចេញប្រកាសនីយបត្រតក្កកម្មជូនអ្នកដាក់ពាក្យសុំគឺ ការពិនិត្យលើការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម និងការត្រួតពិនិត្យលំអិត។

ទី១. ការពិនិត្យលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម៖

នៅក្នុងចំណាត់ការនៃការត្រួតពិនិត្យនេះ យើងអាចហៅបានថា ជាការត្រួតពិនិត្យបឋម។ កម្មវត្ថុនៃការត្រួតពិនិត្យបឋមនេះ គឺជាការត្រួតពិនិត្យមើលលើទម្រង់នៃឯកសារដាក់ពាក្យសុំ ថាតើត្រូវបានបំពេញតាមការកំណត់របស់ច្បាប់ និងមានពត៌មានគ្រប់គ្រាន់ដែរ ឬទេ? ដែលរួមមានជាអាទ៍៖

[28] មាត្រា៣០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

-លិខិតផ្ទេរសិទ្ធិជាតំណាងស្របច្បាប់(ប្រសិនបើមានអ្នកតំណាង)

- ពាក្យស្នើសុំ

-ហត្ថលេខា

-គំរូនៃតក្កកម្ម

-សេចក្តីអធិប្បាយនៃតក្កកម្ម

-សេចក្តីអះអាងនៃសេចក្តីស្នើសុំ

-គំនូសបង្ហាញតក្កកម្ម

-ខ្លឹមសារសង្ខេបនៃតក្កកម្ម

-ឈ្មោះ អាស័យដ្ឋាន និងលំនៅឋានរបស់តក្កករ ឫអ្នកតំណាង

-បានបង់ប្រាក់កម្រៃរដ្ឋបាលកំណត់។

ទី២. ការត្រួតពិនិត្យលំអិត៖ ការត្រួតពិនិត្យលំអិតគឺជា ការពិនិត្យមើលលក្ខខណ្ឌគ្រឹះនៃតក្កកម្ម ភាពថ្មី ជំហានរកឃើញថ្មី និងអាចអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម។ ដំណាក់កាលនេះមន្ត្រីកាន់កាប់បញ្ជីត្រួតពិនិត្យលើអត្ថន័យនៃតក្កកម្មដែលបានដាក់ពាក្យស្នើសុំមកនោះ បានបំពេញលក្ខខណ្ឌនៃតក្កកម្មដែលអាចចុះបញ្ជីបានតាមច្បាប់ដែរឫទេ? ប្រសិនបើតក្កកម្មដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីមិនអាចបំពេញតាមលក្ខខណ្ឌណាមួយ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់អ្នកដាក់ពាក្យស្នើសុំ ឲ្យបំពេញចំណុចខ្វះខាតនៃពាក្យសុំតាមច្បាប់។[29]

### ២.១.២.៣. ការសម្រេចលើប្រកាសនីយបត្រតក្កកម្ម

បើក្រោយពេលមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យខ្លឹមសារនៃសំណុំពាក្យស្នើសុំរួចហើយថា លក្ខខណ្ឌដែលតម្រូវនៅមាត្រា ៣៥និង៣៦ មិនបានបំពេញត្រឹមត្រូវទេ និងមិនអាចត្រូវបានកែតម្រូវទេ នោះមន្ត្រីកាន់កាប់បញ្ជីនឹងសម្រេចបដិសេធការផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្ម។[30] ផ្ទុយទៅវិញ បើគេពិនិត្យឃើញថាត្រឹមត្រូវរួចរាល់អស់ហើយនឹងសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មដល់អ្នកដាក់ពាក្យស្នើសុំ។ នៅរាល់គ្រប់សេចក្តីសម្រេចទាំងឡាយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទាក់ទងនឹងប្រកាសនីយបត្រតក្កកម្មនេះគឺសុទ្ធតែអាចធ្វើជាកម្មវត្ថុនៃការប្តឹងតវ៉ាដោយភាគីពាក់ព័ន្ធទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣ខែ គិតចាប់ពីចេញសេចក្តីសម្រេចនោះមក[31]។

[29] ប្រការ២៥ នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

[30] មាត្រា ៣៥ និង ៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[31] មាត្រា១២៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

### ២.១.២.៤.ការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម

មូលហេតុនៃការបដិសេធជាគោលការណ៍ ការបដិសេធផ្តល់ប្រកាសនីយបត្រតក្កកម្មជូនដល់អ្នកដាក់ពាក្យសុំណាម្នាក់ត្រូវចាត់ទុកថាជាទណ្ឌកម្មរដ្ឋបាលក្នុងករណីដែលសំណុំនៃពាក្យស្នើសុំពុំគោរពទៅតាមខ និងលក្ខខណ្ឌតម្រូវរបស់ច្បាប់។

មូលហេតុពីរយ៉ាងដែលនាំឱ្យមន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការបដិសេធគឺ ការដាក់ពាក្យប្រកាសនីយបត្រតក្កកម្មមិនគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

-ការមិនគោរពលក្ខខណ្ឌគ្រឹះ៖ បើមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យឃើញថាតក្កកម្មដែលបានប្រកាសនីយបត្រតក្កកម្មនោះពុំបានបំពេញនូវលក្ខខណ្ឌវិនិច្ឆ័យតាមខ្លឹមសារនៃតក្កកម្មដែលបានតម្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធនូវពាក្យស្នើសុំចុះបញ្ជីជាដាច់ខាតដោយមិនអាចអនុញ្ញាតឲ្យមានការកែតម្រូវអ្វីឡើយ។ ដូចនេះកង្វះខាតនៃលក្ខខណ្ឌទាក់ទងទៅនឹងខ្លឹមសាររបស់តក្កកម្មនេះ ក៏ជាមូលដ្ឋាននៃការបដិសេធដាច់ខាតនៅក្នុងការទទួលបាននូវប្រកាសនីយបត្រតក្កកម្មនេះដែរ។[32]

-ការមិនគោរពលក្ខខណ្ឌទម្រង់៖ កាលណាមន្ត្រីកាន់កាប់បញ្ជីបានរកឃើញថា សំណុំលិខិតទាំងនោះពុំបានគោរពទៅតាមលក្ខខណ្ឌទម្រង់ដែលបានកំណត់ទេនោះ មន្ត្រីកាន់កាប់បញ្ជីនឹងណែនាំឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការកែតម្រូវជាថ្មីឡើងវិញ។ ប៉ុន្តែប្រសិនបើសំណុំលិខិតទាំងនោះមិនត្រូវបានកែតម្រូវតាមការណែនាំទេ មន្ត្រីកាន់កាប់បញ្ជីនឹងបដិសេធពាក្យស្នើសុំនោះចោលដោយចាត់ទុកថាដូចជាមិនបានសុំចុះបញ្ជី។[33]

### ២.១.២.៥. ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម

កាលបើទាំងលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់បានគោរពតាមគ្រប់គ្រាន់អស់ហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មជូនដល់អ្នកស្នើសុំ។ ករណីនេះការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មដល់អ្នកដាក់ពាក្យស្នើសុំតម្រូវឱ្យអ្នកកាន់កាប់បញ្ជីចេញលិខិតបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មមួយច្បាប់ និងផ្តល់ប្រកាសនីយបត្រតក្កកម្មចម្លងមួយច្បាប់ជូនដល់អ្នកដាក់ពាក្យស្នើសុំនោះ[34]។ បន្ទាប់មកមន្ត្រីកាន់កាប់បញ្ជីត្រូវកក់ត្រាប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ជូននោះចូលក្នុងបញ្ជីសម្រាប់ប្រកាសនីយបត្រតក្កកម្ម។ សេចក្តីចម្លងនៃប្រកាសនីយបត្រតក្កកម្មនេះអាចនឹងត្រូវបានផ្តល់ជូនទៅបុគ្គលណាម្នាក់(ជាសាធារណៈជន) មានប្រយោជន៍ក្រោមរូបភាពជាការជាវពីរដ្ឋទៅតាមតម្លៃដែលបានកំណត់។

[32] ប្រការ២៦ ចំណុចទី២នៃប្រកាសលេខ ៧០៦ ឧរថ កសឧ ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ «ក្នុងករណីការសម្រេចបដិសេធ ការផ្តល់ប្រកាសនីយបត្រតក្កកម្ម មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជាក់អំពីមូលហេតុនៃការបដិសេធនោះ»

[33] មាត្រា៣៤ ចំណុច២នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[34] មាត្រា៣៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

ជាងនេះទៅទៀត ក្រោយទទួលបានប្រកាសនីយបត្រតក្កកម្មនេះម្ចាស់នៃប្រកាសនីយបត្រតក្កកម្មអាចស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជីធ្វើការកែសម្រួលក្នុងអត្ថបទ ឬគំនូសបង្ហាញរបស់ប្រកាសនីយបត្រតក្កកម្មនោះដើម្បីកំណត់ពីទំហំនៃការការពារប្រកាសនីយបត្រតក្កកម្មនោះបាន វៀរលែងតែការកែសម្រួលនោះនាំឱ្យប្រែប្រួលលើខ្លឹមសារដូចមានចែងនៅក្នុងសំណុំលិខិតស្នើសុំពីដំបូង[35]។

### ២.១.២.៥. តម្លៃសេវា

តម្លៃសេវាដែលត្រូវបង់ជូនរដ្ឋាភិបាលសម្រាប់បន្តនូវសុពលភាព គឺមានលក្ខខណៈកើនពីមួយឆ្នាំទៅមួយឆ្នាំ ដែលវាគឺជាចំនុចមួយធ្វើឱ្យប្រកាសនីយបត្រតក្កកម្មមានលក្ខណៈថ្លៃ ដើម្បីការពារតក្កកម្មនោះពីការរំលោភបំពាន។[36]

ជាចុងក្រោយយើងកត់សម្គាល់ឃើញថា នីតិខ្មែរពុំមានមាត្រាណាមួយដែលតម្រូវឲ្យមន្ត្រីកាន់កាប់បញ្ជីមានកាតព្វកិច្ចអាចចុះផ្សាយនូវពាក្យស្នើសុំនោះ ដើម្បីអាចអនុញ្ញាតឱ្យតតិយជនមានប្រយោជន៍ចូលខ្លួនមកអះអាងសិទ្ធិប្រឆាំងនឹងការសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនោះសោះឡើយ។ ថ្វីត្បិតតែមាត្រា១១៩ នៃច្បាប់នេះបានតម្រូវឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលចុះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការនូវរាល់ពត៌មានដែលត្រូវចុះផ្សាយជាសាធារណៈក៏ដោយ។

## ២.២. ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់អន្តរជាតិ

ក្នុងចំណុចនេះដែរយើងនឹងសិក្សាពីការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់អន្តរជាតិ ដោយនឹងមានលើកយកច្បាប់ស្តីពីសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម យកមកធ្វើការបកស្រាយស្តីពីនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មតាមច្បាប់អន្តរជាតិនេះ។

### ២.២.១. ការដាក់ពាក្យ

#### ២.២.១.១. ពាក្យស្នើសុំអន្តរជាតិ

ពាក្យស្នើសុំសម្រាប់ការការពារប្រកាសនីយបត្រតក្កកម្មអន្តរជាតិ អាចធ្វើទៅបានតាមរយៈការដាក់ពាក្យសុំជាអន្តរជាតិស្របតាមសន្ធិសញ្ញានេះ។ ពាក្យស្នើសុំជាអន្តរជាតិត្រូវមានភ្ជាប់ជាមួយការស្នើ ការអត្ថាធិប្បាយ[37] អំណះអំណាងមួយឬច្រើន[38] គំរូបង្ហាញពីតក្កកម្មនោះ[39] (ក្នុងករណីតម្រូវ)និងឧបសម្ព័ន្ធ។[40] ចំពោះឧបសម្ព័ន្ធនេះទៀត

---

[35] មាត្រា៤០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[36] ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥

[37] មាត្រា៥ នៃសន្ធិសញ្ញាសហប្រត្តិបត្តិការប្រកាសនីយបត្រតក្កកម្ម

[38] មាត្រា៦ នៃសន្ធិសញ្ញាសហប្រត្តិបត្តិការប្រកាសនីយបត្រតក្កកម្ម

[39] មាត្រា៧ នៃសន្ធិសញ្ញាសហប្រត្តិបត្តិការប្រកាសនីយបត្រតក្កកម្ម

[40] មាត្រា៣ នៃសន្ធិសញ្ញាសហប្រត្តិបត្តិការប្រកាសនីយបត្រតក្កកម្ម ចុះនៅថ្ងៃទី១៩ មិថុនា ឆ្នាំ ១៩៧០

សោធគឺត្រូវភ្ជាប់មកជាមួយក្នុងគោលបំណងដើម្បីពត៌មានបច្ចេកទេសតែប៉ុណ្ណោះ ដោយមិនអាចយកមកប្រើប្រាស់ក្នុងគោលបំណងផ្សេងឡើយជាពិសេសនោះគឺបកស្រាយអំពីការការពារនៃតក្កកម្ម។

ការដាក់ពាក្យស្នើសុំការពារជាអន្តរជាតិត្រូវគោរពតាមខ្លឹមសារនៃមាត្រា៤ របស់សន្ធិសញ្ញាស្តីពីសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដោយនៅក្នុងពាក្យស្នើសុំនៃប្រកាសនីយបត្រតក្កកម្មត្រូវមានដូចជា៖

- ការអះអាងដែលបញ្ជាក់ថាពាក្យស្នើសុំអន្តរជាតិបានគោរពតាមលក្ខខណ្ឌនៃសន្ធិសញ្ញានេះ
- មានបំណងនៅក្នុងការដាក់ពាក្យស្របតាមពាក្យស្នើសុំអន្តរជាតិនេះ
- ឈ្មោះ និងទិន្នន័យដែលពាក់ព័ន្ធនឹងពាក្យស្នើសុំ និងភ្នាក់ងារ
- ឈ្មោះរបស់តក្កកម្ម
- ឈ្មោះ និងទិន្នន័យផ្សេងៗទៀតពាក់ព័ន្ធនឹងតក្កកម្មដែលតម្រូវដោយច្បាប់ជាតិក្នុងនៅពេលដែលដាក់ពាក្យស្របតាមច្បាប់ជាតិ

#### ២.២.១.២. ការិយាល័យទទួលពាក្យ

ពាក្យស្នើសុំអន្តរជាតិត្រូវដាក់នៅការិយាល័យទទួលពាក្យដើម្បីពិនិត្យពីភាពត្រឹមត្រូវ និងបន្តដំណើរនៃនីតិវិធីស្របតាមសន្ធិសញ្ញា និងបទប្បញ្ញត្តិដទៃទៀត។[41] នៅពេលដែលបានដាក់ពាក្យស្នើសុំនៅការិយាល័យទទួលពាក្យកាលបរិច្ឆេទនោះត្រូវចាត់ទុកជាកាលបរិច្ឆេទនៃការដាក់ពាក្យអន្តរជាតិដោយការិយាល័យទទួលពាក្យត្រូវបង្ហាញ៖[42]

- អ្នកដាក់ពាក្យស្នើសុំមានសិទ្ធិគ្រប់គ្រាន់ក្នុងការដាក់ពាក្យស្នើសុំការពារជាអន្តរជាតិ ដោយមិនមានបញ្ហារាំងស្ទះដោយសារកត្តាតំបន់ ឬសញ្ជាតិឡើយ
- ពាក្យស្នើសុំគឺនៅក្នុងភាសាដែលបានតម្រូវ
- ពាក្យស្នើសុំអន្តរជាតិមានធាតុផ្សំដូចដែលបានរៀបរាប់ខាងក្រោមនេះយ៉ាងហោចណាស់មួយ៖
  - ➢ ការរៀបរាប់ទាំងឡាយណាដែលនៅក្នុងបំណងជាពាក្យស្នើសុំអន្តរជាតិ
  - ➢ ជាការចាត់តាំងរបស់រដ្ឋសមាជិកយ៉ាងហោចណាស់មួយ
  - ➢ ឈ្មោះរបស់អ្នកដាក់ពាក្យដូចដែលបានកំណត់
  - ➢ ផ្នែកណាមួយដែលបានចាត់ទុកជាការអត្ថាធិប្បាយ
  - ➢ ផ្នែកណាមួយដែលបានចាត់ទុកជាអំណះអំណាង

---
[41] មាត្រា១០ នៃសន្ធិសញ្ញាសហប្រត្តិបត្តិការប្រកាសនីយបត្រតក្កកម្ម
[42] មាត្រា១១ នៃសន្ធិសញ្ញាសហប្រត្តិបត្តិការប្រកាសនីយបត្រតក្កកម្ម

ក្នុងករណីដែលការិយាល័យទទួលពាក្យរកឃើញថាពាក្យស្នើសុំអន្តរជាតិមានកំហុសឆ្គង ដែលផ្ទុយពីការរៀបរាប់ខាងលើពេលដែលមកដាក់ពាក្យសុំ នោះការិយាល័យទទួលពាក្យត្រូវចេញលិខិតអញ្ជើញអ្នកដាក់ពាក្យមកបំពេញចំនុចដែលខ្វះខាតនោះ។

នៅក្នុងករណីដែលអ្នកដាក់ពាក្យ បានមកតាមការអញ្ជើញរបស់មន្ត្រីការិយាល័យទទួលពាក្យដើម្បីធ្វើការកែតម្រូវនូវចំនុចដែលខុសនោះ ដូចនេះកាលបរិច្ឆេទនៃការទទួលពាក្យនោះត្រូវផ្លាស់ប្តូរមកថ្ងៃដែលអ្នកដាក់ពាក្យមកកែតម្រូវតក្កកម្មវិញ។ បន្ទាប់ពីបានដាក់ពាក្យរួចរាល់ពាក្យស្នើសុំអន្តរជាតិត្រូវថតចម្លងទុកចំនួនបីច្បាប់ដោយមួយច្បាប់រក្សាទុកនៅការិយាល័យទទួលពាក្យ មួយច្បាប់ត្រូវបញ្ជូនទៅការិយាល័យអន្តរជាតិ និងមួយច្បាប់ចុងក្រោយត្រូវផ្ញើទៅអាជ្ញាធរមានសមត្ថកិច្ចក្នុងការស្រាវជ្រាវអន្តរជាតិ។[43]

### ២.២.២. ការស្រាវជ្រាវអន្តរជាតិ

ពាក្យស្នើសុំអន្តរជាតិទាំងឡាយត្រូវធ្វើការស្រាវជ្រាវជាអន្តរជាតិ ដោយនៅក្នុងគោលបំណងដើម្បីធានាថាតក្កកម្មនោះមិនមានចុះបញ្ជីពីមុនមក។ ការស្រាវជ្រាវជាអន្តរជាតិអាចធ្វើទៅបានគឺអាស្រ័យលើ ចំណុចអត្ថាធិប្បាយ អំណះអំណាង និងគំរូបង្ហាញរបស់តក្កកម្ម។[44]

ការស្រាវជ្រាវអន្តរជាតិត្រូវធ្វើឡើងដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិដែលអាជ្ញាធរស្រាវជ្រាវអន្តរជាតិនេះអាចជាការិយាល័យជាតិ ឬ ជាអង្គការអន្តររដ្ឋាភិបាលដែលមានដូចជាវិទ្យាស្ថានប្រកាសនីយបត្រតក្កកម្មអន្តរជាតិដែលមានតួនាទីក្នុងការបង្កើតរបាយការណ៍ស្រាវជ្រាវទៅលើតក្កកម្មដែលបានស្នើសុំចុះបញ្ជី។ អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវបានតែងតាំងដោយសភានៃសន្ធិសញ្ញាប្រតិបត្តិការមានកិច្ចធានានៃប្រកាសនីយបត្រតក្កកម្ម។[45]

អាជ្ញាធរដែលមានសមត្ថកិច្ចត្រូវប្រកាសនិងត្រូវជូនដំណឹងទៅ អ្នកដាក់ពាក្យនិងការិយាល័យអន្តរជាតិថាមិនមានរបាយណ៍ស្រាវជ្រាវអន្តរជាតិនោះទេ ក្នុងករណីអាជ្ញាធរស្រាវជ្រាវអន្តរជាតិបានពិចារណាលើចំណុចដូចបានរៀបរាប់ខាងក្រោមនេះដូចជា៖[46]

- ពាក្យស្នើសុំអន្តរជាតិដែលពាក្យពាក់ព័ន្ធនឹងកម្មវត្ថុដែលមិនបានតម្រូវដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិដើម្បីធ្វើការស្រាវជ្រាវ និងក្នុងករណីមួយចំនួនគឺសម្រេចមិនធ្វើការស្រាវជ្រាវតែម្តង ឬ
- ការអត្ថាធិប្បាយ អំណះអំណាង ឬគំរូតក្កកម្មមិនត្រឹមត្រូវតាមលក្ខខណ្ឌដែលកំណត់ដែលបណ្តាលឱ្យការស្រាវជ្រាវមិនអាចធ្វើទៅបាន។

---

[43] មាត្រា១២ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

[44] មាត្រា១៥ នៃសន្ធិសញ្ញាប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

[45] មាត្រា១៦ នៃសន្ធិសញ្ញាប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

[46] មាត្រា១៦(២) នៃសន្ធិសញ្ញាប្រត្តិបត្តិការនៃប្រកាសនីយបត្រតក្កកម្ម

ក្នុងករណីអាជ្ញាធរស្រាវជ្រាវអន្តរជាតិ ពិនិត្យឃើញថាពាក្យស្នើសុំអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌនៃតក្កកម្មនោះទេ អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវអញ្ជើញអ្នកដាក់ពាក្យសុំអន្តរជាតិរូបនោះមកធ្វើការបង់ប្រាក់បន្ថែម។ អាជ្ញាធរស្រាវជ្រាវអន្តរជាតិត្រូវបង្កើតឱ្យមានរបាយការណ៍ស្រាវជ្រាវអន្តរជាតិ[47]សម្រាប់ធ្វើការស្រាវជ្រាវលើតក្កកម្មដូចអំណះអំណាងដែលបានភ្ជាប់យកមកជាមួយ ហើយនិងត្រូវកំណត់ពីចំនួនប្រាក់ដែលត្រូវបង់បន្ថែមតាមកាលបរិច្ឆេទកំណត់ជាក់លាក់មួយ។

### ២.២.៣. ការផ្សព្វផ្សាយជាអន្តរជាតិ

ការិយាល័យអន្តរជាតិត្រូវផ្សព្វផ្សាយអំពីពាក្យស្នើសុំអន្តរជាតិនោះ អ្វីដែលពិសេសនោះអ្នកដាក់ពាក្យស្នើសុំអន្តរជាតិត្រូវស្នើសុំទៅការិយាល័យអន្តរជាតិឱ្យធ្វើការផ្សព្វផ្សាយពាក្យស្នើសុំអន្តរជាតិនោះក្នុងរយៈពេល១៨ខែ ដើម្បីឱ្យពាក្យស្នើសុំមានសិទ្ធិអាទិភាព។[48] ជាមួយគ្នានេះផងដែររបាយការណ៍ស្រាវជ្រាវអន្តរជាតិ ឬសេចក្តីប្រកាសអន្តរជាតិត្រូវធ្វើការផ្សព្វផ្សាយផងដែរ។ ប៉ុន្តែផ្ទុយទៅវិញបើការិយាល័យអន្តរជាតិមិនចាំបាច់ធ្វើការផ្សព្វផ្សាយជាអន្តរជាតិទេនោះ គឺកាលណាពាក្យស្នើសុំអន្តរជាតិត្រូវបានដកចេញ ឬត្រូវបានចាត់ទុកថាដកចេញមុខពេលការរៀបចំផ្នែកបច្ចេកទេសនៃការផ្សព្វផ្សាយអន្តរជាតិ។ ក្នុងករណីដែលពាក្យស្នើសុំអន្តរជាតិមានចំនុចមួយចំនួនដែលពាក្យពេចន៍ឬគំរូបង្ហាញមានលក្ខណៈមិនសមរម្យដែលវាធ្វើឱ្យប៉ះពាល់ដល់សីលធម៌ឬសណ្តាប់ធ្នាប់សាធារណៈ ដូចនេះចំណុចដែលមានពាក្យពេចន៍ ឬគំរូបង្ហាញមិនសមរម្យនោះត្រូវលុបចេញពីការផ្សព្វផ្សាយជាអន្តរជាតិនោះ ប៉ុន្តែត្រូវមានការថតចំលងទុកបញ្ជាក់ពីចំណុចនិងទំព័រដែលពុំអាចផ្សព្វផ្សាយបាននោះ។[49]

### ២.២.៤. ការស្រាវជ្រាវអន្តរជាតិបន្ថែម(មិនតម្រូវនោះទេ)

តាមរយៈការស្នើសុំរបស់អ្នកដាក់ពាក្យសុំជាអន្តរជាតិ ដើម្បីឱ្យអាជ្ញាធរស្រាវជ្រាវអន្តរជាតិធ្វើការត្រួតពិនិត្យជាលើកទីពីរដើម្បីជៀសវាងពាក្យស្នើសុំអន្តរជាតិដែលដូចគ្នាធ្លាប់បានផ្សព្វផ្សាយ ហើយអាជ្ញាធរស្រាវជ្រាវអន្តរជាតិបានមើលរំលងអំឡុងពេលនៃការស្រាវជ្រាវលើកដំបូងនោះ ដោយសារតែពាក្យស្នើសុំអាចធ្វើឡើងដោយភាសាខុសៗគ្នា និងស្ថានភាពបច្ចេកទេសខុសៗគ្នា។ ការត្រួតពិនិត្យបន្ថែមនេះអាចធ្វើឡើងដោយអាជ្ញាធរស្រាវជ្រាវអន្តរជាតិផ្សេងទៀត។ ការស្រាវជ្រាវបន្ថែមជាអន្តរជាតិនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីកាត់បន្ថយហានិភ័យពីការចុះបញ្ជីតក្កកម្មដែលធ្លាប់បានចុះបញ្ជីពីមុខមក ហើយអ្វីដែលពិសេសជាងនេះទៅទៀតគឺតាមរយៈការស្នើសុំដើម្បីឱ្យមានការ

[47] មាត្រា១៨ នៃសន្ធិសញ្ញាប្រត្តិបត្តិការនៃប្រកាសនីយបត្រតក្កកម្ម

[48] មាត្រា២១(១) និង(២) នៃសន្ធិសញ្ញាប្រត្តិបត្តិការនៃប្រកាសនីយបត្រតក្កកម្ម

[49] មាត្រា២១(៦) នៃសន្ធិសញ្ញាប្រត្តិបត្តិការនៃប្រកាសនីយបត្រតក្កកម្ម

ស្រាវជ្រាវបន្ថែមអន្តរជាតិទៅពាក្យស្នើសុំនេះគឺអាចពង្រីកភាសានិង/ឬ វិសាលភាពបច្ចេកទេសនៃឯកសារដែលបានស្រាវជ្រាវ។[50]

### ២.២.៥. ការត្រួតពិនិត្យបឋមអន្តរជាតិ (មិនតម្រូវនោះទេ)

ការត្រួតពិនិត្យបឋមអន្តរជាតិ ជាការវាយតម្លៃជាលើកទី២ដើម្បីបញ្ជាក់ថាតក្កកម្មណាមួយដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្ម តាមការយល់ឃើញដែលសរសេរជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិក្នុងស្តង់មួយដែលបានកំណត់។ ក្នុងករណីដែលអ្នកដាក់ពាក្យមានបំណងក្នុងការផ្លាស់ប្តូរពាក្យស្នើសុំអន្តរជាតិរបស់ខ្លួនក្នុងគោលបំណងដើម្បីឱ្យសមស្របតាមឯកសារដែលបញ្ជាក់ក្នុងរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងការសរុបសេចក្តីនៃការយល់ឃើញរបស់អាជ្ញាធរស្រាវជ្រាវអន្តរជាតិ ដោយការត្រួតពិនិត្យបឋមអន្តរជាតិគឺជានីតិវិធីតែមួយគត់ដែលដើរតួយ៉ាងសំខាន់ក្នុងតំណាក់កាលនៃការត្រួតពិនិត្យ និងជាចំណែកមួយដើម្បីឱ្យអ្នកត្រួតពិនិត្យធ្វើការសម្រេចចិត្តមុនពេលដល់តំណាក់កាលអនុវត្តក្នុងប្រទេស។[51]

### ២.២.៦. ដំណាក់កាលអនុវត្តក្នុងប្រទេស

អ្នកដាក់ពាក្យត្រូវធ្វើការសម្រេចចិត្តថាខ្លួនចង់ឱ្យតក្កកម្មខ្លួន ត្រូវបានការពារដោយប្រទេសណាមុខពេលបន្តដំណើរនីតិវិធីទៅតំណាក់កាលបន្ទាប់ដោយត្រូវគោរពតាមលក្ខខណ្ឌរបស់ប្រទេសនោះជាមុនសិន។ លក្ខខណ្ឌទាំងនោះមានដូចជាការបង់កម្រៃទៅតាមការកំណត់របស់ប្រទេសនោះ និងនៅក្នុងករណីខ្លះត្រូវដាក់ស្នើសុំឯកសារបកប្រែផងដែរ។ ក្នុងនីតិវិធីទាំងនេះត្រូវចាប់អនុវត្តមុនពេលចូលដល់ខែទី៣០នៃកាលបរិច្ឆេទអាទិភាពទៅតាមការិយាល័យប្រកាសនីយបត្រតក្កកម្មទៅតាមប្រទេសទាំងនោះ។

### ២.២.៧. តម្លៃសេវា

ជាទូទៅអ្នកដាក់ពាក្យស្នើសុំអន្តរជាតិត្រូវបង់សេវាចំនួនបីប្រភេទនៅពេលដែលដាក់ពាក្យស្នើសុំអន្តរជាតិ៖

- ថ្លៃដាក់ពាក្យអន្តរជាតិមានតម្លៃ ១៣៣០ដុល្លារស្វីស
- ថ្លៃស្រាវជ្រាវដែលមានតម្លៃពី១៥០ ទៅ២០០០ដុល្លារស្វីស អាស្រ័យតាមការជ្រើសរើសអាជ្ញាធរស្រាវជ្រាវអន្តរជាតិ
- ថ្លៃបញ្ជូនឯកសារអាស្រ័យលើការកំណត់ការិយាល័យទទួល[52]

---

[50] WIPO, Protecting your Invention Abroad, ខែមេសា ឆ្នាំ២០២១ PCT FAQs (wipo.int)

[51] មាត្រា ៣១ ៣២ ៣៣ នៃសន្ធិសញ្ញាប្រត្តិបត្តិការនៃប្រកាសនីយបត្រតក្កកម្ម

[52] WIPO, Protecting your Invention Abroad, ខែមេសា ឆ្នាំ២០២១ PCT FAQs (wipo.int)

## ២.៣. ការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មរបស់បរទេស

### ២.៣.១. ប្រកាសនីយបត្រតក្កកម្មនៃកម្ពុជាជាមួយនឹងការិយាល័យប្រកាសនីយបត្រតក្កកម្មជប៉ុន

យោងតាមប្រកាសលេខ១៨១ ស្តីពីការពន្លឿនប្រកាសនីយបត្រតក្កកម្មស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ទាក់ទងនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុនចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ អ្នកដែលដាក់ពាក្យស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្មនៅប្រទេសកម្ពុជា អាចស្នើសុំពន្លឿននីតិវិធីនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មដែលបានដាក់បានក្រោមកិច្ចសហប្រតិបត្តិកាសម្របសម្រួលផ្តល់ប្រកាសនីយបត្រតក្កកម្មនេះ។

យោងតាមប្រកាសលេខ១៨១ ស្តីពីការអនុវត្តកិច្ចសហប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជាពាក្យស្នើសុំពន្លឿននីតិវិធីនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ត្រូវដាក់ទៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុនដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់អោយដោយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុនព្រមទាំងអត្ថបទបកប្រែ។ អត្ថបទត្រូវបកប្រែជាភាសាអង់គ្លេស និងជាភាសាខ្មែរមានដូចជា សេចក្តីអះអាងតក្កកម្ម លក្ខណៈបច្ចេកទេស និងតារាងសេចក្តីអះអាង។ អ្នកដាក់ពាក្យសុំត្រូវផ្តល់អត្ថបទបកប្រែជាភាសាខ្មែរជូនដល់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម។

### ២.៣.២. ការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលកម្ពុជា និងអង្គភាពកម្មសិទ្ធិបញ្ញារបស់ប្រទេសសិង្ហបុរីបានចុះអនុស្សរណៈនៃការយោគយល់គ្នាដោយអនុញ្ញាតអោយមាន ការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសកម្ពុជាតាមរយៈអាជ្ញាធរនៃប្រទេសសិង្ហបុរី ឬក៏ដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មប្រទេសសិង្ហបុរីតាមរយៈអាជ្ញាធរកម្ពុជាបាន។ ក្រោយមកសម្រាប់អនុវត្តអនុស្សរណៈនោះ ក្រសួងឧស្សាហកម្មក៏បានចេញនូវប្រកាសលេខ ១៨២ ស្តីពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ហើយអ្នកដាក់ពាក្យសុំផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ក៏អាចធ្វើបានតាមរយៈអង្គភាពកម្មសិទ្ធិបញ្ញានៅប្រទេសសិង្ហបុរីដែរ។ អនុស្សរណៈនៃការយោគយល់គ្នារវាងប្រទេសទាំងពីរមានសុពលភាព ៥ (ប្រាំ) ឆ្នាំ ចាប់ពីថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៥ និងអាចត្រូវបន្តជាថ្មីបានដោយមានការព្រមព្រៀងគ្នាពីភាគីទាំងពីរ។

ដើម្បីអាចដាក់ពាក្យសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសកម្ពុជា ជាដំបូងអ្នកដាក់ពាក្យសុំត្រូវមានប្រកាសនីយបត្រតក្កកម្មទទួលបានពីប្រទេសសិង្ហបុរីជាមុនសិន។ ម្យ៉ាងទៀត ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីដែលទទួលបាននោះ ត្រូវតែមានសុពលភាពការពារក្នុងអំឡុងពេលនៃការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា ហើយប្រកាសនីយបត្រតក្កកម្មត្រូវមានកាលបរិច្ឆេទសុំចុះបញ្ជីនៅថ្ងៃ ឬក្រោយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣។ ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ត្រូវធ្វើឡើងនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលដោយភ្ជាប់មកជាមួយដូចជា កម្រៃនៃការដាក់ពាក្យ ច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មសិង្ហបុរី ភ្ជាប់ឯកសារថតចម្លងសេចក្តីពណ៌នាលម្អិតនៃប្រកាសនីយបត្រតក្កកម្ម ថតចម្លងខ្លឹមសារតក្កកម្មសង្ខេបដោយមានការបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ច្បាប់ដើមនៃលិខិតផ្ទេរសិទ្ធិតំណាងដោយមានបញ្ជាក់ពីមន្ទីសាការីសាធារណៈ (ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ)។ ទោះបីជា ច្បាប់ថតចម្លងវិញ្ញាបនបត្រប្រកាសនីយបត្រតក្កកម្មសិង្ហបុរីដោយមានការបញ្ជាក់ថាបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមតម្រូវអោយមានក៏ដោយ ក៏មន្ត្រីកាន់កាប់បញ្ជីនៅតែត្រួតពិនិត្យដោយផ្អែកទៅលើច្បាប់ដើមនៃប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន និងបទបញ្ញាត្តិទូទៅផ្សេងទៀតរបស់កម្ពុជាដែរ។ ឯកសារបកប្រែជាភាសាខ្មែរ ត្រូវដាក់ជូនទៅការិយាល័យនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មប្រកាសនីយបត្រតក្កកម្មរបស់ក្រសួងឧស្សាហកម្មក្នុងរយៈពេល៦ (ប្រាំមួយ)ខែ ដោយរាប់គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម។ កម្រៃចុះបញ្ជី និងកម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជាត្រូវបង់ក្នុងរយៈពេល ៣ (បី) ខែគិតចាប់ពីកាលបរិច្ឆេទជូនដំណឹងបង់ប្រាក់។ សិទ្ធិទទួលបានពីការចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅកម្ពុជា មិនត្រូវអនុវត្តមុនកាលបរិច្ឆេទសុំចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មសិង្ហបុរីនៅប្រទេសកម្ពុជាឡើយ។ បុគ្គលដែលប្រើប្រាស់តក្កកម្ម ឬធ្វើអាជីវកម្មលើតក្កកម្មនោះគឺមានសិទ្ធិបន្តធ្វើសកម្មភាពនោះដដែល។ សេចក្តីសម្រេចរបស់ក្រសួងឧស្សាហកម្មពាក់ព័ន្ធនឹងការចុះញ្ជីប្រកាសនីយបត្រតក្កកម្មអាចជាកម្មវត្ថុប្តឹងតវ៉ាទៅតុលាការសមត្ថកិច្ចបានក្នុងរយៈពេល ៣ (បី) ខែ ចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

### ២.៣.៣. ការទទួលស្គាល់នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

ក្រោមកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៣ ខែ មករា ឆ្នាំ២០១៧ ដោយប្រធានអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងទេសរដ្ឋមន្ត្រីនៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលបានអនុញ្ញាតអោយម្ចាស់សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុបអាចស្នើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងពង្រីកវិសាលភាពសិទ្ធិរបស់ខ្លួននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាបាន។ ក្នុងកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

ត្រូវបានអនុម័តយល់ព្រមដោយទ្វេភាគីព្រះរាជក្រមចុះនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ និងប្រកាសរបស់ក្រសួងឧស្សាហកម្មលេខ២៨២ ស្តីពីការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជាចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧។

ចំពោះការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា អាចធ្វើតាមការដាក់ពាក្យស្នើសុំ។ រាល់សំណុំលិខិតស្នើសុំដែលបានដាក់នៅអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុបក៏ដូចសំណុំលិខិតស្នើសុំដែលបានដាក់នៅក្រោមសន្ធិសញ្ញាកិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មដែរ។ សំណុំលិខិតស្នើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុបត្រូវមានថ្ងៃដាក់ពាក្យនៅថ្ងៃ ឬក្រោយថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ជាថ្ងៃដែលកិច្ចព្រមព្រៀងទទួលស្គាល់សុពលភាពចូលជាធរមាន។ ប៉ុន្តែប្រកាសនីយបត្រតក្កកម្មលើផលិតផលឱសថមិនបានរាប់បញ្ចូលក្នុងការការពារក្រោមច្បាប់ប្រកាសនីយបត្រតក្កកម្មរបស់កម្ពុជាឡើយ ហើយដូចនេះសំណុំលិខិតស្នើសុំសម្រាប់ផលិតផលឱសថមិនអាចធ្វើការស្នើសុំទទួលស្គាល់សុពលភាពបានទេ។

ជំហានដំបូងក្នុងដំណើរការស្នើសុំទទួលស្គាល់សុពលភាព គឺត្រូវបង់កម្រៃនៃការទទួលស្គាល់សុពលភាពជាមុននៅក្នុងរយៈពេល៦ (ប្រាំមួយ) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយរបាយការណ៍ការស្រាវជ្រាវក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ឬនៅអំឡុងពេលអនុវត្តការងារដែលបានតម្រូវសម្រាប់ចូលទៅក្នុងដំណាក់កាលអឺរ៉ុបនៃសំណុំលិខិតស្នើសុំអន្តរជាតិ។ សម្រាប់ការបង់កម្រៃនៃការទទួលស្គាល់សុពលភាពនេះអាចធ្វើឡើងដោយភ្នាក់ងារតំណាងនៅអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។ កម្រៃនៃការទទួលស្គាល់សុពលភាពនៅតែអាចអនុញ្ញាតអោយបង់នៅក្នុងរយៈពេលបន្ថែមចំនួន២ (ពីរ) ខែបន្ទាប់ពីផុតរយៈពេល៦ (ប្រាំមួយ) ខែដំបូង ប៉ុន្តែតម្រូវអោយបង់កម្រៃបន្ថែមចំនួន៥0%នៅក្នុងរយៈពេលបន្ថែមនេះ។ ជំហានបន្ទាប់មក សន្មតថាកម្រៃនៃការទទួលស្គាល់សុពលភាពត្រូវបានបង់ក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីកាលបរិច្ឆេទដែលបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបពាក្យស្នើសុំទទួលស្គាល់សុពលភាពត្រូវដាក់ជូនក្រសួងឧស្សាហកម្ម។ រាល់ឯកសាត្រូវការចាំបាច់មានដូចជា ចំណងជើងតក្កកម្ម ខ្លឹមសារសង្ខេប និងសេចក្តីអះអាង ត្រូវបកប្រែជាភាសាអង់គ្លេសទៅភាសាខ្មែរដែលជាភាសាជាតិរបស់កម្ពុជាត្រូវដាក់ទៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម។ កម្រៃនៃការបោះពុម្ព និងកម្រៃការផ្តល់វិញ្ញាបនបត្រនឹងត្រូវបង់បន្ទាប់ពីប្រកាសនីយបត្រតក្កកម្មត្រូវបានផ្តល់ នៅក្រោយពីការចុះបញ្ជីទទួលស្គាល់សុពលភាពបានជោគជ័យ ម្ចាស់ប្រកាសនីយបត្រតក្កកម្មនឹងត្រូវផ្តល់ជូននូវវិញ្ញាបនបត្រចុះបញ្ជីប្រកាសនីយបត្រតក្កកម្មដោយក្រសួងឧស្សាហកម្ម។

# ជំពូកទី៣
# សិទ្ធិនិងភាតព្វកិច្ចដែលទទួលបានបន្ទាប់ពីការចុះបញ្ជី

## ៣.១. អាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ

### ៣.១.១. ប្រភេទអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិ

ម្ចាស់ដើមនៃប្រកាសនីយបត្រតក្កកម្មទទួលបាននូវសិទ្ធិផ្តាច់មុខ នៅក្នុងការធ្វើអាជីកម្មលើតក្កកម្មដែលខ្លួនបានសុំចុះបញ្ជីរួច។ ដូច្នេះតក្កករមានសិទ្ធិក្នុងការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យតតិយជនណាម្នាក់ធ្វើអាជីវកម្មលើតក្កកម្មដែលខ្លួនបានចុះបញ្ជីរួចហើយនោះបាន។

#### ៣.១.១.១. ការអនុញ្ញាតដោយឆន្ទៈនៃម្ចាស់ប្រកាសនីយបត្រតក្កកម្ម

ការអនុញ្ញាតនេះអាចស្តែងឡើងក្រោមទម្រង់ពីរយ៉ាងពោលគឺអាចជា តាមការលក់សិទ្ធិនៃប្រកាសនីយបត្រតក្កកម្មទៅឱ្យតតិយជនតែម្តងដែលហៅថាអនុប្បទានឬអាចគ្រាន់តែជាការជួលសិទ្ធិនោះប៉ុណ្ណោះ។ តាមរយៈយន្តការនៃកិច្ចសន្យាដែលឲ្យឈ្មោះថា «អាជ្ញាប័ណ្ណ» រាល់ការអនុញ្ញាតរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មឲ្យតតិយជន (ជនទី៣ធ្វើអាជីវកម្មលើតក្កកម្មដែលខ្លួនបានចុះបញ្ជីនោះត្រូវមានកាតព្វកិច្ចជូនដំណឹងទៅអាជ្ញាធររដ្ឋ)។ រាល់គ្រប់កិច្ចសន្យាពាក់ព័ន្ធនឹងការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្មឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬការចុះបញ្ជីគំនូរ-ឧស្សាហកម្ម ប្រកាសប្តូរម្ចាស់កម្មសិទ្ធិនៃសំណុំលិខិតស្នើសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរហើយកត់ត្រាចូលបញ្ជីនិងចុះផ្សាយជាសាធារណៈដោយមន្ត្រីកាន់កាប់បញ្ជី លើកលែងតែករណីនៃលិខិតស្នើសុំដែលមិនត្រូវធ្វើការចុះផ្សាយ។[53] ចំពោះការប្តូរម្ចាស់កម្មសិទ្ធិនេះនឹងមិនមានអានុភាពចំពោះភាគីទី៣ឡើយរហូតដល់កត់ត្រាចូលបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ។

#### ៣.១.១.២. ការធ្វើអនុប្បទានសិទ្ធិលើប្រកាសនីយបត្រតក្កកម្ម

ក្នុងកិច្ចសន្យាលក់សិទ្ធីហៅម៉្យាងទៀតថា ការធ្វើអនុប្បទានសិទ្ធិគឺជាកិច្ចសន្យាដែលតាមនោះអនុប្បទាយី (អ្នកធ្វើអនុប្បទានដែលជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម) សម្រេចផ្ទេរនូវសិទ្ធិកម្មសិទ្ធិលើប្រកាសនីយបត្រតក្កកម្មដែលខ្លួនមានទៅឲ្យអនុប្បទានិក(តតិយជនដែលត្រូវទទួលសិទ្ធិ)ជាថ្នូរនឹងកម្រៃណាមួយ។ យើងពុំទាន់មានរបបគតិយុត្តដោយឡែកណាមួយដែលច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនេះបានកំណត់ឲ្យឡើយ។ ដូចនេះត្រូវអនុវត្តរបបគតិយុត្តនៃវិធានរួមជាពិសេសគឺវិធាននៃកិច្ចសន្យាទិញ-លក់។

ម៉្យាងទៀតបើប្រកាសនីយបត្រតក្កកម្មគឺជាសិទ្ធិរួមគ្នារបស់បុគ្គលពីរនាក់ ឬច្រើននាក់នោះការផ្ទេរនោះអាចធ្វើទៅបានតែទៅតាមចំណែកនៃសិទ្ធិដែលបុគ្គលម្នាក់ៗមានប៉ុណ្ណោះ។ តាមរយៈយន្តការនៃកិច្ចសន្យាទៅតាមប្រភេទ

[53] មាត្រា១១៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

កាតព្វកិច្ចមួយចំនួនដែលអនុប្បទាយីត្រូវធានាដល់អនុប្បទានិកគឺ ត្រូវតែមានជាពិសេសគឺការធានាអំពីសុពលភាព នៃប្រកាសនីយបត្រតក្កកម្មដែលជាកម្មវត្ថុនៃកិច្ចសន្យានេះតែម្តង។

### ៣.១.១.៣.ការផ្តល់អាជ្ញាប័ណ្ណសិទ្ធិចំពោះប្រកាសនីយបត្រតក្កកម្ម

សម្រាប់កិច្ចសន្យាជួលសិទ្ធិ ឬហៅម៉្យាងទៀតថាការផ្តល់អាជ្ញាប័ណ្ណគឺជាកិច្ចសន្យាដែលមិនសំដៅផ្ទេរសិទ្ធិកម្មសិទ្ធិលើប្រកាសនីយបត្រតក្កកម្មនោះឡើយ។ តាមយន្តការនេះម្ចាស់នៃប្រកាសនីយបត្រតក្កកម្មដែលនៅក្រោយការបង្កើតកិច្ចសន្យានេះនៅតែជាម្ចាស់សិទ្ធិលើប្រកាសនីយបត្រតក្កកម្មដដែលនោះ បានសម្រេចអនុញ្ញាតផ្តល់សិទ្ធិលើការអាជីវកម្មលើតក្កកម្មរបស់ខ្លួនទាំងមូលឬមួយផ្នែកទៅដល់បុគ្គលម្នាក់ហៅថា«អ្នកទទួលអាជ្ញាប័ណ្ណ» គឺជាថ្នូរនឹងកម្រៃណាមួយ។ ជាទូទៅកិច្ចសន្យាប្រភេទនេះអាចត្រូវបានប្រដូចនឹងកិច្ចសន្យាជួលទូទៅផងដែរពោលគឺអាចធ្វើឡើងដោយមានការកម្រិតសិទ្ធិដែលត្រូវអនុញ្ញាតនោះ ឬដោយគ្មានកម្រិតសិទ្ធិ។ ក្នុងករណីដែលកិច្ចសន្យាពុំបានហាមឃាត់អ្នកទទួលអាជ្ញាប័ណ្ណអាចសម្រេចជួលសិទ្ធិនេះបន្តឲ្យទៅបុគ្គលផ្សេងទៀតផងដែរហៅថាអាជ្ញាប័ណ្ណបន្ត។ កិច្ចសន្យាអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬគំនូសឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ ឬសំណុំលិខិត ករណីខាងលើនេះត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី។[54] មន្ត្រីកាន់កាប់បញ្ជីត្រូវរក្សាការសម្ងាត់ដែលមាននៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ ប៉ុន្តែត្រូវកត់ត្រាចូលបញ្ជី និងត្រូវចុះផ្សាយជាសាធារណៈនូវចំណុចគោលមួយចំនួន។ កិច្ចសន្យអាជ្ញាប័ណ្ណនេះមិនមានអានុភាពចំពោះភាគីទី៣ឡើយ រហូតដល់ការកត់ត្រាចូលបញ្ជីត្រូវធ្វើរួចជាស្ថាពរ។

### ៣.១.១.៤. ការអនុញ្ញាតដោយបង្ខំឆន្ទៈនៃម្ចាស់ប្រកាសនីយបត្រតក្កកម្ម

ក្នុងករណីមួយចំនួន អាជ្ញាធរដែលតំណាងដោយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចសម្រេចឲ្យមានការធ្វើអាជីវកម្មលើតក្កកម្មបើទោះបីជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មរូបនោះពុំផ្តល់ឆន្ទៈយល់ព្រមក៏ដោយ ការអនុញ្ញាតនេះអាចស្តែងឡើងក្រោមរូបភាពពីរយ៉ាងផ្សេងៗគ្នាគឺការអនុញ្ញាតឱ្យធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬដោយបុគ្គលដែលបានទទួលការអនុញ្ញាតពីរដ្ឋាភិបាល ឬក៏អាចជាអាជ្ញាប័ណ្ណបញ្ញា។ ដោយសារតែការអនុញ្ញាតក្រោមទម្រង់ទាំងពីរនេះសុទ្ធសឹងតែត្រូវបានសម្រេចដោយអាជ្ញាធររដ្ឋ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដូចគ្នា។ ដូចនេះហើយ អ្នកដែលទទួលបានការអនុញ្ញាតទាំងនេះសុទ្ធតែពុំអាចផ្ទេរបន្តតាមឆន្ទៈរបស់ខ្លួន (ធ្វើអាជ្ញាប័ណ្ណបន្តទៀត) ទៅបុគ្គលផ្សេងទៀតបានដោយសេរីដូចករណីនៃអាជ្ញាប័ណ្ណទូទៅឡើយ លើកលែងតែមានការយល់ព្រមពីអាជ្ញាធររដ្ឋនោះ។ ប៉ុន្តែដោយសារវាជាសិទ្ធិបេតិកភ័ណ្ឌ វាក៏ជាផ្នែកមួយនៃទ្រព្យសកម្មរបស់អ្នកទទួលបានអាជ្ញាប័ណ្ណជារូបវន្តបុគ្គលឬជាមូលនិធិពាណិជ្ជកម្មរបស់សហគ្រាសដែរ និងអាចផ្ទេរបាននៅក្នុងករណីពិសេសមួយ

[54] មាត្រា១១៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

ចំនួនដូចជាការផ្ទេរជាមួយទ្រព្យ ឬមូលនិធិពាណិជ្ជកម្មទាំងមូលដោយមូលហេតុសងបំណុលក្ស័យធន ទទួលមរណភាពឬដោយលក់មូលនិធិពាណិជ្ជកម្មនោះ។ល។

### ៣.១.១.៥. ការអនុញ្ញាតឱ្យធ្វើអាជីវកម្មតក្កកម្មដោយរដ្ឋាភិបាល ឬដោយបុគ្គលទទួលបានការអនុញ្ញាតពីរដ្ឋាភិបាល

ការសម្រេចអនុញ្ញាតត្រូវតែឈរលើមូលដ្ឋាននៃការបម្រើផលប្រយោជន៍សាធារណៈ ឬមូលហេតុនៃការធានាឲ្យមានការប្រកួតប្រជែងមួយដោយស្មោះត្រង់។[55] ដើម្បីជាការលះបង់ចំពោះបុព្វហេតុទាំងពីរខាងលើនេះរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលអាចជ្រើសរើសតតិយជនណាម្នាក់ដែលអាចជាអង្គភាពចំណុះរដ្ឋ ឬឯកជនសុទ្ធសាធឲ្យធ្វើអាជីវកម្មលើតក្កកម្មបានទោះបីជាគ្មានការយល់ព្រមពីម្ចាស់នៃប្រកាសនីយបត្រតក្កកម្មក៏ដោយ។ ការពិតទៅការសម្រេចនេះអាចត្រូវបានចាត់ទុកដូចជាការបង្ខំឲ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឱ្យធ្វើអាជ្ញាប័ណ្ណលើតក្កកម្មរបស់ខ្លួនដែលគ្រាន់តែតាមរយៈយន្តការនេះ ម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្មនឹងបាត់បង់សេរីភាពក្នុងការចុះកិច្ចសន្យាពីព្រោះការសម្រេចចិត្តជ្រើសរើសដៃគូនៃកិច្ចសន្យាប្រភេទអាជ្ញាប័ណ្ណនេះ និងការកំណត់អំពីខ្លឹមសារនៃកិច្ចសន្យាត្រូវធ្វើឡើងដោយរដ្ឋមន្ត្រី។ ប៉ុន្តែម្ចាស់ប្រកាសនីយបត្រតក្កកម្ម នៅតែជាម្ចាស់នៃអាជ្ញាប័ណ្ណដែលមានសិទ្ធិទទួលបានផលប្រយោជន៍សមរម្យដូចករណីអាជ្ញាប័ណ្ណទូទៅដដែល។

លើសពីនេះទៅទៀត យន្តការនៃអាជ្ញាប័ណ្ណដោយការសម្រេចរបស់រដ្ឋនេះផ្តល់អំណាចធំធេងណាស់ដល់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនេះ។[56] រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចសម្រេចកែប្រែលើខ្លឹមសារនៃអាជ្ញាប័ណ្ណ ឬក៏សម្រេចបញ្ចប់អាជ្ញាប័ណ្ណនៅក្នុងសុពលភាពនៃអាជ្ញាប័ណ្ណនោះក៏បាន។ តែទោះជាយ៉ាងណាក៏ដោយ ការសម្រេចនេះគឺគ្រាន់តែជាអាជ្ញាប័ណ្ណមិនទាន់ដាច់ខាតមួយដោយសារតែច្បាប់នៅតែទទួលស្គាល់សិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មនៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណនេះតាមឆន្ទៈរបស់ខ្លួន និងក្នុងករណីអាជ្ញាប័ណ្ណមានបញ្ហាគឺនៅតែអាចធ្វើបានជាដដែល។[57] ជាចុងក្រោយការអនុញ្ញាតនេះគឺគ្រាន់តែជាសេចក្តីសម្រេចរដ្ឋបាលដែលនៅក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចនេះម្ចាស់ប្រកាសនីយបត្រតក្កកម្ម នៅតែមានសិទ្ធិប្តឹងប្រឆាំងតវ៉ាទៅតុលាការមានសមត្ថកិច្ចជានិច្ច។[58]

[55] មាត្រា៤៧ (១) នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[56] មាត្រា៤៨ និង ៤៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[57] មាត្រា៥១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[58] មាត្រា៥៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

### ៣.១.១.៦. អាជ្ញាប័ណ្ណបញ្ជា

អាជ្ញាប័ណ្ណប្រភេទនេះផងដែរ វាគឺជាកិច្ចសន្យាដែលតាមនោះរដ្ឋបង្ខំឲ្យម្ចាស់ប្រកាសនីយបត្រតក្កកម្មបង្កើតកិច្ចព្រមព្រៀងមួយជាមួយនឹងតតិយជនណាម្នាក់តាមការស្នើសុំរបស់តតិយជននោះនៅក្រោមរូបភាពជា ទណ្ឌកម្មនៃការមិនធ្វើអាជីវកម្មលើតក្កកម្មដែលបានចុះបញ្ជីរួចហើយរបស់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះ។ ប្រការខុសនេះពីច្បាប់ពីច្បាប់បារាំងដែលអាជ្ញាប័ណ្ណនេះគឺត្រូវតែជាលទ្ធផលនៃសេចក្តីសម្រេចរបស់តុលាការ ឯច្បាប់ខ្មែរផ្តល់អំណាចសម្រេចនេះទៅឲ្យរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលតែប៉ុណ្ណោះ។ សេចក្តីសម្រេចអំពីអាជ្ញាប័ណ្ណបញ្ជានេះត្រូវតែមានចែងអំពីលក្ខខណ្ឌក្នុងការធ្វើអាជីវកម្មដែលអ្នកទទួលអាជ្ញាប័ណ្ណ និងរួមមានទាំងចែងអំពីវិសាលភាព មុខងារនៃអាជ្ញាប័ណ្ណ ពេលវេលាកំណត់ដែលអ្នកទទួលអាជ្ញាប័ណ្ណត្រូវចាប់ផ្តើមធ្វើអាជីវកម្មលើតក្កកម្មនោះ ចំនួនទឹកប្រាក់ និងលក្ខខណ្ឌទូទាត់កម្រៃសមរម្យដែលត្រូវផ្តល់ជូនទៅម្ចាស់ប្រកាសនីយបត្រតក្កកម្មទៀតផង[59]។ ប៉ុន្តែដើម្បីទទួលបាននូវសិទ្ធិធ្វើអាជីវកម្មតាមរយៈអាជ្ញាប័ណ្ណបញ្ជានេះ ក៏បានតម្រូវឲ្យតតិយជនដែលជាអ្នកស្នើសុំត្រូវតែបង្ហាញភស្តុតាងអំពីលក្ខខណ្ឌដូចច្បាប់កំណត់។ យើងធ្វើការបែងចែកលក្ខខណ្ឌទាំងនោះជាពីរ គឺជួលកាលដោយសារតែការមិនធ្វើអាជីវកម្ម ឫការធ្វើអាជីវកម្មមិនពេញលេញនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលក្នុងករណីនេះអ្នកទទួលអាជ្ញាប័ណ្ណត្រូវមានកាតព្វកិច្ចអនុវត្តការធ្វើអាជីវកម្មលើតក្កកម្មឲ្យបានពេញលេញតាមច្បាប់[60] ពុំនោះទេរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលអាចបញ្ចប់អាជ្ញាប័ណ្ណនោះបានដូចជានៅក្នុងករណីនៃការធ្វើអាជីវកម្មដោយរដ្ឋាភិបាលឫដោយមានការអនុញ្ញាតពីរដ្ឋាភិបាលផងដែរ[61]។

ជួនកាលទៀត វាគឺដោយសារតែមានវត្តមាននៃជម្លោះលើការធ្វើអាជីវកម្មប្រកាសនីយបត្រតក្កកម្មពីរដែលមានកម្មវត្ថុជាតក្កកម្មទាក់ទងគ្នា។ ក្នុងន័យនេះប្រសិនបើមានតក្កកម្មពីរស្ថិតក្រោម ប្រកាសនីយបត្រតក្កកម្មពីរដាច់ដោយឡែកពីគ្នាដែលតក្កកម្មជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មក្រោយ(ទី២) មានកម្រិតនៃបច្ចេកទេសជឿនលឿន និងមានសារៈសំខាន់ចំពោះសេដ្ឋកិច្ចជាងបើប្រៀបធៀបនឹងតក្កកម្មដែលជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មមុន (ទី១) ហើយប្រសិនបើតក្កកម្មទី២នេះមិនអាចនឹងធ្វើអាជីវកម្មបានដោយមិនប៉ះពាល់ដល់ការធ្វើអាជីវកម្មនៃតក្កកម្មទី១ នោះអាជ្ញាប័ណ្ណនោះអាចស្នើសុំទៅរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដោយម្ចាស់នៃប្រកាសនីយបត្រតក្កកម្មក្រោ(ទី២)នេះ ដើម្បីអាចបញ្ចៀសឱ្យផុតនូវការរំលោភសិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មមុន(ទី១)នោះ។[62] ក្នុងករណីនេះផ្អែកទៅតាមមាត្រា៦០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មឆ្នាំ២០០៣នៅពេលមានការស្នើសុំរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មមុន(ទី១) រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មត្រូវសម្រេចឲ្យមានអាជ្ញាប័ណ្ណបញ្ជាត្រលប់ទៅ

[59] មាត្រា៥៧ និង ៥៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[60] មាត្រា៥៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[61] មាត្រា៦៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[62] មាត្រា៥៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

លើប្រកាសនីយបត្រតក្កកម្មក្រោយ(ទី២) វិញ។ ដូច្នេះករណីនេះត្រូវមានអាជ្ញាប័ណ្ណបញ្ជាចំនួនពីរដែលទំនាក់ទំនងនឹងគ្នា។ របបគតិយុត្តិដែលត្រូវអនុវត្តលើអាជ្ញាប័ណ្ណបញ្ជាទាំងពីគឺដូចគ្នានឹងរបបគតិយុត្តិនៃអាជ្ញាប័ណ្ណទូទៅផងដែរ លើកលែងតែការផ្ទេរដែលកើតចេញពីអាជ្ញាប័ណ្ណប្រភេទនេះអាចធ្វើបានតែដោយមានការផ្ទេរប្រកាសនីយបត្រតក្កកម្មនីមួយៗប៉ុណ្ណោះ ពីព្រោះតែបុព្វហេតុនៃការបង្កើតអាជ្ញាប័ណ្ណប្រភេទនេះគឺដើម្បីបញ្ចៀសនូវជម្លោះក្នុងការរំលោភសិទ្ធិគ្នានៃប្រកាសនីយបត្រតក្កកម្មនីមួយៗនៅពេលធ្វើអាជីវកម្ម។

### ៣.១.២. លក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណបញ្ជា

#### ៣.១.១.១. សេចក្តីសម្រេចចេញអាជ្ញាប័ណ្ណបញ្ជា

ការសម្រេចចេញអាជ្ញាប័ណ្ណបញ្ជាគឺត្រូវបានបែងចែកជាវិសាលភាព និងមុខងារនៃអាជ្ញាប័ណ្ណហើយពេលវេលាកំណត់ដែលអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវកំណត់ចាប់ផ្តើមធ្វើអាជីវកម្មលើតក្កកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្ម។ចំនួនប្រាក់សមរម្យត្រូវជូននិងទូទាត់តាមលក្ខខណ្ឌទៅម្ចាស់ប្រកាសនីយបត្រតក្កកម្ម។[63]

#### ៣.១.១.២. សិទ្ធិរបស់អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជា

អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជា មានសិទ្ធិធ្វើអាជីវកម្មលើតក្កកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្មរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅតាមលក្ខខណ្ឌដូចដែលមានចែង នៅក្នុងសេចក្តីសម្រេចនៃការចេញអាជ្ញាប័ណ្ណបញ្ជានោះ។ អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជា ត្រូវចាប់ផ្តើមធ្វើអាជីវកម្មលើតក្កកម្មនោះទៅតាមពេលវេលាដែលបានកំណត់នៅក្នុងសេចក្តីសម្រេចខាងលើ និងត្រូវធ្វើអាជីវកម្មឲ្យបានពេញលេញលើតក្កកម្មនោះ។[64]

#### ៣.១.២.៣. សិទ្ធិនិងភាតព្វកិច្ចដែលបានពីអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម

#### ក. ទំហំនៃសិទ្ធិ

សិទ្ធិផ្តាច់មុខនៃម្ចាស់ប្រកាសនីយបត្រតក្កកម្ម គឺការធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជានូវតក្កកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្មរួច។ ឯចំពោះបុគ្គលដទៃទៀតនោះចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះ។[65] ក្រៅពីគោរពនៃគោលការណ៍ពេលវេលា(អាជ្ញាយុកាលនៃសិទ្ធិ) និងគោលការណ៍ដែនដីនៃសិទ្ធិ ម្ចាស់សិទ្ធិនៃប្រកាសនីយបត្រតក្កកម្មមានសិទ្ធិផ្តាច់មុខទៅលើតក្កកម្មនោះក្នុងរបៀបស្រដៀងគ្នាទៅនឹងសិទ្ធិកម្មសិទ្ធិទូទៅដែរពោលគឺសិទ្ធិប្រើប្រាស់ អាស្រ័យផល និងសិទ្ធិចាត់ចែង។

ការធ្វើអាជីវកម្មលើតក្កកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្មរួចហើយ ចង់សំដៅដល់សកម្មភាពពីរប្រភេទគឺ ប្រកាសនីយបត្រតក្កកម្មសម្រាប់អាជីវកម្មចំពោះផលិតផល និងប្រកាសនីយបត្រតក្កកម្មចំពោះដំណើរការ

[63] មាត្រា៥៧ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[64] មាត្រា៥៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[65] មាត្រា៤១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

ផលិតតក្កកម្ម។ ទាក់ទងនឹងសិទ្ធិរបស់ប្រកាសនីយបត្រតក្កកម្មលើផលិតផលនេះរួមមានទាំងទៅលើការផលិត ការនាំចូល ការផ្គត់ផ្គង់សម្រាប់ការលក់ និងសម្រាប់ការប្រើប្រាស់ផលិតផលនោះ និងទាំងការស្តុកទុកផលិតផលនោះក្នុងគោលបំណងផ្គត់ផ្គង់សម្រាប់លក់ ឫសម្រាប់ប្រើប្រាស់ផងដែរ។

**ខ. កាតព្វកិច្ច**

ថ្វីត្បិតតែប្រកាសនីយបត្រតក្កកម្ម អាចចាត់ទុកជាប្រភពនៃសិទ្ធិផ្តាច់មុខនៅក្នុងការធ្វើអាជីវកម្មលើតក្កកម្មដែលរដ្ឋយល់ព្រមផ្តល់ដល់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះក៏ដោយ ក៏ភាពជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះនឹងត្រូវប្រឈមមុខនឹងបន្ទុកនៃកាតព្វកិច្ចដែលតម្រូវមួយចំនួនជាថ្នូរនិងសិទ្ធិដែលផ្តល់ឲ្យនេះ និងហានិភ័យនៃការប្រកាសមោឃភាពនៃប្រកាសនីយបត្រតក្កកម្មនោះចោលទៅវិញដែរ នៅក្នុងករណីដែលមានបណ្តឹងពីវិការៈមួយចំនួនក្រោយពេលសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម។

ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មមានកាតព្វកិច្ចពីរគឺ៖ ទី១ ត្រូវបង់កម្រៃប្រចាំឆ្នាំសម្រាប់ជាថ្នូរនឹងការទទួលស្គាល់សិទ្ធិប្រកាសនីយបត្រតក្កកម្ម ដើម្បីជាការធានាឱ្យបាននូវសុពលភាពនៃប្រកាសនីយបត្រតក្កកម្មនិងសំណុំលិខិតនៃពាក្យស្នើសុំទាំងអស់ផងដែរជូនមន្ត្រីកាន់កាប់បញ្ជី។ នៅក្នុងអំឡុងពេលសុពលភាពរបស់ប្រកាសនីយបត្រតក្កកម្ម កម្រៃនេះនឹងត្រូវបង់ជូនទៅមន្ត្រីកាន់កាប់បញ្ជី១ឆ្នាំម្តងៗជារៀងរាល់ឆ្នាំ គិតរាប់ពីពេលមួយឆ្នាំក្រោយកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំពោលគឺក្នុងរយៈពេល៣ខែ គិតចាប់ពីពេលជូនដំណឹងអំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មនេះរួចមក។[66] រយៈពេលអនុគ្រោះអាចនឹងត្រូវបានផ្តល់ឲ្យចំពោះរាល់ការយឺតយ៉ាវក្នុងការបង់កម្រៃប្រចាំឆ្នាំជាថ្នូរនឹងការបង់កម្រៃបន្ថែមលើការយឺតយ៉ាវនេះទៅតាមតម្លៃកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[67] ករណីដែលពុំបានបង់កម្រៃប្រចាំឆ្នាំនេះនឹងអាចក្លាយជាកម្មវត្ថុនៃការលុបចោលប្រកាសនីយបត្រតក្កកម្មដែលផ្តល់ជូននោះ។ ទី២ ត្រូវធ្វើអាជីវកម្មលើតក្កកម្ម បើទោះបីជាកាតព្វកិច្ចក្នុងការធ្វើអាជីវកម្មពុំបានបញ្ញត្តិដោយជាក់ស្តែងនៅក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនេះក៏ដោយ ក៏កាតព្វកិច្ចក្នុងការធ្វើអាជីវកម្មនេះហាក់ស្តែងឡើងទន្ទឹមគ្នានឹងសិទ្ធិផ្តាច់មុខក្នុងការធ្វើអាជីវកម្មលើតក្កកម្ម ដែលច្បាប់នេះបានប្រគល់ជូនដល់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មទាំងឡាយផងដែរ។ ដោយផ្អែកលើការបកស្រាយប្រាស ឫផ្ទុយទៅលើអត្ថន័យនៃមាត្រា៥៦នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មចែងថា៖ នៅរាល់ពេលដែលមានការស្នើសុំទៅរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលរយៈពេល ៤ឆ្នាំ គិតពីកាលបរិច្ឆេទសុំចុះបញ្ជីនៃប្រកាសនីយបត្រតក្កកម្ម ឫ៣ឆ្នាំគិតពីកាលបរិច្ឆេទផ្តល់ប្រកាសនីយបត្រតក្កកម្មដោយយកកាលបរិច្ឆេទមួយណាដែលផុតកំណត់ក្រោយគេ នោះរដ្ឋមន្ត្រីអាចចេញអាជ្ញាប័ណ្ណបញ្ជាបានបើពិនិត្យឃើញថាតក្កកម្មដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្មរួចហើយ មិន

[66] មាត្រា៤៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[67] មាត្រា៤៦ និង ១៣០ នៃច្បាប់ស្តីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

ត្រូវបានធ្វើអាជីវកម្ម ឬក៏ធ្វើអាជីវកម្មមិនពេញលេញ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងអាចកំណត់បានថា ច្បាប់នេះបានបង្ខំឲ្យម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ត្រូវតែមានកាតព្វកិច្ចធ្វើអាជីវកម្មលើតក្កកម្មដែលខ្លួនបានសុំរួចរាល់ហើយនោះ។ ទណ្ឌកម្មនៃការមិនគោរពកាតព្វកិច្ចនេះពុំមែនជាការលុបចេញពីបញ្ជីដែលបានចុះរួចរាល់ហើយដូចក្នុងករណីសិទ្ធិលើម៉ាក់ទេ ប៉ុន្តែជាការតម្រូវឲ្យមានអាជ្ញាប័ណ្ណបញ្ហាដើម្បីធានាឲ្យបាននូវការធ្វើអាជីវកម្មពិតប្រាកដ និងគ្រប់គ្រាន់មួយលើតក្កកម្មនោះទៅវិញពោលគឺជាការបង្ខំឲ្យធ្វើអាជីវកម្មដោយរដ្ឋតែម្តង។

ប្រកាសនីយបត្រតក្កកម្មដែលបានចុះបញ្ជីរួចរាល់ហើយក៏អាចក្លាយជាកម្មវត្ថុនៃការប្រកាសមោឃភាពបានដែរ។[68] គ្រប់បុគ្គលដែលមានការពាក់ព័ន្ធ ឬមានផលប្រយោជន៍ទាំងឡាយអាចស្នើសុំទៅតុលាការមានសមត្ថកិច្ចឲ្យសម្រេចទុកជាមោឃៈនូវប្រកាសនីយបត្រតក្កកម្មបាន។ ការមោឃភាពនេះត្រូវផ្អែកលើមូលដ្ឋានដូចមានចែងក្នុងមាត្រា៦៦នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មដែទាក់ទងផ្ទាល់ជាមួយនឹងតក្កកម្ម ឬតក្កករដូចជាតក្កកម្មនោះផ្ទុយនឹងលក្ខខណ្ឌតម្រូវណាមួយនៃវាក្យខ័ណ្ឌទី២ និងទី៣នៃមាត្រា៣ ទាក់ទងនឹងនិយមន័យនៃតក្កកម្មមាត្រា៤ ទាក់ទងនឹងតក្កកម្មដែលមិនអាចជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មបានមាត្រា៥ ដល់មាត្រា៩ ទាក់ទងនឹងលក្ខខណ្ឌគ្រឹះនៃតក្កកម្ម និងតក្កកម្មដែលត្រូវបានហាមឃាត់ដាច់ខាត់ ឬករណីប្រសិនបើម្ចាស់នៃប្រកាសនីយបត្រតក្កកម្មមិនមែនជាតក្កករ ឬមិនមែនជាអ្នកស្នងបន្តរបស់តក្កករទេនោះ។ ក្នុងករណីបណ្តឹងសុំមោឃភាពនេះបន្ទុកនៃភស្តុតាងអំពីហេតុនៃមោឃភាពត្រូវធ្លាក់ទៅលើបុគ្គលដែលជាអ្នកប្តឹងអំពីមោឃភាពនោះ។

កាលបើមោឃភាពនៃប្រកាសនីយបត្រតក្កកម្មត្រូវបានប្រកាសដោយតុលាការ នោះអានុភាពប្រតិសកម្មនៃមោឃភាពនេះនឹងបណ្តាលឲ្យរាល់សំណុំលិខិត និងឯកសារគតិយុត្តិទាំងឡាយដែលទាក់ទងនឹងប្រកាសនីយបត្រតក្កកម្មរួមទាំងសេចក្តីអះអាង ឬផ្នែកនៃសេចក្តីអះអាងនោះផងត្រូវទុកជាមិនបានការនិងអស់សុពលភាពចាប់ពីថ្ងៃដែលប្រកាសផ្តល់ប្រកាសនីយបត្រតក្កកម្មនោះមក។[69] សេចក្តីសម្រេចជាស្ថាពររបស់តុលាការអំពីមោឃភាពនេះត្រូវតែជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជីដើម្បីកត់ត្រានិងចុះផ្សាយឲ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន។[70]

### ៣.១.៣. ការរំលោភសិទ្ធិ និង ដំណោះស្រាយវិវាទ

ដូចទៅនឹងករណីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិលើម៉ាក់ផងដែរសិទ្ធិដែលប្រគល់ឲ្យតាមរយៈប្រកាសនីយបត្រតក្កកម្មនេះ នឹងអាចក្លាយទៅជាកម្មវត្ថុនៃការរំលោភបំពានសិទ្ធិដ៏ស្រួចស្រាលមួយផងដែរ។ ដូច្នេះហើយក្នុងទិសដៅ

[68] មាត្រា៦៥ ដល់ ៦៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[69] មាត្រា៦៧ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

[70] មាត្រា៦៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ២០០៣

នៃការធានាឲ្យមានប្រសិទ្ធិភាពនូវការការពារសិទ្ធិស្របច្បាប់របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ច្បាប់បានបង្កើតនូវយន្តការដោះស្រាយប្រឆាំងនឹងអំពើរំលោភបំពានទាំងនេះ ដើម្បីលើកទឹកចិត្តដល់ការសុំប្រកាសនីយបត្រតក្កកម្មនេះផងដែរ។

### ៣.១.៣.១. ការរំលោភសិទ្ធិលើប្រកាសនីយបត្រតក្កកម្ម

ការរំលោភសិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម សំដៅដល់ការអនុញ្ញាតនូវសកម្មភាពដែលបំពានដល់សិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មដូចមានចែងក្នុងផ្នែកទី៩នៃជំពូកទី២នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម។ ពាក្យថាការរំលោភសិទ្ធិក្នុងន័យនេះគឺ វាស្តែងឡើងក្រោមទម្រង់ជាអំពើក្លែងបន្លំលើតក្កកម្មដែលបានចុះបញ្ជីការពារដោយប្រកាសនីយបត្រតក្កកម្មរួចហើយ។ ដើម្បីប្រឆាំងនឹងការរំលោភសិទ្ធិនេះគឺទាមទារនូវការរៀបចំនីតិវិធីប្តឹងទៅតុលាការមានសមត្ថកិច្ច។ ក្នុងករណីនេះ មានតែម្ចាស់ប្រកាសនីយបត្រតក្កកម្មតែម្នាក់គត់ដែលមានគុណភាពគ្រប់គ្រាន់ក្នុងការប្តឹងនេះ។ ផ្ទុយទៅវិញម្ចាស់សិទ្ធិដែលទទួលបានតាមរយៈកិច្ចសន្យាអនុប្បទាន ឬតាមរយៈអាជ្ញាប័ណ្ណទាំងឡាយពុំអាចស្នើសុំទៅតុលាការដោយផ្ទាល់បានទេពោលគឺត្រូវស្នើសុំឲ្យម្ចាស់ដើមនៃគឺប្រកាសនីយបត្រតក្កកម្មជាអ្នកប្តឹង។ តែទោះជាយ៉ាងណាក៏ដោយដើម្បីបង្ការសិទ្ធិក្នុងគោលបំណងបំពានដល់ការធ្វើអាជីវកម្មស្របច្បាប់ ឬស៊ើបពត៌មានអំពីតក្កកម្មណាមួយតាមរយៈការប្តឹងនេះច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មបានបញ្ញត្តិថា «ការចោទប្រកាន់អំពីបទរំលោភសិទ្ធិនេះមិនអាចធ្វើបានទេប្រសិនបើផលិតផលថ្មី ហើយអ្នកដែលត្រូវចោទប្រកាន់នោះទៀតសោតបានលើកភស្តុតាងមកបញ្ជាក់ថា ផលិតផលនោះមិនត្រូវបានផលិតតាមដំណើរផលិតកម្មដែលចោទប្រកាន់ថារំលោភសិទ្ធិនោះ។ នៅក្នុងករណីនេះផងដែរ តុលាការមានសមត្ថកិច្ចត្រូវតែគិតគូដល់ផលប្រយោជន៍ស្របច្បាប់របស់បុគ្គលដែលត្រូវចោទប្រកាន់ថារំលោភនោះដោយមិនធ្វើឲ្យលេចឮខ្ចរខ្ចាយអំពីការសម្ងាត់នៃការផលិត និងរបរជំនួញរបស់បុគ្គលដែលត្រូវចោទប្រកាន់នោះឡើយ»។

### ៣.១.៣.២. យន្តការដោះស្រាយវិវាទ

#### ក. ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ

ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក៏ជាផ្នែកមួយក្នុងការការពារការរំលោភលើអាជីវកម្មតក្កកម្មដែរ។ អំពើនៃការរំលោភសិទ្ធិលើអាជីវកម្មតក្កកម្ម គឺជាបណ្តឹងអាជ្ញាដែលបណ្តឹងអាជ្ញាគឺគ្មានការសម្របសម្រួលឡើយ។ យោងតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម អំពើរំលោភបំពានលើតក្កកម្មគឺជាកម្មវត្ថុនៃបណ្តឹងទៅតុលាការដើម្បីចាត់វិធានកាប្រឆាំងនឹអំពើរំលោភបំពាននោះ ក្នុងករណីដែលរកឃើញថាមានអំពើរំលោភបំពានលើតក្កកម្មកើតមានពិតប្រាកដ នោះទណ្ឌកម្មព្រហ្មទណ្ឌនិងរដ្ឋប្បវេណីនឹងត្រូវយកមកអនុវត្តតានអំណាចឆន្ទានុសិទ្ធិរបស់តុលាការ។ តែបញ្ហានៅត្រង់ថាតើទណ្ឌកម្មព្រហ្មអាចយកមកអនុវត្តបានទេ ប្រសិនបើគ្មានបណ្តឹង? អនុលោមតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម បណ្តឹងប្រឆាំងនឹងការរំលោភបំពានលើតក្កកម្មត្រូវធ្វើឡើងដោយបុគ្គលដែលមានសិទ្ធិស្រប

ច្បាប់លើគក្កកម្មអាចជាម្ចាស់ដើមនៃគក្កកម្ម ឬអាចជាបុគ្គលដែលទទួលសិទ្ធិតាមអាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្សេងទៀត នោះតុលាការនឹងចាត់វិធានការបានតាមការទាមទាររបស់ម្ចាស់បណ្តឹង ហើយឈានទៅដល់ការសម្រេចលើអង្គសេចក្តីបណ្តឹងរំលោភសិទ្ធិលើអាជីវកម្មគក្កកម្ម។[71] សរុបសេចក្តីមកវិញ ចំពោះទណ្ឌកម្មព្រហ្មទណ្ឌគឺកើតឡើងដោយបណ្តឹងរបស់ម្ចាស់សិទ្ធិនេះមានន័យថា វាជាចំណាត់ការរបស់ម្ចាស់សិទ្ធិក្នុងការជ្រើសរើសវិធានការតាមផ្លូវតុលាការ។ ក្រៅពីចំណាត់ការតាមនីតិវិធីតុលាការ វិធានក្រៅប្រព័ន្ធតុលាការក៏ជាជម្រើសមួយមានប្រសិទ្ធិភាពដែរដែលវិធាននេះស្តែងឡើងតាមសកម្មភាពមួយចំនួនដូចជា ការចរចារ សន្ធានកម្ម និងមជ្ឈត្តការ ហើយឈានទៅរកការបង្កើតកិច្ចព្រមព្រៀងថ្មីជាមួយគ្នា។

តើមានកត្តាណាខ្លះដែលជាមូលហេតុជ្រើសរើសយកនូវវិធានក្រៅប្រព័ន្ធតុលាការមកអនុវត្ត ចំពោះអំពើនៃការរំលោភបំពានលើសិទ្ធិអាជីវកម្មគក្កកម្ម? ក្នុងកិច្ចការពាណិជ្ជកម្មបណ្តឹងទៅស្ថាប័នតុលាការអាចធ្វើឲ្យប៉ះពាល់ដល់កិត្តិយសក្រុមហ៊ុនក៏ដូចជាសេដ្ឋកិច្ចរបស់ក្រុមហ៊ុនផង មិនតែប៉ុណ្ណោះតាមរយៈវិធាននេះគឺមិនផ្តល់ឲ្យមានភាគីចាញ់ឬឈ្នះឡើយ។ ភាគីទាំងពីរធ្វើការចរចារសម្រុះសម្រួលគ្នាដែលនឹងបង្កើតឲ្យមានជាកិច្ចសន្យាព្រមព្រៀងមិនធ្វើការប្រកួតប្រជែងគ្នា ឬបែងចែកតំបន់អាជីវកម្មជាដើម។

**ខ. ដំណោះស្រាយតាមប្រព័ន្ធតុលាការ**

ទាក់ទងនឹងយន្តការ ដំណោះស្រាយវិវាទចំពោះការរំលោភសិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រគក្កកម្មនេះ តាមច្បាប់ស្តីពីប្រកាសនីយបត្រគក្កកម្មគ្រាន់តែបានបញ្ញត្តិអំពីយន្តការតុលាការតែមួយមុខគត់។ តាមរយៈនេះតុលាការសម្រេចឲ្យមានយន្តការជាបណ្តោះអាសន្ននៅមុនពេលរកឃើញអំពីអត្ថិភាពនៃការរំលោភសិទ្ធិ ឬអាចជាស្ថាពរតែម្តងបន្ទាប់ពីរកឃើញការរំលោភសិទ្ធិយ៉ាងពិតប្រាកដ។ ចំពោះយន្តការបណ្តោះអាសន្ន តុលាការមានសមត្ថកិច្ចអាចនឹងចេញសេចក្តីសម្រេចបណ្តោះអាសន្នដើម្បីទប់ស្កាត់ការរំលោភសិទ្ធិ ឬការរំលោភដែលប្រុងនឹងកើតមាននោះបាន។ ប៉ុន្តែអ្វីដែលជាបញ្ហាចោទចំពោះខ្លឹមសារនៃមាត្រា១២៦នេះគឺ ទី១ យន្តការបណ្តោះអាសន្នហាក់អាចធ្វើទៅបាន លុះត្រាតែម្ចាស់ប្រកាសនីយបត្រគក្កកម្មបានបដិសេធក្នុងការប្តឹងប្រឆាំងការក្លែងបន្លំ បន្ទាប់ពីមានសំណើពីម្ចាស់ដែលទទួលបានសិទ្ធិ ឬអ្នកទទួលអាជ្ញាប័ណ្ណរួចហើយ។ ទី២ តាមរយៈយន្តការនេះថ្វីត្បិតតែជាយន្តការបណ្តោះអាសន្ន ប៉ុន្តែតុលាការអាចសម្រេចឲ្យមានការសងការខូចខាត ដែលក្នុងករណីនេះនឹងនាំឲ្យផ្ទុយនឹងគោលការណ៍យុត្តិធម៌ក្នុងការដាក់ទណ្ឌកម្មតាមរយៈដាក់សវនកាដ៏ត្រឹមត្រូវមួយមិនខាន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយមាត្រានេះហាក់បានបើកផ្លូវឲ្យចៅក្រមអាចយកវិធានគតិយុត្តិផ្សេងទៀត ក្រៅអំពីច្បាប់ស្តីពីប្រកាសនីយបត្រគក្កកម្មមកប្រើចំពោះការរំលោភសិទ្ធិនេះដូចជាច្បាប់ស្តីពីអ្នកនិពន្ធក៏ដូចជាច្បាប់ស្តីពីម៉ាក់ជាដើម ដែលក្នុងនោះរួមមានទាំងយន្តការរដ្ឋបាលដូចជាយន្តការតាមមាត់ច្រកព្រំដែនជាដើម។

[71] មាត្រា១២៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រគក្កកម្ម ឆ្នាំ២០០៣

ដោយឡែក ក្នុងករណីដែលការរំលោភសិទ្ធិបានកំណត់ច្បាស់ហើយតុលាការត្រូវកំណត់អំពីទោសទណ្ឌ ដល់បុគ្គលដែលបានបប្រព្រឹត្តអំពើរំលោភសិទ្ធិនៃប្រកាសនីយបត្រតក្កកម្មនេះអាចនឹងត្រូវផ្តន្ទាទោស ដោយផាពិន័យ ជាប្រាក់ពី ៥,០០០,០០០ (ប្រាំលានរៀល) ដល់២០,០០០,០០០ (ម្ភៃលានរៀល) ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគាពី១ (មួយ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើតែម្តង។ កាលបើមានករណីមិនរាងចាលក្នុងរយៈពេល ប្រាំឆ្នាំ គិតចាប់ពីពេលត្រូវបានផ្តន្ទទោសនោះមកនឹងត្រូវផ្តន្ទាទោសទ្វេដង (ទុកជាស្ថានទម្ងន់ទោស)។ លើសពីនេះ ទៅទៀត តុលាការអាចសម្រេចបញ្ជាឲ្យធ្វើការរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ ឬឲ្យបំផ្លាញចោលនូវទំនិញនិងឧបករណ៍ សម្ភារៈដែលយកមកប្រើប្រាស់ក្នុងការប្រព្រឹត្តិអំពើរំលោភទៀតផង។

## ៣.២. អាជ្ញាប័ណ្ណនៃប្រកាសសនីយបត្រតក្កកម្មក្រោមច្បាប់អន្តរជាតិ

ប្រកាសនីយបត្រតក្កកម្មបានកំណត់និយមន័យថា ជាផលិតផលឬដំណើរការផលិតក្នុងគ្រប់វិស័យបច្ចេក ទេសឱ្យតែតក្កកម្មនោះថ្មីស្រឡាង មានជំហានរកឃើញថ្មី និងអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម។ សិទ្ធិ ប្រកាសនីយបត្រតក្កកម្មអាចផ្តល់ឱ្យដោយគ្មានការរើសអើង ចំពោះទីកន្លែងតក្កកម្មចំពោះវិស័យបច្ចេកទេសហើយ ទោះបីជាផលិតផលដែលនាំចូល ឬផលិតផលក្នុងស្រុកក៏ដោយ។[72]

ក្នុងលក្ខខណ្ឌដែលម្ចាស់តក្កកម្មចង់ដាក់ពាក្យសុំប្រកាសនីបត្រតក្កកម្ម អ្នកដាក់ពាក្យសុំប្រកាសនីយបត្រ តក្កកម្មបង្ហាញ អំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និងពេញលេញដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុង ជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ និងអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំចង្អុលបង្ហាញពីនីតិវិធីដែលល្អជាងគេដើម្បី អនុវត្តតក្កកម្មដែលបានដឹងដោយតក្កករនៅពេលចុះកាលបរិច្ឆេទសុំចុះបញ្ជី ឬនៅពេលចុះកាលបរិច្ឆេទអាទិភាពនៃ សំណុំលិខិតស្នើសុំ ក្នុងករណីអាទិភាពត្រូវបានអះអាង។

យ៉ាងណាមិញក្នុងករណីដែលម្ចាស់តក្កកម្មជាជនបរទេសអាចតម្រូវឱ្យអ្នកដាក់ពាក្យប្រកាសនីយបត្រត្តក្កម្ម ផ្តល់ពត៌មានដែលទាក់ទងនឹងការដាក់ និងការផ្តល់សំណុំលិខិតស្នើសុំបរទេស។

### ៣.២.១. ប្រភេទនៃអាជ្ញាប័ណ្ណប្រកាសនីយបត្រតក្កកម្ម

#### ៣.២.១.១. ការធ្វើអាជីវកម្មលើប្រកាសសនីយបត្រតក្កកម្មដោយម្ចាស់

ដោយបន្ទាប់ពីម្ចាស់តក្កកម្មធ្វើការស្នើសុំប្រកាសនីយបត្រតក្កកម្ម ម្ចាស់អាជីវកម្មមានសិទ្ធិផ្តាច់មុខក្នុងការ ធ្វើអាជីវកម្មលើតក្កកម្មនោះ។ ដោយម្ចាស់តក្កកម្មអាចធ្វើការសម្រេចបង្កើតកិច្ចព្រមព្រៀងរបស់ខ្លួនតាមរយៈសំណើ និងស្ទីការដើម្បីបង្កើតឱ្យកិច្ចព្រមព្រៀងរបស់ខ្លួនមានសុពលភាព។

[72] មាត្រា ២៧(១) នៃ Trip Agreement.

ម្ចាស់តក្កកម្មអាចសម្រេចក្នុងការកំណត់អំពីសិទ្ធិ និងការកាតព្វកិច្ចរបស់អ្នកទទួលសិទ្ធិក្នុងធ្វើអាជីវកម្មបន្ត ប៉ុន្តែយ៉ាងណាមិញម្ចាស់តក្កកម្មត្រូវធានាខ្លួនមិនប្រើប្រាស់សិទ្ធិផ្តាច់មុខរបស់ខ្លួនដើម្បីរំលោភបំពានសិទ្ធិអ្នកដទៃ ឬប្រើប្រាស់ក្នុងគោលបំណងនៃការប្រកួតប្រជែងមិនស្មោះត្រង់។

ខាងក្រោមនេះគឺករណីសិក្សា ដែលបានកើតមាននៅសហរដ្ឋអាមេរិកដែលម្ចាស់តក្កកម្មបានប្រើប្រាស់សិទ្ធិរបស់ខ្លួនជាម្ចាស់តក្កកម្មហួសហេតុទើបរដ្ឋាភិបាលអាមេរិក បានធ្វើការប្តឹងទៅលើម្ចាស់តក្កកម្មអំពីអំពើដែលប្រឆាំងនឹងសេចក្តីទុកចិត្ត។ ដោយនៅខាងក្រោមនេះមានបែងចែកជា [១]អង្គហេតុ [២]ចំណោទបញ្ហាគតិយុត្តិ [៣]ការបកស្រាយ និងចុងក្រោយគឺ [៤]សេចក្តីសម្រេច។[73]

១. អង្គហេតុ

ក្រុមហ៊ុន Imperial Chemical Industries Ltd (ICI) និង ក្រុមហ៊ុន Glaxo Ltd គឺជាក្រុមហ៊ុនឱសថស្ថានដែលបានចុះបញ្ជីនៅអង់គ្លេសមាន តក្កកម្មជាច្រើនដែលពាក់ព័ន្ធនឹងថ្នាំក្នុងទម្រង់ជាគ្រាប់ដែលទប់ស្កាត់ការកកើតនៃផ្សិតដែលមានឈ្មោះថា Griseofulvin។ ក្រុមហ៊ុន Glaxo មានតក្កកម្មទៅលើការផលិតថ្នាំជាទម្រង់ជាម្សៅ។ ក្រុមហ៊ុនទាំងពីរបានផ្ទេរសិទ្ធិតំណាងសម្រាប់ថ្នាំដែលមានទម្រង់ជាថ្នាំគ្រាប់និងថ្នាំម្សៅជាប្រកាសនីយបត្រតក្កកម្ម និងបានលក់សិទ្ធិបន្តទៅឱ្យ ក្រុមហ៊ុននៅសហរដ្ឋអាមេរិកធ្វើអាជីវកម្មបន្តលើតក្កកម្មនោះ។ កិច្ចព្រមព្រៀងស្តីពីសិទ្ធិតំណាងនេះបានភ្ជាប់ជាមួយកថាខ័ណ្ឌមួយដែលបានសរបញ្ជាក់ថាមិនឱ្យមានការលក់ និងការលក់បន្តថ្នាំដែលជាប្រភេទជាម្សៅនិងលក់សិទ្ធិបន្តទៅតតិយជនដោយគ្មានការអនុញ្ញាតពីម្ចាស់តក្កកម្ម។

សហរដ្ឋអាមេរិកបានធ្វើការប្តឹងបណ្តឹងរដ្ឋប្បវេណី អំពីការប្រឆាំងនឹងសេចក្តីទុកចិត្តទៅតុលាការថ្នាក់ស្រុកដោយចង្អុលបង្ហាញថានៅចំណុចដែលពាក់ព័ន្ធការលក់សិទ្ធិបន្ត និងកិច្ចព្រមព្រៀងស្តីសិទ្ធិតំណាងបានបំពានផ្នែកទី១ នៃច្បាប់ស្តីពីសកម្មភាពដែលប្រឆាំងនឹងសេចក្តីទុកចិត្ត។ តុលាការថ្នាក់ស្រុកបានធ្វើការលើកឡើងថាការលក់ថ្នាំប្រភេទម្សៅបាននេះបានកម្រិតសេរីភាពរបស់អ្នកទទួលសិទ្ធិបន្តដែលវាបានផ្ទុយពីផ្នែកទី១ នៃច្បាប់ស្តីពីសកម្មភាពដែលប្រឆាំងនឹងសេចក្តីទុកចិត្ត ប៉ុន្តែបានធ្វើការបដិសេធអំពីការស្នើសុំរបស់រដ្ឋាភិបាលសម្រាប់ការលក់ផ្តាច់មុខនៃថ្នាំប្រភេទម្សៅដោយផ្តល់ទៅវិញនូវផលចំណេញដែលសមហេតុផលមួយទៅម្ចាស់តក្កកម្ម។ តុលាការថ្នាក់ស្រុកដដែលបានលើកឡើងទៀតថាបណ្តឹងដែលពាក់ព័ន្ធនឹងការប្រឆាំងនឹងសេចក្តីទុកចិត្ត ដែលមានទាក់ទងសុពលភាពរបស់តក្កកម្មនឹងអាចធ្វើការប្រឆាំងបានឡើយលុះត្រាតែតក្កកម្មនោះមិនបានយកមកប្រើប្រាស់សម្រាប់ការការពារ។ ក្រុមហ៊ុន ICI បានដាក់សំបុត្រភស្តុតាងដើម្បីធ្វើការបដិសេធថាខ្លួនមិនបានធ្វើការប្រើប្រាស់តក្កកម្មរបស់ខ្លួនសម្រាប់ការ

[73] United States Vs. Glaxo Group LTD សេចក្តីសម្រេចដោយតុលាការជាន់ខ្ពស់របស់សហរដ្ឋអាមេរិកដែលចុះថ្ងៃទី ២២ មករា ១៩៧៣
https://www.supremecourt.gov/pdfs/transcripts/1972/71-666_11-09-1972.pdf
https://supreme.justia.com/cases/federal/us/410/52/

ការពារឡើយ។ រដ្ឋាភិបាលទទួលការចាត់បង់ដោយសារការសម្រេចនេះបានធ្វើការដាក់ពាក្យបណ្ដឹងទៅតុលាជាន់ខ្ពស់នៃសហរដ្ឋអាមេរិក។

២. ចំណោទបញ្ហាគតិយុត្តិ

នៅក្នុងករណីសិក្សាមានបញ្ហាគតិយុត្តិចំនួនពីរដែលបានលេចចេញ៖ [១] តើរដ្ឋាភិបាលអាមេរិកអាចធ្វើការប្រឆាំងនឹងសុពលភាពតក្កកម្មដែលបានធ្វើការកម្រិតសេរីភាពក្នុងការធ្វើអាជីវកម្មដោយខុសច្បាប់ នៅពេលដែលចុងចម្លើយមិនបានធ្វើការប្រើប្រាស់តក្កកម្មសម្រាប់ការការពារលើសកម្មភាពរបស់ខ្លួនបានដែរឬទេ [២] តើតុលាការថ្នាក់ស្រុកពិតជាមានកំហុសពិតមែនឬទេ ដែលមិនផ្ដល់សិទ្ធិឱ្យរដ្ឋាភិបាលធ្វើអាជីវកម្មលើតក្កកម្មតាមការស្នើសុំរបស់រដ្ឋាភិបាល?

៣. ការបកស្រាយ

សម្រាប់ចំណោទបញ្ហាគតិយុត្តិទី១ តុលាការជាន់ខ្ពស់បានធ្វើការសម្រេចដោយផ្អែកទៅលើយុត្តិសាស្ត្រតុលាការដែលធ្លាប់បានសម្រេចពីមុនមក (Edward Katzinger Co vs. Chicago Metallic Manufacturing Co) ដោយធ្វើការបញ្ជាក់ថាម្ចាស់តក្កកម្មមិនអាចប្រើប្រាស់សិទ្ធិផ្ដាច់មុខដែលខ្លួនមានក្នុងតក្កកម្មទៅរឹតបណ្ដឹងសិទ្ធិរបស់អ្នកទទួលទិញអាជ្ញាប័ណ្ណបន្តនោះទេ។

សម្រាប់ចំណោទបញ្ហាគតិយុត្តិទី២ តុលាការជាន់ខ្ពស់បានរកឃើញថ្នាំដែលជាប្រភេទម្សៅបានជំរុញឱ្យមានការប្រកួតប្រជែងទីផ្សារយ៉ាងខ្លាំងក្លា ដោយសារកត្តានេះហើយបានជាចុងចម្លើយបានកម្រឹតការធ្វើអាជីវកម្មលើតក្កកម្មរបស់ខ្លួន។ តុលាការជាន់ខ្ពស់ក៏បានធ្វើការបង្ហាញការយល់ឃើញរបស់ខ្លួនថានៅពេលដែលក្រុមហ៊ុនថ្នាំផ្សេងបាននាំចូលទីផ្សារវាបានធ្វើឱ្យថ្នាំតម្លៃដុំធ្លាក់ចុះ ហើយវានឹងក្លាយជាអង្គហេតុមួយដែលអាចនឹងបង្ខំឱ្យចុងចម្លើយត្រូវលក់ថ្នាំរបស់ខ្លួនក្នុងតម្លៃថោក។ ដោយសារកត្តានោះហើយតុលាការជាន់ខ្ពស់បានរកឃើញថា លុះត្រាតែមានក្រុមហ៊ុនផ្សេងបានធ្វើការផលិតថ្នាំ Griseofulvin ដែលនេះវាអាស្រ័យលើការសម្រេចចិត្តរបស់ចុងចម្លើយក្នុងការលក់សិទ្ធិអាជ្ញាប័ណ្ណរបស់ខ្លួនដែលវាគឺបំពានក្នុងការប្រើប្រាស់សិទ្ធិផ្ដាច់មុខរបស់ខ្លួន។

៤. សេចក្ដីសម្រេច

តុលាការជាន់ខ្ពស់នៃសហរដ្ឋអាមេរិក បានធ្វើការសម្រេចដោយឱ្យរដ្ឋាភិបាលអាមេរិកមានសិទ្ធិក្នុងការធ្វើអាជីវកម្មលើថ្នាំ Griseofulvin។

### ៣.២.១.២. ការធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬបុគ្គលដែលទទួលបានការអនុញ្ញាត

**ក. ការធ្វើអាជីវកម្មដោយរដ្ឋាភិបាល**

យ៉ាងណាមិញ ទោះជាម្ចាស់អាជីវកម្មមានសិទ្ធិផ្តាច់មុខទៅលើតក្កកម្មរបស់ខ្លួនក៏ដោយក៏ត្រូវមានករណីលើលែងដែលជាចាំបាច់ជាពិសេសនៅពេលដែលតក្កកម្មបានក្លាយទៅជាកម្មវត្ថុនៃសេចក្តីត្រូវដែល យើងអាចហៅម្យ៉ាងទៀតថាដើម្បីប្រយោជន៍សាធារណៈ ចំណែកឯករណីលើកលែងក៏មិនបានបណ្តាលឱ្យមានការប៉ះពាល់មិនសមហេតុផលដល់ប្រយោជន៍ស្របច្បាប់របស់ម្ចាស់តក្កកម្មផងដែរ។

រដ្ឋាភិបាលទៀតសោធអាចធ្វើអាជីវកម្មលើប្រកាសនីយបត្រតក្កកម្មនោះបានកាលណា តក្កកម្មនោះគឺជាសេចក្តីត្រូវការយ៉ាងចាំបាច់ និងក្នុងករណីប្រទេសជាតិមានភាពអាសន្ន ឬកាលៈទេសៈដទៃទៀតដែលកើតឡើងជាបន្ទាន់បំផុតៗ ឬក្នុងករណីនៃការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម។

ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើក្នុងករណីនៃការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈជាពាណិជ្ជកម្មដែលរដ្ឋាភិបាល ឬអ្នកចុះកិច្ចសន្យាដោយគ្មានការស្រាវជ្រាវប្រកាសនីយបត្រតក្កកម្ម បានដឹង ឬមានមូលដ្ឋានបង្ហាញថាបានដឹងថាប្រកាសនីយបត្រតក្កកម្មដែលមានសុពលភាពកំពុងប្រើប្រាស់ដោយ ឬនឹងប្រើប្រាស់ដោយឬសម្រាប់រដ្ឋាភិបាល ម្ចាស់សិទ្ធិត្រូវបានជូនដំណឹងភ្លាម។[74]

### ខ. ការអនុញ្ញាតឱ្យតតិយធ្វើអាជីវកម្មលើតក្កកម្មដោយរដ្ឋាភិបាល

ក្នុងករណីការអនុញ្ញាតឱ្យតតិយធ្វើអាជីវកម្មលើតក្កកម្មដោយរដ្ឋាភិបាល កាលណាតក្កកម្មនោះមានតម្រូវការប្រើប្រាស់ខ្ពស់សម្រាប់សាធារណៈជន និងមុនមានអនុញ្ញាតក្នុងការប្រើប្រាស់អ្នកស្នើសុំប្រើប្រាស់បានព្យាយាមសុំការអនុញ្ញាតពីម្ចាស់សិទ្ធិលើបែបបទនិងលក្ខខណ្ឌពាណិជ្ជកម្មសមរម្យ ហើយការព្យាយាមមិនបានសម្រេចក្នុងពេលវេលាដែលសមរម្យ។[75]

ដើម្បីជាការងាយស្រួលក្នុងការយល់ ឱ្យបានស៊ីជម្រៅនូវអ្វីដែលមានចែងក្នុងច្បាប់យើងមកមើលអ្វីដែលមានអនុវត្ត។ ហើយខាងក្រោមនេះគឺជាករណីសិក្សាដែលបានកើតមានក្នុងប្រទេសឥណ្ឌាដែលរដ្ឋាភិបាលបានផ្តល់សិទ្ធិក្នុងការធ្វើអាជីវកម្មទៅតតិយជនដែលគាត់បានធ្វើការស្នើសុំទៅរដ្ឋាភិបាល។[76] ក្នុងករណីសិក្សានេះបានបែងចែកជា [១]អង្គហេតុ [២]ចំណោទបញ្ហាគតិយុត្តិ [៣]ការបកស្រាយ និងចុងក្រោយគឺ [៤]សេចក្តីសម្រេច។

១. អង្គហេតុ

Sorafenib គឺជា Pharmaceutical Compound សម្រាប់ព្យាបាលជម្ងឺមហារីកថ្លើមនិងតម្រង់នោមដែលបានផលិតដោយក្រុមហ៊ុន Bayer របស់ប្រទេសអាល្លឺម៉ង់ដែលដំណើរការរកស៊ីនៅប្រទេសឥណ្ឌា Pharmaceutical

---

[74] មាត្រា ៣១ (ខ) នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

[75] មាត្រា ៣១ (ខ) នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

[76] ករណីសិក្សា Bayer Corporation vs. Union of India and Others (Bayer v. Natco) សេចក្តីសម្រេចចុះនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៣ https://spicyip.com/wp-content/uploads/2018/02/Natco-v.-Bayer-INTELLECTUAL-PROPERTY-APPELLATE-BOARD-CHENNAI-%E2%80%93-4th-March-2013.pdf.

Compound បានចរាចរណ៍លក់ទូទាំងពិភពលោក។ ក្រុមហ៊ុនក្នុងស្រុកឈ្មោះ CIPLA បានចាប់ផ្តើមផលិត និងចរាចរណ៍ដែលផលិតតាម Sorafenib កាលពីឆ្នាំ២០០៨ និងដាក់ឈ្មោះថា Soranib ។ ក្រុមហ៊ុន Bayer បានដាក់ពាក្យបណ្តឹងប្តឹង CIPLA ពីការរំលោភសិទ្ធិកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងតក្កកម្មទៅតុលាការឥណ្ឌា។

ក្នុងពេលនោះ Sorafenib របស់ក្រុមហ៊ុនអាល្លឺម៉ង់មានតម្លៃដល់USD ៥២៨០ ក្នុងមួយខែ ប៉ុន្តែ CIPLA លក់ត្រឹមតែ USD ៥២៥ ក្នុងបរិមាណដូចគ្នា។ កំឡុងពេលនៃជម្លោះរវាង CIPLA និង Bayer មានក្រុមហ៊ុនឈ្មោះ Natco បានដាក់ស្នើសុំធ្វើអាជីវកម្មលើថ្នាំ Sorafenib ពីអាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងប្រកាសសនីយបត្រតក្កកម្មរបស់ប្រទេសឥណ្ឌា។ Natco បានស្នើសុំធ្វើអាជីវកម្មលើថ្នាំ Sorafenib ដោយផ្អែកលើផ្នែកទី៨៤ កថាខណ្ឌ១ នៃច្បាប់ស្តីពីសកម្មភាពលើប្រកាសសនីយបត្រតក្កកម្មរបស់ប្រទេសឥណ្ឌា១៩៧០ ដែលបានធ្វើវិសោធនកម្មកាលពី ២០០៥។

ក្នុងផ្នែកទី៨៤ កថាខណ្ឌទី១នៃច្បាប់ស្តីពីសកម្មភាព លើប្រកាសសនីយបត្រតក្កកម្មរបស់ប្រទេសឥណ្ឌា ដែលបានធ្វើវិសោធនកម្មដោយបានចែងថាក្នុងរយៈពេល៣ឆ្នាំបន្ទាប់ពីថ្ងៃ បានផ្តល់ប្រកាសសនីយបត្រតក្កកម្មការស្នើសុំធ្វើអាជីវកម្មទៅលើតក្កកម្មនោះអាចធ្វើទៅបានកាលណាស្ថិតក្នុងប្រការណាមួយនៃផ្នែកនេះ៖

- សាធារណៈជនមិនទទួលបានផលិតផលពីតក្កកម្មនោះក្នុងលក្ខខណ្ឌសមរម្យមួយ
- សាធារណៈជនមិនអាចប្រើប្រាស់ផលិតផលពីតក្កកម្មនោះក្នុងព្រោះតម្លៃ
- ផលិតផលពីតក្កកម្មមិនបានផលិតក្នុងដែនដីប្រទេសឥណ្ឌា

អាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងប្រកាសសនីយបត្រតក្កកម្ម របស់ប្រទេសឥណ្ឌាបានសម្រេចផ្តល់សិទ្ធិធ្វើអាជីវកម្មជូនក្រុមហ៊ុន Natco ដោយវាត្រឹមត្រូវតាមផ្នែកទី៨៤នៃច្បាប់ស្តីពីសកម្មភាពលើប្រកាសសនីយបត្រតក្កកម្មរបស់ប្រទេសឥណ្ឌា។ អាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងប្រកាសសនីយបត្រតក្កកម្មរបស់ប្រទេសឥណ្ឌាបានចេញលិខិតដែលចែងពីខនិងលក្ខខណ្ឌនៃការអនុញ្ញាតឱ្យធ្វើអាជីវកម្មដោយរដ្ឋាភិបាល និងផ្តល់តម្លៃតមស្នងជូន ៦ភាគរយដែលបានមកពីផលចំណេញជូន Bayer។ Bayer ក៏បានដាក់ពាក្យបណ្តឹងជំទាស់ចំពោះការសម្រេចចិត្តនេះទៅក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញា។

២. ចំណោទបញ្ហាគតិយុត្តិ

ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាបានបញ្ជាក់ថាការស្នើសុំធ្វើអាជីវកម្មលើប្រកាសសនីយបត្រតក្កកម្មដោយរដ្ឋាភិបាលអាស្រ័យទៅតាមករណីខុសៗគ្នា។ យ៉ាងណាមិញការសម្រេចចិត្តរបស់ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាដោយផ្អែកផលប្រយោជន៍របស់សាធារណៈជាធំ ចៀសជាងគិតពីប្រយោជន៍ឯកជនរបស់បុគ្គល។

ម្យ៉ាងវិញទៀតមុនពេលដែល Natco ធ្វើការស្នើសុំធ្វើអាជីវកម្មលើប្រកាសសនីយបត្រតក្កកម្មដោយរដ្ឋាភិបាល Natco ក៏បានទាក់ទងទៅ Bayer ដើម្បីសុំទិញសិទ្ធិក្នុងការធ្វើអាជីវកម្មលើតក្កកម្ម ប៉ុន្តែខាង Bayer បានបដិសេធ។ នេះបានបញ្ជាក់ថា Natco បានអនុវត្តតាមផ្នែក ៨៦(៦)(ក) ដែលតម្រូវឱ្យអ្នកស្នើធ្វើការស្នើសុំធ្វើអាជីវកម្មពីម្ចាស់តក្កករជាមុនសិនមុនពេលធ្វើការស្នើសុំធ្វើអាជីវកម្មលើប្រកាសសនីយបត្រតក្កកម្មដោយ រដ្ឋាភិបាលបន្ទាប់ពីម្ចាស់តក្កកម្មបានធ្វើការបដិសេធក្នុងការស្នើនោះ។

ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាទទួលស្គាល់ថាការអនុញ្ញាតឱ្យធ្វើអាជីវកម្មប្រកាសនីយបត្រតក្កកម្មដោយរដ្ឋាភិបាលអាចធ្វើទៅបានកាលណាត្រឹមត្រូវតាម ប្រការណាមួយនៃផ្នែក៨៤នៃច្បាប់ស្តីពីសកម្មភាពលើប្រកាសសនីយបត្រតក្កកម្មរបស់ប្រទេសឥណ្ឌា។

៣. ការបកស្រាយ

មូលហេតុដែលក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាទទួលស្គាល់ថា ការអនុញ្ញាតឱ្យធ្វើអាជីវកម្មលើប្រកាសសនីយបត្រតក្កកម្មដោយរដ្ឋាភិបាលអាចធ្វើទៅបានព្រោះ៖

- *លក្ខខណ្ឌសមរម្យសម្រាប់សាធារណៈជន*

ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញា រកឃើញថាតក្កករមិនទាន់បានផ្តល់ជូនលក្ខខណ្ឌដ៏សមរម្យសម្រាប់សាធារណៈជន។ ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាបានបញ្ជាក់ថាតក្កករមិនបានផ្តល់ជូនលក្ខខណ្ឌដ៏សមរម្យសម្រាប់សាធារណៈជនដោយសារកត្តាដូចជា៖ ចំណុចទីមួយគ្មានការចរាចរណ៍តក្កកម្ម ចំណុចទីពីរតម្លៃមិនអាចទទួលយកបាន ចំណុចទី៣ការចរាចរណ៍តក្កកម្មមិនស្ថិតនៅលើ Commercial Scale។ នៅក្នុងករណីនេះដោយសារអង្គហេតុមិនសមស្របតាមធាតុផ្សំដែលមានចែងក្នុងផ្នែក ៨៤ (១) ទាំងចំណុច ក ខ និងគ ព្រោះ ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញារកឃើញថាតម្លៃនៃថ្នាំមានតម្លៃខ្ពស់ពេកដែលសាធារណៈជនភាគច្រើនមិនអាចធ្វើការជាវបាន។ ម្យ៉ាងវិញទៀត នៅពេលដែលតម្រូវការមិនសមស្របទៅនឹងការផ្គត់ផ្គង់វាជាអង្គហេតុដែលបញ្ជាក់បានថាសាធារណៈមិនបានទទួលបានការប្រើប្រាស់លើថ្នាំនោះ។

- *តម្លៃសមរម្យ*

ចំណោទបញ្ហាគតិយុត្តិដែលសំខាន់សម្រាប់អង្គហេតុទាំងមូលគឺពាក់ព័ន្ធនឹង ទៅការសម្រេចចិត្តក្នុងចំនុចនេះ។ ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាយល់ថាបញ្ហាគតិយុត្តិដែលពាក់ព័ន្ធនឹង តម្លៃសមរម្យ គឺមានភាពសំខាន់ប្រសិនបើថ្នាំគឺជាសេចក្តីការរបស់សាធារណៈជន ដើម្បីធានាសាធារណៈគ្រប់ៗអាចទទួលយកបាន។ ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញា ក៏យល់ស្របជាមួយអាជ្ញាធរគ្រប់គ្រងប្រកាសសនីយបត្រតក្កកម្មចំពោះចំណុចពាក់ព័ន្ធនឹងតម្លៃរបស់ថ្នាំ ដែលវាមានតម្លៃខ្ពស់ពេកដែលសាធារណៈជនមួយចំនួនធំមិនអាចទទួលយកបាន។ ដូចនេះហើយបានបញ្ជាក់ឱ្យឃើញថាថ្នាំមានតម្លៃមិនសមរម្យ។

- *ការផលិតនៃតក្កកម្ម*

ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញា មិនបានបញ្ជាក់ច្បាស់លាស់ថាតើការផលិតនៃតក្កកម្មចង់សំដៅដល់ការនាំចូល ឬផលិតផ្ទាល់នៅប្រទេសឥណ្ឌា ប៉ុន្តែបានរកឃើញថាតក្កកម្មមិនបានផលិតនៅក្នុងប្រទេសឥណ្ឌានោះទេ។ ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាយល់ស្របថាថ្នាំទាំងនោះបាននាំចូលមកចៀសជាងផលិតនៅក្នុងប្រទេសហើយការនាំចូលនេះគឺដើម្បីចរាចរណ៍លក់នៅក្នុងប្រទេសឥណ្ឌា។ យ៉ាងណាមិញខាងក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញា បានលើកឡើងថាការនាំចូលបែបនេះដើម្បីក្នុងគោលដៅពាណិជ្ជកម្មនិងគួរតែលក់ក្នុងតម្លៃដែលសមរម្យ។ ដូចនេះខាងក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាបានសម្រេចថាថ្នាំនោះមិនអាចនិយាយថាផលិតនៅក្នុងប្រទេសឡើយ។

- *ប្រយោជន៍សាធារណៈ*

ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញា បានលើកឡើងថាត្រូវទុកប្រយោជន៍សាធារណៈជាការសំខាន់ និងការស្នើសុំរបស់ Natco ដើម្បីធ្វើយ៉ាងណាឱ្យថ្នាំនោះបានទៅសាធារណៈជនគ្រប់ៗគ្នាគឺមានហេតុផលគ្រប់គ្រាន់សម្រាប់ Natco គួរទទួលបានសិទ្ធិក្នុងការធ្វើអាជីវកម្មលើតក្កកម្មដែលអនុញ្ញាតដោយរដ្ឋាភិបាល។

ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាបានបន្ថែមទៀតថាធាតុផ្សំដែលមានចែងក្នុងផ្នែក ៨៤ (៦) មិនត្រូវក្លាយជាមូលហេតុដែលច្រានចោលការស្នើសុំរបស់ភាគីម្ខាងទៀត ដែលមានបំណងក្នុងការធ្វើយ៉ាងណាឱ្យអ្វីដែលបានរកឃើញអាចប្រើជាប្រយោជន៍ដល់សាធារណៈជន។ ក្នុងច្បាប់បានចែងយ៉ាងច្បាស់ថាតក្កករត្រូវផ្តល់ជូននូវព័ត៌មានសំខាន់ៗពាក់ព័ន្ធតក្កកម្ម ដែលនេះសបញ្ជាក់ថាចំណុចនេះគឺផ្តោតយ៉ាងសំខាន់ទៅលើផលប្រយោជន៍សាធារណៈចៀសជាងប្រយោជន៍របស់បុគ្គលមិនថាម្ចាស់តក្កកម្មឬអ្នកស្នើសុំធ្វើអាជីវកម្មលើតក្កកម្ម ដែលអនុញ្ញាតដោយរដ្ឋាភិបាល។ ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាលើកឡើងទៀតថាតក្កកម្មបានផ្តល់ឱ្យសម្រាប់ប្រយោជន៍សាធារណៈដូចនេះមានន័យថា តក្កកម្មគួរតែអាចទទួលបានដោយងាយស្រួលនិងចំណាយក្នុងតម្លៃដែលសមរម្យ។

៤. សេចក្តីសម្រេច

ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញា សុំធ្វើការបដិសេធក្នុងការលុកដៃក្នុងសេចក្តីសម្រេចដែលបានចេញដោយអាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងប្រកាសសនីយបត្រតក្កកម្មទាំងផ្នែក ផ្នែកលក្ខខណ្ឌច្បាប់និងនីតិវិធី។ ក្រុមប្រឹក្សាទទួលពាក្យបណ្តឹងនៃកម្មសិទ្ធិបញ្ញាអនុញ្ញាតក្នុងការបង្កើនតម្លៃតបស្នងដែលខាង Natco ត្រូវផ្តល់ជូន Bayer ចំនួន ៧ ភាគរយពីផលចំណេញដែលរកបាន។

### ៣.២.២. សិទ្ធិដែលទទួលបាន

#### ៣.២.២.១. សិទ្ធិផ្តាច់មុខ

បន្ទាប់ពីបានធ្វើការចុះបញ្ជីនូវប្រកាសនីយបត្រតក្កកម្មរបស់ខ្លួនម្ចាស់អាជីវកម្ម ទទួលបាននូវសិទ្ធិសំខាន់ជាច្រើនដើម្បីជាការតបស្នងនូវតម្លៃពលកម្ម គំនិតដែលបានប្រើប្រាស់ក្នុងការបង្កើតតក្កកម្មដែលថ្មីនេះដូចនេះសិទ្ធិទាំងនោះមានដូចជាសិទ្ធិដែលទប់ស្កាត់តតិយជនប្រើប្រាស់តក្កកម្ម ដោយគ្មានការយល់ព្រមពីម្ចាស់តក្កកម្មក្នុងការអនុវត្តសកម្មភាពដូចជាការផលិត ការប្រើប្រាស់ ការផ្គត់ផ្គង់សម្រាប់លក់ ការលក់ ឬការនាំចូលផលិតផលនេះក្នុងគោលបំណងដូចរៀបរាប់ខាងលើ។ ដោយយើងដឹងហើយថាទោះជាតក្កកម្មនៅពេលដែលចុះបញ្ជីត្រូវធ្វើការផ្សព្វផ្សាយជាសារធារណៈនូវរូបមន្តរបស់ខ្លួនក៏ដោយ ប៉ុន្តែគ្មានបុគ្គលណាម្នាក់អាចយកតក្កកម្មដែលបានចុះបញ្ជីមកផលិតបានឡើយហើយនេះគឺជាសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់សិទ្ធិរបស់ម្ចាស់តក្កកម្ម។

ម្យ៉ាងវិញទោះជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្ម ជាដំណើរការផលិតផលគឺម្ចាស់តក្កកម្មទទួលបានសិទ្ធិដែលហាមឃាត់តតិយជនធ្វើការប្រើប្រាស់ដំណើរការផលិតនិងសកម្មភាពដូចជា ការប្រើប្រាស់ ការផ្គត់ផ្គង់សម្រាប់លក់ ការលក់ ឬការនាំចូលក្នុងគោលបំណងដូចបានរៀបរាប់ខាងលើដែលនឹងទទួលបានផលិតផលតាមរយៈដំណើរការផលិតនោះដោយគ្មានការយល់ព្រមពីម្ចាស់។

#### ៣.២.២.២. សិទ្ធិក្នុងការធ្វើអាជីវកម្មលើតក្កកម្ម

ជាពិសេសជាងនេះទៅទៀតសិទ្ធិដែលម្ចាស់ប្រកាសនីយបត្រតក្កកម្ម អាចអនុវត្តទៅបានគឺសិទ្ធិប្រគល់ក្នុងការ ឬផ្ទេរដោយសន្តតិកម្មប្រកាសនីយបត្រតក្កកម្ម និងមានសិទ្ធិចុះកិច្ចសន្យាអាជ្ញាប័ណ្ណ។ ដោយសារម្ចាស់តក្កកម្មមានកម្មសិទ្ធិលើតក្កកម្មដែលបានចុះបញ្ជី នោះដូចគាត់គឺមានសិទ្ធិក្នុងការផ្ទេរកម្មសិទ្ធិលើតក្កកម្មនោះទៅបុគ្គលដទៃបាន ឬអាចឱ្យសិទ្ធិទៅបុគ្គលដទៃធ្វើអាជីវកម្មលើតក្កកម្មនោះដោយផ្តល់មកវិញនូវតម្លៃតបស្នងដែលសមរម្យមួយ។

### ៣.២.៣. ការដោះស្រាយវិវាទ

#### ៣.២.៣.១. វិធីក្នុងការដោះស្រាយវិវាទ

នៅក្នុងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញានិតិវិធិក្នុងការដោះស្រាយវិវាទមានលក្ខណៈទន់ភ្លន់ព្រោះវាទាក់ទងនឹងទំនាក់ទំនងរវាងប្រទេសនឹងប្រទេសដែលជាសមាជិក WTO រាល់វិវាទដែលកើតមានត្រូវដោះស្រាយតាមរយៈអនុស្សរណៈនៃដោះស្រាយវិវាទដើម្បី ធ្វើការប្រឹក្សាយោបល់និងដោះស្រាយជម្លោះ។[77] ដំណោះស្រាយបែបនេះគឺដើម្បីស្វែងរកនូវចំនុចរួមនៃវិវាទ និងអ្វីទៅដែលជាការចង់បានរបស់ភាគីទាំងសងខាង។

[77] មាត្រា ៦៤ (១) នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

ការធ្វើបែបនេះផលដែរគឺដើម្បីធានាទំនាក់ទំនងរបស់ភាគីនៅពេលដែលដោះស្រាយវិវាទរួចរាល់ភាគីនៅតែបន្តទំនាក់ទំនងពាណិជ្ជកម្មជាមួយគ្នាដោយមិនបណ្តោយឱ្យទំនាក់ទំនងរង្គោះរង្គើឡើយ។

**៣.២.៣.២. បន្ទុកនៃភស្តុតាង**

ករណីមានការរំលោភបំពានសិទ្ធិរបស់ម្ចាស់តក្កកម្មដូចមានចែងក្នុងមាត្រា២៨ កថាខណ្ឌ១(ខ) ប្រសិនបើកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មជាដំណើរផលិត អាជ្ញាធរតុលាការមានសិទ្ធិក្នុងការទាមទារឱ្យផលិតករធ្វើកាបកស្រាយការពារថាអ្វីដែលកំពុងនោះមិនបានប្រើប្រាស់វិធីក្នុងការផលិតដូចតក្កកម្មឡើយ។

ដូចនេះម្ចាស់តក្កកម្មត្រូវធ្វើការបង្ហាញថាយ៉ាងហោចណាស់មួយករណី ដូចធាតុណាមួយខាងក្រោមក្នុងករណីដែលផលិតផលនោះដូចនឹងផលិតផលដែលផលិតដោយតក្កកម្មៈ

- ផលិតផលនោះនៅថ្មីដែលបានទទួលដោយតក្កកម្ម
- វាអាចទៅរួចដែលផលិតផលនោះត្រូវបានផលិតដោយវិធីរបស់តក្កកម្ម និងម្ចាស់តក្កកម្មជឿថាមិនអាចរកឃើញថាតក្កកម្មរបស់ខ្លួនត្រូវបានលួចយកទៅប្រើប្រាស់ទោះបានប្រើគ្រប់វិធីក៏ដោយ។

សមាជិកត្រូវទទួលបានសិទ្ធិក្នុងការផ្តល់ភស្តុតាងដើម្បីដាក់បន្ទុក ទៅលើជនដែលបានរំលោភលើតក្កកម្មកាលណាក្នុងករណីដែលលក្ខខណ្ឌខាងលើណាមួយបានបំពេញ។ ក្នុងករណីដើម្បីបញ្ជាក់ពីភស្តុតាងដែលផ្ទុយផលប្រយោជន៍របស់ចុងចម្លើយដើម្បីការពារការសម្ងាត់ផលិតកម្ម និងការសម្ងាត់ពាណិជ្ជកម្មនឹងត្រូវលើកយកមកពិចារណា។

**៣.២.៣.៣. ការលុបចោល/ការបាត់បង់សិទ្ធិ**

បន្ទាប់ពីមានការរកឃើញអំពីការរំលោភបំពានណាមួយ តុលាការអាចធ្វើការត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការនិងអាចធ្វើសេចក្តីសម្រេចណាមួយក្នុងការលុបចោល ឬធ្វើឱ្យបាត់បង់សិទ្ធិប្រកាសនីយបត្រតក្កកម្មណាមួយ។[78] ដូចដែលមានចែងក្នុងមាត្រានៃច្បាប់ តុលាការគឺមានសិទ្ធិក្នុងការសម្រេចក្នុងការស្វែងរកឃើញអំពីការរំលោភបំពានណាមួយ។ ពិសេសនោះក្នុងមាត្រានេះគឺផ្តល់ដែនសមត្ថកិច្ចជូនទៅតុលាការរបស់រដ្ឋដែលជាសមាជិកដើម្បីធ្វើការដោះស្រាយវិវាទរបស់ម្ចាស់អាជីវកម្មដែលមានក្នុងប្រទេសខ្លួនពាក់ព័ន្ធនឹងប្រកាសសនីយបត្រតក្កកម្ម។

**៣.២.៣.៤.ស្ថាប័នមានសមត្ថកិច្ច**

យោងតាមកិច្ចព្រមព្រៀង ស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញាបានកំណត់ថាក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា គឺជាមានតួនាទីត្រួតពិនិត្យពីការអនុវត្តកិច្ចព្រមព្រៀងនេះ និងជាពិសេសការគោរពកាតព្វកិច្ចរបស់សមាជិកទាំងតាមកិច្ចព្រមព្រៀងចៀសវៀងមានការរំលោភបំពានដោយ

[78] មាត្រា៣២ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

សមាជិក។ ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ក៏មានតួនាទីក្នុងការប្រឹក្សាយោបល់ជូនសមាជិក នៅពេលដែលសមាជិកមានបញ្ហាពាក់ព័ន្ធទិដ្ឋភាពពាណិជ្ជកម្មទាំងឡាយដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា។

លើសពីនេះទៅទៀតក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្ម ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាមានតួនាទីក្នុងផ្តល់ជំនួយអំពីនីតិវិធីក្នុងការដោះស្រាយវិវាទជូនសមាជិក។ រាល់ការផ្តល់នូវមតិយោបល់រាល់ពត៌មានទាំងឡាយត្រូវតែជាពត៌មានដែលមានប្រភពច្បាស់លាស់ ដើម្បីធានានូវសុក្រិតភាពនៅពេលសមាជិកយកទៅអនុវត្ត។ ម្យ៉ាងវិញទៀតក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ត្រូវខិតខំបង្កើតបទប្បញ្ញត្តិសមស្របក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកិច្ចប្រជុំទីមួយរបស់ខ្លួន ដោយទទួលបានការប្រឹក្សាយោបល់ជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីធ្វើកិច្ចសហប្រតិបត្តិការប្រកបដោយចេរភាព។[79]

[79] មាត្រា៦៨ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

# សេចក្តីសន្និដ្ឋាន

តាមការបកស្រាយខាងលើអំពីអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម តាមច្បាប់ជាតិនិងច្បាប់អន្តរជាតិ ឃើញថាមានចំណុចដូចគ្នាមួយចំនួន។ អាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្មក្រោមច្បាប់ជាតិនិងអន្តរជាតិសុទ្ធតែបានផ្តល់នូវសិទ្ធិនិងកាតព្វកិច្ចជូនម្ចាស់តក្កកម្មក្នុងការប្រើប្រាស់ក្នុងដែលកំណត់មួយដែលសមរម្យ។ ម្យ៉ាងវិញទៀត អាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម បានដើរតួរយ៉ាងសំខាន់ក្នុងការកម្រិតនូវការប្រើប្រាស់របស់ម្ចាស់សិទ្ធិដែលម្ចាស់សិទ្ធិមិនអាចប្រើសិទ្ធិ ដែលទទួលបានមកធ្វើជាលេសនៃការប្រកួតប្រជែងមិនស្មោះត្រង់។ តួយ៉ាងអាចកំណត់បានថាអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម គឺផ្នែកមួយដែលជួយកំណត់តុល្យភាពនៃការប្រើប្រាស់សិទ្ធិរបស់ម្ចាស់តក្កកម្ម។ អ្វីដែលសំខាន់នោះក្នុងករណីដែលជាលក្ខខណ្ឌចាំបាច់ឧទាហរណ៍ដូចជាប្រទេសមានអាសន្នដោយសារជម្ងឺរាតត្បាត ឬជាតម្រូវការចាំបាច់សម្រាប់ការថែទាំសុខភាព ដូចនេះនៅក្នុងករណីទាំងនេះរដ្ឋាភិបាលអាចលូកដៃក្នុងការផ្តល់នូវអាជ្ញាប័ណ្ណចាំបាច់សម្រាប់ធ្វើការផលិតដោយផ្ទាល់ ឬអនុញ្ញាតឱ្យតតិយជនអាចមានសិទ្ធិក្នុងការផលិតតាមរយៈតក្កកម្មនោះបាន ប៉ុន្តែម្ចាស់តក្កកម្មនូវតែមានសិទ្ធិលើតក្កកម្មរបស់ខ្លួនដូចដើម។ ម្យ៉ាងវិញទៀតទាំងក្នុងច្បាប់ជាតិនិងច្បាប់អន្តរជាតិអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្មមានដូចជា អាជ្ញាប័ណ្ណដែលធ្វើឡើងដោយម្ចាស់សិទ្ធិ អាជ្ញាប័ណ្ណដែលធ្វើឡើងដោយរដ្ឋាភិបាល អាជ្ញាប័ណ្ណដែលអនុញ្ញាតដោយរដ្ឋាភិបាលជាដើម។

រួមជាមួយគ្នានេះផងដែរទោះជាប្រទេសកម្ពុជាជាផ្នែកមួយនៃ WTO ប៉ុន្តែការអនុវត្តច្បាប់ក៏ត្រូវមើលលើស្ថានភាពនៃប្រទេសផងដែរ។ អាជ្ញាប័ណ្ណនៃប្រកាសនីយតក្កកម្មក្រោមច្បាប់ជាតិនិងអន្តរជាតិក៏មានចំនុចខុសគ្នាយ៉ាងគួរឱ្យកត់សម្គាល់ផងដែរ។ តួយ៉ាងដូចជាការប្រើប្រាស់ពាក្យពេចន៍ដើម្បីកំណត់ពីប្រភេទនៃអាជ្ញាប័ណ្ណប្រកាសនីយបត្រតក្កកម្ម ដោយនៅក្នុងច្បាប់ជាតិមានប្រើប្រាស់នូវពាក្យ «អាជ្ញាប័ណ្ណបញ្ជា» សម្រាប់កំណត់ពីប្រភេទនៃអាជ្ញាប័ណ្ណ។ ប៉ុន្តែទោះជាក្នុងច្បាប់អន្តរជាតិមិនធ្វើកំណត់នូវពាក្យឱ្យចំសម្រាប់អាជ្ញាប័ណ្ណក៏ដោយក៏យើងអាចកំណត់ពីភាពដូចគ្នាតាមរយៈនិយមន័យនៃអាជ្ញាប័ណ្ណនិងលក្ខខណ្ឌលក្នុងការទទួលបាននូវអាជ្ញាប័ណ្ណនោះ។ ម្យ៉ាងវិញទៀតដោយសារប្រទេសកម្ពុជាយកចិត្តទុកដាក់យ៉ាងសំខាន់សម្រាប់វិស័យសុខាភិបាល ដូចនេះប្រទេសកម្ពុជាមានច្បាប់ដោយឡែកមួយដែលជាច្បាប់ស្តីអំពីអាជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈត្រូវបានបង្កើតឡើងក្នុងថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៨ ដែលមានគោលបំណងធ្វើយ៉ាងណាធានាថាប្រជាជនក្នុងប្រទេសកម្ពុជាទទួលបានឱសថសម្រាប់សុខភាពតាមរយៈការផ្តល់អាជ្ញាប័ណ្ណបញ្ជាឱ្យផលិត នាំចេញ និងនាំចូលផលិតផលឱសថក្នុងកាលៈទេសៈប្រទេសជាតិមានអាសន្នដែលកំណត់ដោយក្រសួងសុខាភិបាល។

ដូចនេះហើយតាមរយៈការបកស្រាយខាងលើនេះ យើងឃើញថាក្នុងករណីដែលមានការរកឃើញនូវឱសថសម្រាប់ព្យាបាលនូវជម្ងឺណាមួយ ហើយឱសថនោះបានក្លាយជាឱសថដែលចាំបាច់សម្រាប់បុគ្គលជាច្រើនដូចនេះ

ម្ចាស់តក្កកម្មមិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការតម្លើងថ្លៃឱសថនោះឱ្យមានតម្លៃថ្លៃខ្លាំងនោះទេ ព្រោះរដ្ឋាភិបាលមានសិទ្ធិក្នុងផ្តល់អាជ្ញាប័ណ្ណ ទៅលើតក្កកម្មនោះដោយរដ្ឋាភិបាលអាចធ្វើការផលិតដោយខ្លួនឯង ឬក៏អនុញ្ញាតទៅឱ្យតតិយជនធ្វើការផលិតលើតក្កកម្មនោះ ដោយផ្តល់មកវិញនូវតម្លៃតបស្នងមួយចំនួន។ ឧទាហរណ៍ស្រួលយល់បំផុតគឺដូចជាយើងសព្វថ្ងៃនេះជម្ងឺកូវីត១៩ បានវាយលុកទូទាំងពិភពលោក ដូចនេះក្នុងករណីមានក្រុមហ៊ុនឱសថស្ថានណាមួយរកឃើញថ្នាំដែលព្យាបាលជម្ងឺកូវីត១៩ បើនៅក្នុងករណីដែលចាំបាច់រដ្ឋាភិបាលនៃប្រទេសនោះអាចធ្វើការផ្តល់អាជ្ញាប័ណ្ណបាន។ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជាយើង ទោះយើងជាសមាជិកនៃសន្ធិសញ្ញាទាំងឡាយនៃប្រកាសនីយបត្រតក្កកម្មក៏អាជ្ញាធរកម្ពុជាពុំធ្លាប់ប្រើប្រាស់សិទ្ធិនេះពីមុនមកឡើយ។

ដូចនេះបានសរបញ្ជាក់ឱ្យឃើញថាវិស័យប្រកាសនីយបត្រតក្កកម្មនៅមានកម្រិតនៅឡើយ ដោយប្រជាជនច្រើនពុំសូវយល់ដឹងឱ្យបានច្បាស់លាស់ពីប្រកាសនីយបត្រតក្កកម្មនេះ។ ជាមួយគ្នានេះផងដែរ រដ្ឋាភិបាលប្រទេសកម្ពុជាគួរតែជម្រុញឱ្យមានការយល់ដឹងឱ្យកាន់តែស៊ីជម្រៅផ្នែកប្រកាសនីយបត្រតក្កកម្មនេះ ព្រោះពិភពលោកកំពុងដើរឆ្ពោះទៅកាន់ឧស្សាហកម្ម៤.0 ដែលជាការប្រកួតប្រជែងផ្នែកបច្ចេកវិទ្យាឧស្សាហកម្មកាន់តែកើនឡើងខ្ពស់។ អ្វីដែលពិសេសជាងនេះទៀតនោះ គឺធ្វើយ៉ាងណានាថាការអនុវត្តច្បាប់ប្រកបសុក្រិតភាពដើម្បីទាក់ទាញប្រទេសដែលមានភាពជឿនលឿនផ្នែកឧស្សាហកម្មដើម្បីមកវិនិយោគនៅកម្ពុជា។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវកន្លងមកយើងបានកត់សម្គាល់ឃើញថា ចាប់តាំងពីពេលដែលប្រទេសកម្ពុជាបានត្រៀមខ្លួន និងបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤មក រាជរដ្ឋាភិបាល ព្រមទាំងក្រសួងពាក់ព័ន្ធនានារបស់កម្ពុជា បានខិតខំប្រឹងប្រែងក្នុងការអនុមត័ច្បាប់ទាក់ទងវិស័យកម្មសិទ្ធិបញ្ញា និង បង្កើតទំនាក់ទំនងជាមួយនឹងអន្តរជាតិក្រោមកិច្ចសហប្រតិបត្តិការក្នុងវិស័យកម្មសិទ្ធិឧស្សាហកម្ម ក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីទទួលបាននូវលទ្ធផលគាប់ប្រសើរ និងប្រសិទ្ធិភាពខ្ពស់ក្នុងការការពារគំនិតច្នៃប្រឌិត ការបង្កើតថ្មីនៃតក្កកម្ម រួមទាំងអាជីវកម្មរបស់ប្រជាជនកម្ពុជា ឬជនបរទេសដែលមានឆន្ទៈចង់ពង្រីកស្នាដៃតក្កកម្មខ្លួនក្នុងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែទន្ទឹមនឹងនេះវាក៏ជាបញ្ហាដែលគួឱ្យបារម្ភផងដែរ ដោយសារតែកម្ពុជាធ្លាប់ជួបនឹងភ្លើងសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំ បណ្តាលឱ្យបាត់បង់នូវរាល់ឯកសាដែលបន្សល់ទុក ក៏ដូចជាបុគ្គលដែលមានចំណេះជំនាញអស់ជាច្រើននាក់។ បច្ចុប្បន្នកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ យើងកំពុងតែបណ្តុះបណ្តាលយុវជន ក៏ព្រោះពុំទាន់សំបូរធនធានមនុស្ស ហើយជាមួយគ្នានេះសេដ្ឋកិច្ចជាតិរបស់យើងក៏នៅមានកម្រិត ខ្វះនូវឧបករណ៍សម្ភារៈគ្រប់គ្រាន់ ដើម្បីធ្វើការដកពិសោធន៍អំពីវិទ្យាសាស្ត្រដែលមានក្នុងឧស្សាហកម្មកម្មសិទ្ធិនៅឡើយ ដែលជាហេតុនាំឲ្យប្រទេសយើងដើរក្រោយគេក្នុងជំនាញវិទ្យាសាស្ត្រ-បច្ចេកទេសតក្កកម្ម ហើយប្រសិទ្ធិភាពរបស់ច្បាប់ក៏ពុំបានប្រើឲ្យអស់ពីលទ្ធភាពផងដែរ។ ជាក់ស្តែងបច្ចុប្បន្ននេះ សង្គមយើងបាននាំចូលនូវផលិតផល និងសម្ភារៈប្រើប្រាស់ទំនើបៗជាច្រើនពីក្រៅប្រទេសមានដូចជា វៀតណាម ថៃ កូរ៉េ ជប៉ុន ចិន ហុងកុង អ៊ឺរ៉ុបជាដើម ធ្វើឱ្យជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាព។ ដើម្បីជាដំណោះស្រាយក្នុងការជំរុញការរីកចម្រើននៃកម្មសិទ្ធិឧស្សាហកម្ម-តក្កកម្មក្នុងប្រទេស ជាមតិយោបល់គប្បីយើងទាំងអស់គ្នាជាប្រជាជនគួរតែចេះឈឺឆ្អាលត្រូវរួមសាមគ្គីគ្នាជាមួយរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធពីគ្រប់មជ្ឈដ្ឋាន ជម្រុញលើកទឹកចិត្តដល់ប្រជាជនដើម្បីឱ្យគាត់មានគំនិតធ្វើការស្រាវជ្រាវច្នៃប្រឌិតបង្កើតស្នាដៃផលិតផលថ្មីៗ ធ្វើការឧបត្ថម្ភគាំទ្រដល់តក្កករដែលគាត់សម្រេចបាននូវតក្កកម្មមុនដំបូងគេ បណ្តុះស្មារតីប្រជាពលរដ្ឋឱ្យងាកមកប្រើប្រាស់ និងឱ្យតម្លៃផលិតផលដែលផលិតបាននៅក្នុងស្រុក ពន្យល់ និងផ្សព្វផ្សាយពីសារៈសំខាន់របស់ច្បាប់ទៅដល់ពលរដ្ឋគ្រប់រូប អប់រំមន្ត្រីទទួលបន្ទុកគ្រប់ជាន់ថ្នាក់ដោយផ្អែកលើចំណេះ និងសមត្ថភាព។ ម៉្យាងទៀត ការរៀបចំឱ្យមានការដោះស្រាយវិវាទទាំងក្រៅ និងក្នុងប្រព័ន្ធតុលាការដាច់ដោយឡែក មានភាពច្បាស់លាស់ឈរលើគោលការណ៍សុចរិតត្រឹមត្រូវ ក៏ជាមូលដ្ឋាននាំឱ្យមានការជឿទុកចិត្តពីសំណាក់ប្រជាជន និងវិនិយោគិនបរទេសដែលមានបំណងចង់ធ្វើវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាដែរ។

# ឯកសារយោង

## ❖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា
- សន្ធិសញ្ញាស្តីពីសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម
- ក្រុមកម្មសិទ្ធិបញ្ញាបារាំង
- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូឧស្សាហកម្ម ឆ្នាំ២០០៣។
- ច្បាប់ស្តីការងារ
- ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ
- ប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

## ❖ សៀវភៅដែលបានបោះពុម្ពផ្សាយ

- សាស្ត្រាចារ្យ ទេព សុខ សៀវភៅនីតិកម្មសិទ្ធិបញ្ញា ឆ្នាំ២០២០-២០២១
- សាស្ត្រាចារ្យអនុបណ្ឌិត លឹម យូសួ សៀវភៅសេចក្តីផ្តើមនីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០១៣
- ឯកឧត្តម តន យឿន, សាស្ត្រចារ្យ អ៊ុក វណ្ណារ័ត្ន សៀវភៅនីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០១៣
- សាស្ត្រចារ្យ នី វិចិត្រ សៀវភៅនីតិកម្មសិទ្ធិបញ្ញាកម្ពុជា ឆ្នាំ ២០១៣
- សាស្ត្រចារ្យ កាន់ សុទ្ធប៉ូលីន សៀវភៅនីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០១៣

## ❖ គេហទំព័រ

- ករណីសិក្សា Bayer Corporation vs. Union of India and Others (Bayer v. Natco) សេចក្តីសម្រេចចុះនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៣ https://spicyip.com/wp-content/uploads/2018/02/Natco-v.-Bayer-INTELLECTUAL-PROPERTY-APPELLATE-BOARD-CHENNAI-%E2%80%93-4th-March-2013.pdf (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១)
- ករណីសិក្សា United States Vs. Glaxo Group LTD សេចក្តីសម្រេចដោយតុលាការជាន់ខ្ពស់របស់សហរដ្ឋអាមេរិកដែលចុះថ្ងៃទី២២ខែមករាឆ្នាំ១៩៧៣ https://www.supremecourt.gov/pdfs/transcripts/1972/71-666_11-09-1972.pdf

https://supreme.justia.com/cases/federal/us/410/52/ (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០២១)

- Fisher, William Weston. "Patent". Encyclopedia Britannica, 27 May. 2019, https://www.britannica.com/topic/patent (ចូលទស្សនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១)

# ឧបសម្ព័ន្ធ